ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# យុទ្ធសាស្ត្រ

# ស្តីពី

# ការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ

# ២០១៩ - ២០២៥

រៀបចំដោយ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# បុព្វកថា

**«យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥»** គឺជាសមាសភាគដ៏មានសារៈសំខាន់មួយរបស់ **«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥»** ដែលត្រូវបានដាក់ឱ្យអនុម័តដោយគណៈរដ្ឋមន្ត្រីពេញអង្គកាលពីឆ្នាំ ២០១៨ កន្លងទៅ ។ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកានេះ បានដើរតួនាទីជាយុទ្ធសាស្ត្រស្នូលនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយបានកំណត់ទិសដៅច្បាស់លាស់នៃប្រព័ន្ធថវិកាជាតិ ដែលធានាបាននូវប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់ធនធានសាធារណៈ ។

ក្រោយពីកម្ពុជាបានឆ្លងផុតពីសង្គ្រាមផ្ទៃក្នុងដ៏រ៉ាំរ៉ៃជាង ២ ទសវត្សកន្លងមក ដែលបានបំផ្លាញហេដ្ឋារចនាសម្ព័ន្ធក្នុងប្រទេសស្ទើរទាំងស្រុង, រាជរដ្ឋាភិបាលកម្ពុជា បានខិតខំដាក់ចេញនូវយុទ្ធសាស្ត្រជាច្រើនទៅតាមដំណាក់កាលនីមួយៗនៃអាណត្តិរាជរដ្ឋាភិបាល សម្រាប់ធ្វើការអភិវឌ្ឍជាតិជាជំហានៗ ។ ដើម្បីសម្រេចបាននូវគោលដៅជាតិទាំងនេះ ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដើរតួនាទីជាឧបករណ៍សេដ្ឋកិច្ចយ៉ាងសំខាន់ក្នុងការទ្រទ្រង់នូវការអភិវឌ្ឍស្ទើរគ្រប់វិស័យ, ការជំរុញ និងរក្សាចីរភាព នៃកំណើនសេដ្ឋកិច្ចជាតិ ។ ជាក់ស្តែង, ជាមួយនឹងការរក្សាបាននូវកំណើនសេដ្ឋកិច្ចជាមធ្យម ៧,៧% ក្នុងឆ្នាំ ក្នុងរយៈពេលជាងពីរទសវត្សចុងក្រោយ, ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់បានកើនឡើងប្រមាណជាង ៤ ដង និងការកាត់បន្ថយភាពក្រីក្រក្នុងល្បឿនលឿនមកនៅក្នុងរង្វង់ ១០% ធ្វើឱ្យកម្ពុជាបានប្រែក្លាយខ្លួនពីប្រទេសមានចំណូលទាប មកជាប្រទេសមានចំណូលមធ្យមកម្រិតទាបកាលពីឆ្នាំ ២០១៥ កន្លងទៅ ។ លទ្ធផលនេះ គឺជាភស្តុតាងឆ្លុះបញ្ចាំងអំពីការដាក់ចេញនូវគោលនយោបាយ, យុទ្ធសាស្ត្រ និងការដឹកនាំរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាលតាមមាគ៌ាដ៏ត្រឹមត្រូវ ដោយមិនត្រឹមតែបាននាំនាវាកម្ពុជាមួយនេះ រំដោះខ្លួនឱ្យចាកផុតពីប្រទេសដែលរងការបំផ្លិច-បំផ្លាញស្ទើរទាំងស្រុងដោយសារសង្គ្រាមស៊ីវិល, ជាទីវាលពិឃាដដែលគេភ័យខ្លាចគ្រប់គ្នា និងជាប្រទេសដែលរងនូវការហ៊ុំព័ទ្ធដោយទណ្ឌកម្មសេដ្ឋកិច្ចប៉ុណ្ណោះទេ តែថែមទាំងបានក្លាយជាប្រទេសខ្លាសេដ្ឋកិច្ចថ្មីនៅអាស៊ី, និងកំពុងឈានឡើងក្នុងជំហានដ៏រឹងមាំ ក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នាឆ្នាំ២០៣០ ខាងមុខទៀតផង ។

ក្នុងរយៈពេល ១៥ ឆ្នាំកន្លងទៅនេះ, កម្ពុជាបានអនុវត្តប្រកបដោយជោគជ័យនូវយុទ្ធសាស្ត្រចតុកោណដំណាក់-កាលទី១, ទី២, និងទី៣ ដោយបានធ្វើឱ្យកម្ពុជាកំពុងឈានឡើងទៅកាន់ដំណាក់កាលថ្មីមួយទៀតកាន់តែខ្ពស់ត្រដែតនៅលើវិថីនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ក្នុងមហិច្ឆតាចិញ្ចឹមចិត្តប្រែក្លាយខ្លួនជាប្រទេសដែលមានចំណូលខ្ពស់នាឆ្នាំ២០៥០ ដោយឈរលើភាពជាម្ចាស់ និងការទទួលខុសត្រូវខ្ពស់លើជោគវាសនារបស់ខ្លួន ។ ការងារកែទម្រង់លើគ្រប់វិស័យ និងកាន់តែស៊ីជម្រៅ គឺជាកម្លាំងស្នូលនៃការពង្រឹង និងធានានូវលទ្ធផលជោគជ័យនៃគោលដៅអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាល ចាំបាច់ត្រូវបង្កើនកិច្ចខិតខំប្រឹងប្រែងកាន់តែខ្លាំងក្លាថែមទៀត ក្នុងការជំរុញពិពិធកម្មសេដ្ឋកិច្ច និងលើកកម្ពស់ភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ តាមរយៈការដាក់ចេញ និងជំរុញការអនុវត្ត **«យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥»** ក្នុងគោលដៅបង្កើន និងលើកកម្ពស់ការគ្រប់គ្រងការវិនិយោគសាធារណៈឱ្យកាន់តែឆ្លើយតបនឹងតម្រូវការអាទិភាព, ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, និងចីរភាព សំដៅធានាបាននូវការបែងចែក និងប្រើប្រាស់ធនធានសាធារណៈប្រកបដោយសមធម៌។

លើសពីនេះ, ការឈានទៅបង្កើតប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈដ៏រឹងមាំមួយ នឹងធ្វើឱ្យមានការប្រែប្រួលសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នមួយចំនួន, ព្រមទាំងផ្លាស់ប្តូររបៀបបំពេញការងារ ដែលក្រសួង

ស្ថាប័ន និងគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ ចាំបាច់ត្រូវបុរេសកម្ម, សកម្ម, អន្តរសកម្ម, និងម៉ឺងម៉ាត់ជាងមុន ដើម្បីមិនត្រឹមតែធានាថាគ្មានការរាំងស្ទះដល់ចលនាការអភិវឌ្ឍប្រទេស ដោយការជាប់គាំងនៃគម្រោងវិនិយោគសាធារណៈនៅដំណាក់-កាលណាមួយនោះទេ, តែថែមទាំងជួយលើកកម្ពស់ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, និងចីរភាពនៃការវិនិយោគសាធារណៈ ឱ្យកាន់តែប្រសើរជាងមុនទៀតផង សំដៅធានាបាននូវបរិយាប័ន្ន ទាំងក្នុងផ្នែកសេដ្ឋកិច្ច និងក្នុងផ្នែកសង្គម ។ *ក្នុងស្មារតីនេះ, ការអនុវត្តយុទ្ធសាស្ត្រនេះ ត្រូវប្រកាន់យកនូវអភិក្រម* ***«ប្រយ័ត្នប្រយែង, សន្សឹមៗ, ឈរលើគោលការណ៍ប្រាកដនិយម, ទន់ភ្លន់, និង រៀនផង-ធ្វើផង »*** ។ ទោះជាយ៉ាងនេះក្តី, ក្នុងបុព្វហេតុនៃការជំរុញល្បឿននៃការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ រាជរដ្ឋាភិបាលក៏នឹងពង្រឹងឆន្ទៈខ្ពស់លើភាពជាអ្នកដឹកនាំ, ស្មារតីម្ចាស់ការប្រកបដោយការទទួលខុសត្រូវខ្ពស់, នឹងពង្រឹងសមត្ថភាពស្ថាប័ន ដោយធ្វើវិចារណកម្មមុខងារ និងសម្រិតសម្រាំងរកមន្ត្រីមានសមត្ថភាពខ្ពស់ ប្រកបដោយទេព្យកោសល្យ, គុណវុឌ្ឍិ និងការប្តេជ្ញាចិត្តខ្ពស់ សម្រាប់ដឹកនាំអនុវត្តការដ្ឋានកែទម្រង់នេះ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្ត និងសម្រេចគោលដៅតាមការរំពឹងទុក។

ជាចុងក្រោយ, ខ្ញុំសូមសម្តែងនូវការវាយតម្លៃខ្ពស់, ការកោតសរសើរ, និងអំណរគុណ ជូនចំពោះ **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងឯកឧត្តម និងលោកជំទាវ ជារដ្ឋមន្ត្រី និងប្រធានស្ថាប័ន, ព្រមទាំងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ទាំងអស់ ដែលបានខិតខំប្រឹងប្រែងយ៉ាងប្តូរផ្តាច់ ក្នុងការដឹកនាំ និងសហការអនុវត្តការងារកែទម្រង់នានារបស់រាជរដ្ឋាភិបាល ជាពិសេស ក្នុងការដ្ឋានកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយភាពជាម្ចាស់ និងការទទួលខុសត្រូវខ្ពស់ រហូតទទួលបានសមិទ្ធផលគួរជាទីមោទនៈដូចពេលបច្ចុប្បន្ន ។ នៅពេលខាងមុខនេះ ការងារកែទម្រង់ គឺមានលក្ខណៈកាន់តែស្មុគស្មាញ និងលំបាកជាងមុន ដែលទាមទារឱ្យយើងគ្រប់គ្នា ត្រូវតែពង្រឹង និងយកចិត្តទុកដាក់ឱ្យកាន់តែខ្លាំងក្លាថែមទៀត ដើម្បីបំពេញសេចក្តីត្រូវការ និងការចង់បានរបស់ប្រជាជនកម្ពុជា ។ អាស្រ័យហេតុនេះ, ខ្ញុំសូមណែនាំឱ្យ ក្រសួង ស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាល ត្រូវតែប្រកាន់យកនូវអភិក្រមអនុវត្តការងារប្រកបដោយបុរេសកម្ម និងសកម្ម ដើម្បីធានាបាននូវភាពជោគជ័យបន្តទៀត ជាពិសេស ត្រូវប្រកាន់យកនូវគោលការណ៍ និងស្មារតីភ្ញាក់រលឹក ធ្វើការកែទម្រង់ជាប្រចាំតាមអភិក្រម **«ងូតទឹក ឆ្លុះកញ្ចក់ ដុសក្អែល ព្យាបាល និងវះកាត់ »** ។

ថ្ងៃអង្គារ ៩រោច ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# អារម្ភកថា

ក្នុងរយៈពេល ១៥ ឆ្នាំ កន្លងទៅនេះ, ក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, រាជរដ្ឋាភិបាល កសាង និងសម្រេចបាននូវសមិទ្ធផលជាសារវន្តទៅតាមគោលដៅនៃដំណាក់កាលនីមួយៗ ក្នុងនោះ៖ ដំណាក់កាលទី១ គឺ **«ភាពជឿទុកចិត្តបាននៃថវិកា»** និងដំណាក់កាលទី២ គឺ **«គណនេយ្យភាពហិរញ្ញវត្ថុ»** ។ បច្ចុប្បន្ន ដំណាក់កាលទី៣ គឺ **«ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ»** បាននិងកំពុងបោះជំហានទៅមុខប្រកបដោយភាពប្រយ័ត្នប្រយែង ដោយក្នុងនោះ រាជរដ្ឋាភិបាលបានដាក់ចេញនូវ **«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥»** ជាស្នូលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ យុទ្ធសាស្ត្រនេះ មានគោលបំណងប្រែក្លាយជាបណ្តើរៗនូវប្រព័ន្ធថវិកាកម្ពុជាឱ្យក្លាយជាប្រព័ន្ធមួយដែលមានប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាពស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ ដែលបានកំណត់ទិសដៅច្បាស់លាស់សម្រាប់ដំណាក់កាលទី៤ គឺ **«គណនេយ្យភាពសមិទ្ធកម្ម»** ជាដំណាក់កាលចុងក្រោយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលគ្រោងនឹងចាប់ផ្តើមនៅឆ្នាំ ២០២១ ខាងមុខ។

រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយឆន្ទៈមោះមុត និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាលើការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ តាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ រួមជាមួយនឹងការកែទម្រង់ស៊ីជម្រៅ និងមុតស្រួចរបស់រាជរដ្ឋាភិបាល ពិសេស ការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សំដៅបែងចែកធនធានប្រកបដោយសមធម៌ ដើម្បីធានាឱ្យបាននូវចីរភាព និងបរិយាប័ន្ននៃការអភិវឌ្ឍកម្ពុជា។

ជាការពិត, ការអភិវឌ្ឍប្រទេសជាតិអាចរីកចម្រើនទៅមុខបាន ដរាបណាយើងរក្សាបាននូវសន្តិភាពពេញលេញ និងស្ថេរភាពសង្គម ហើយការធានាបាននូវសន្តិភាព និងស្ថេរភាពសង្គម គឺបានពីផ្លែផ្កានៃការអភិវឌ្ឍប្រកបដោយចីរភាព, សមធម៌, និងបរិយាប័ន្ន។ ក្នុងន័យនេះ, ការដឹកនាំប្រទេសដែលចេញពីចំណុចសូន្យ គឺពុំមែនជាការងារងាយស្រួលនោះទេ សម្រាប់ថ្នាក់ដឹកនាំប្រទេស ដើម្បីធានាឱ្យបានទាំងការអភិវឌ្ឍប្រទេសផង ព្រមទាំងធានានូវសុខសន្តិភាព និងស្ថេរភាពទូទាំងប្រទេសផង។ សម្រាប់កម្ពុជា គឺពិតជាភ័ព្វសំណាងណាស់ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រី** តែងតែឈរលើគោលការណ៍តម្កល់ប្រយោជន៍ជាតិ និងប្រជាជនជាធំ ហើយបានដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រនានាក្នុងទិសដៅដ៏ត្រឹមត្រូវ សម្រាប់ធានាបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ការកសាងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ គឺជាគ្រឹះនៃការជំរុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព ។ ជាមួយគ្នានេះ, ការវិនិយោគសាធារណៈចំទិសដៅអាទិភាព ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព គឺកាន់តែមានសារៈសំខាន់ និងចាំបាច់សម្រាប់ដំណាក់កាលអភិវឌ្ឍន៍របស់កម្ពុជា។ ក្នុងន័យនេះ, រាជរដ្ឋាភិបាល ចាំបាច់ត្រូវតែរៀបចំ និងដាក់ចេញនូវយុទ្ធសាស្ត្រមុតស្រួច និងម៉ឺងម៉ាត់ ក្នុងការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ជាពិសេស សម្រាប់បរិការណ៍បច្ចុប្បន្នរបស់កម្ពុជា ដែលម្យ៉ាង (១) កំពុងមាន

តម្រូវការទុនវិនិយោគកាន់តែធំ សម្រាប់ឆ្លើយតបនឹងតម្រូវការអភិវឌ្ឍន៍កម្ពុជានៅដំណាក់កាលថ្មី, ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការពង្រឹងសមត្ថភាពប្រកួតប្រជែង ប៉ុន្តែ(២) កម្ពុជាក៏កំពុងប្រឈមនឹងភាពកម្រនៃធនធានវិនិយោគសាធារណៈទាំងពីប្រភពខាងក្រៅ និងផ្ទៃក្នុង។ លើសពីនេះ, (៣) ការវិនិយោគសាធារណៈកាន់តែមានចរិតស្មុគស្មាញ, តម្លៃកាន់តែថ្លៃ និងទំហំវិនិយោគកាន់តែធំ។

ក្នុងទិសដៅនេះ ខ្ញុំបានចាត់ក្រុមការងារមួយ ស្ថិតក្រោមការដឹកនាំកម្រិតគោលនយោបាយដោយ **ឯកឧត្តម វង្សី វិស្សុត រដ្ឋលេខាធិការប្រចាំការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ឱ្យរៀបចំឯកសារយុទ្ធសាស្ត្រដែលមានចរិតលក្ខណៈជាការកែទម្រង់ស៊ីជម្រៅ និងមុតស្រួចលើផ្នែកគ្រប់គ្រងការវិនិយោគសាធារណៈ ដែលនឹងជួយបំពេញភាពគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡាគ្នា នៃការអនុវត្តបណ្ដាគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល និងត្រូវចាត់ទុកជាសមាសភាគមួយដ៏សំខាន់នៃ **«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥»** នោះគឺ **«យុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥»** ។

**«យុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥»** គឺជាឯកសារតម្រង់ទិស ដែលបង្ហាញពីទិដ្ឋភាពរួមនៃការគ្រប់គ្រងការវិនិយោគសាធារណៈ ដោយបានសិក្សាអំពី **«ក្របខ័ណ្ឌនៃការគ្រប់គ្រងការវិនិយោគសាធារណៈ៖ ការអនុវត្តជាសកល និងបរិការណ៍កម្ពុជា»** និងបានដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្រមួយចំនួន, សំដៅឈានទៅបង្កើតឱ្យបាននូវ **«ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរួមមួយរបស់ជាតិនៅមុនដំណាច់ឆ្នាំ២០២៥»** ដែលធានាបាននូវភាពឆ្លើយតប, ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាពនៃការបែងចែក និងការប្រើប្រាស់ធនធានសាធារណៈ ស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ និងបរិការណ៍ជាក់ស្ដែងរបស់កម្ពុជា សំដៅរួមចំណែកបង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង ដែលជាមូលដ្ឋានគ្រឹះក្នុងការធានាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន ឆ្ពោះទៅសម្រេចបង្គោលចរឆ្នាំ២០៣០ និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ។

វិធានការជាយុទ្ធសាស្ត្រ នឹងត្រូវអនុវត្តជា ២ ដំណាក់កាល រួមមាន៖ វិធានការជាយុទ្ធសាស្ត្របន្ទាន់ចំពោះមុខ និងវិធានការជាយុទ្ធសាស្ត្ររយៈពេលមធ្យម ដែលមានគោលដៅ៖ ១)- ពិនិត្យមើលឡើងវិញ និងរៀបចំក្របខ័ណ្ឌគតិយុត្ត សម្រាប់ធ្វើឱ្យមានសង្គតិភាពកម្រិតគោលការណ៍ និងអភិក្រមនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ, ២)- ពង្រឹងការធ្វើអាទិភាវូបនីយកម្មការវិនិយោគសាធារណៈបីឆ្នាំរំកិល, ការធ្វើផែនការនីយកម្មនៃការវិនិយោគសាធារណៈ និងការធ្វើសមាហរណកម្មថវិកាវិនិយោគសាធារណៈពីប្រភពថវិកាជាតិ និងថវិកាដៃគូអភិវឌ្ឍន៍, ៣)- ពង្រឹងការធ្វើសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ, ៤)- ពង្រឹងគុណភាពប្រសិទ្ធភាពអនុវត្ត និងភាពផ្សារភ្ជាប់រវាងកម្មវិធីវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល ជាមួយនឹងថវិកានីយកម្មការវិនិយោគសាធារណៈ, ៥)- បង្កើត និង/ឬ ពង្រឹងយន្តការស្ថាប័នសម្រាប់គ្រប់គ្រងការវិនិយោគសាធារណៈ, និង ៦)- រៀបចំ និងបង្កើតឯកសារណែនាំស្ដីពីគោលការណ៍ និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការគម្រោងវិនិយោគសាធារណៈ។

ពិតណាស់ថា គោលដៅចម្បងនៃយុទ្ធសាស្ត្រនេះ គឺការកែទម្រង់ និងបង្កើតប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរួមមួយរបស់ជាតិ។ ខ្ញុំគួរមានភាពចាំបាច់គួសរំលេចខ្លឹមសារគន្លឹះនៅត្រង់ចំណុចនេះថា យុទ្ធសាស្ត្រនេះ

មិនមែនត្រឹមតែផ្តោតលើការកែទម្រង់នៅដំណាក់កាលចំណាយវិនិយោគសាធារណៈប៉ុណ្ណោះទេ ប៉ុន្តែជាការកែទម្រង់លើប្រព័ន្ធគ្រប់គ្រងចំណាយហេដ្ឋារចនាសម្ព័ន្ធសាធារណៈទាំងស្រុង ដែលមានភាពប្រទាក់ក្រឡាគ្នា និងបំពេញឱ្យគ្នាទៅវិញទៅមក រវាង÷

១)- «**ការគ្រប់គ្រងផែនការវិនិយោគសាធារណៈ**» ដើម្បីឆ្លើយតបនឹងតម្រូវការអាទិភាព សម្រាប់ការអភិវឌ្ឍជាតិរយៈពេលមធ្យម,

២)- «**ការគ្រប់គ្រងថវិកា**» ដើម្បីធានាឱ្យការវិភាជថវិកាវិនិយោគ ត្រូវបានធ្វើឡើងដោយឆ្លើយតប និងអនុលោមតាមក្របខ័ណ្ឌថវិការយៈពេលមធ្យម និងត្រូវបានគិតគូជាមួយនឹងការរៀបចំថវិកាចរន្ត សម្រាប់ចំណាយប្រតិបត្តិការ និងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ, និង

៣)- «**ការគ្រប់គ្រងគម្រោងវិនិយោគនៅគ្រប់ដំណាក់កាលនៃវដ្តគម្រោង**» ដើម្បីធានាប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, និងចីរភាព នៃហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។

ក្នុងន័យនេះ, ការចូលរួមយ៉ាងសកម្ម និងប្រកបដោយការប្តេជ្ញាចិត្តខ្ពស់របស់គ្រប់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល និងតួអង្គពាក់ព័ន្ធទាំងអស់ រួមទាំងវិស័យឯកជន និងដៃគូអភិវឌ្ឍន៍ នៅក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ គឺជាបុរេលក្ខខណ្ឌកំណត់ភាពជោគជ័យនៃការដ្ឋានកែទម្រង់ថ្មីមួយនេះ ។

ជាទីបញ្ចប់, ខ្ញុំក៏សូមគោរពសម្តែងកតញ្ញូតាធម៌ និងកតវេទិតាធម៌យ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលសម្តេចជាអគ្គមគ្គុទេសក៍ដ៏ឆ្នើមប្រកបដោយឧត្តមគតិនយោបាយមុតស្រួច ហើយតែងតែផ្តល់ការគាំទ្រទាំងផ្នែកនយោបាយ និងផ្តល់អនុសាសន៍គន្លឹះៗ ព្រមទាំងតម្រង់ទិស លើការងារកែទម្រង់របស់រាជរដ្ឋាភិបាល។

ថ្ងៃ អង្គារ ៩រោច ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែ តុលា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# មាតិកា

ទំព័រ


**១. សេចក្តីផ្តើម** ........................................ ១

១.១. សាវតារ ........................................ ១

១.២. សារៈសំខាន់ ........................................ ២

**២. ចក្ខុវិស័យ** ........................................ ៦

**៣. គោលបំណង និងគោលដៅ** ........................................ ៧

**៤. ក្របខ័ណ្ឌនៃការគ្រប់គ្រងវិនិយោគសាធារណៈ៖ បទពិសោធន៍ជាអន្តរជាតិ និងបរិការណ៍កម្ពុជា** ........ ៨

៤.១. បទពិសោធន៍ជាអន្តរជាតិ ........................................ ៨

៤.១.១. ក្របខ័ណ្ឌគ្រប់គ្រងការវិនិយោគសាធារណៈ ........................................ ៩

៤.១.២. ដំណាក់កាលនៃវដ្តគម្រោងវិនិយោគសាធារណៈ ........................................ ១១

៤.១.៣. និន្នាការសកល ........................................ ១៤

៤.២. បរិការណ៍កម្ពុជា ........................................ ១៥

៤.២.១. ក្របខ័ណ្ឌគោលនយោបាយ ........................................ ១៥

៤.២.២. ក្របខ័ណ្ឌគតិយុត្ត ........................................ ១៦

៤.២.៣. យន្តការស្ថាប័ន ........................................ ១៨

៤.២.៤. យន្តការគាំទ្រហិរញ្ញវត្ថុ ........................................ ២១

៤.២.៥. គោលការណ៍ និងអភិក្រមនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ........................................ ២២

៤.៣. បញ្ហាប្រឈម និងកាលានុវត្តភាព ........................................ ២៦

៤.៣.១. បញ្ហាប្រឈម ........................................ ២៦

៤.៣.២. កាលានុវត្តភាព ........................................ ២៩

**៥. វិធានការជាយុទ្ធសាស្ត្រ** ........................................ ៣០

៥.១. វិធានការជាយុទ្ធសាស្ត្របន្ទាន់ចំពោះមុខ ........................................ ៣០

៥.២. វិធានការជាយុទ្ធសាស្ត្ររយៈពេលមធ្យម ........................................ ៣៤

**៦. ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការអនុវត្តវិធានការជាយុទ្ធសាស្ត្រ** ........................................ ៣៦

**៧. សេចក្តីសន្និដ្ឋាន** ........................................ ៣៧

ឧបសម្ព័ន្ធ ១ : សទ្ទានុក្រម

ឧបសម្ព័ន្ធ ២ : ផែនការសកម្មភាពរួម សម្រាប់អនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ

ឧបសម្ព័ន្ធ ៣ : ផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ការគ្រប់គ្រងការវិនិយោគសាធារណៈ

# សេចក្ដីផ្ដើម

# ១. សេចក្តីផ្តើម

## ១.១. សាវតារ

រាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តប្រកបដោយជោគជ័យនូវការស្តារ និងអភិវឌ្ឍប្រទេសជាតិឡើងវិញ ពីប្រទេសដែលរងនូវការបំផ្លិចបំផ្លាញស្ទើរទាំងស្រុងដោយសារសង្គ្រាមស៊ីវិល, ជាទីវាលពិឃាដដែលគេភ័យខ្លាចគ្រប់គ្នា និងជាប្រទេសដែលរងនូវការហ៊ុំព័ទ្ធដោយទណ្ឌកម្មសេដ្ឋកិច្ច, ប្រែក្លាយមកជាប្រទេសដែលមានសន្តិភាពពេញលេញ, ជាប្រទេសគោលដៅទេសចរណ៍ដ៏ទាក់ទាញរបស់តំបន់ និងពិភពលោក និងជាពិសេស គឺការសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ជាមធ្យម ៧,៧% ក្នុងឆ្នាំ ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ ហើយបានប្រែក្លាយខ្លួនជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបកាលពីឆ្នាំ២០១៥ កន្លងទៅ។ សមិទ្ធផល និងការផ្លាស់ប្តូរមុខមាត់ដ៏គួរជាទីមោទនៈបំផុតនេះ គឺកើតចេញពីការដាក់ចេញ និងអនុវត្តប្រកបដោយជោគជ័យនូវ **«គោលនយោបាយឈ្នះ-ឈ្នះ»**, **យុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណទាំងបួនដំណាក់កាល** របស់រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណទាំង២ ដំណាក់កាលខាងដើម, រាជរដ្ឋាភិបាលបានផ្តល់លំដាប់អាទិភាពនៃការវិនិយោគសាធារណៈចំនួន ៤ គឺ÷ **ផ្លូវ ទឹក ភ្លើង និងមនុស្ស** ដើម្បីជំរុញការអភិវឌ្ឍប្រទេស។ សារៈសំខាន់នៃលំដាប់អាទិភាពនេះ ត្រូវបានផ្លាស់ប្តូរទៅតាមដំណាក់កាលនីមួយៗនៃការអភិវឌ្ឍ ជាពិសេស ក្នុងដំណាក់កាលអភិវឌ្ឍន៍ថ្មីនៃការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់កម្ពុជា ពោលគឺពីប្រទេសដែលមានសេដ្ឋកិច្ចពឹងផ្អែកយ៉ាងខ្លាំងលើវិស័យកសិកម្ម ទៅជាប្រទេសដែលមានសេដ្ឋកិច្ចពឹងផ្អែកលើវិស័យឧស្សាហកម្ម និងសេវាកម្ម។ នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងទី៤ **មនុស្ស** បានក្លាយជាអាទិភាពទី១ ហើយ **ផ្លូវ ភ្លើង និងទឹក** បានក្លាយជាអាទិភាពបន្តបន្ទាប់។

ការវិនិយោគសាធារណៈនៅកម្ពុជា ត្រូវបានចាប់ផ្តើមពីដំណាក់កាលដំបូងនៅដើមទសវត្សរ៍ឆ្នាំ១៩៩០ ដោយត្រូវពឹងផ្អែកទាំងស្រុងលើហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍ ដែលមួយផ្នែកធំជាហិរញ្ញប្បទានឥតសំណង, មួយចំនួនជាឥណទានដែលមានកម្រិតសម្បទានខ្ពស់បំផុត, និងមួយចំនួនទៀតជាជំនួយបច្ចេកទេស។ ទំហំហិរញ្ញប្បទានសហប្រតិបត្តិការ បានកើនឡើងពីប្រមាណជិត ៣០០ លានដុល្លារអាមេរិក នៅឆ្នាំ១៩៩៣ រហូតដល់ប្រមាណ ២,៤ ប៊ីលានដុល្លារអាមេរិក នៅក្នុងឆ្នាំ២០១៨ គឺកើនឡើង ៨ ដង។ ក្នុងទំហំហិរញ្ញប្បទានសហប្រតិបត្តិការ ខាងលើនេះ, នៅឆ្នាំ១៩៩៣ ទំហំនៃការខ្ចីឥណទានសម្បទានសម្រាប់ការវិនិយោគសាធារណៈមានប្រមាណ ៤៦% នៃហិរញ្ញប្បទានសរុប ដែលទំហំនេះបានកើនឡើងរហូតដល់ប្រមាណ ៧៦% នៅឆ្នាំ២០១៨។ បើទោះបីជាទំហំនៃការខ្ចីឥណទានសម្បទានសម្រាប់ការវិនិយោគសាធារណៈកើនឡើងក៏ដោយ ក៏កម្ពុជានៅតែរក្សាអប្បមាទខ្ពស់លើការគ្រប់គ្រងបំណុលសាធារណៈរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, និងចីរភាព ដោយបានធ្វើឱ្យកម្ពុជា ដែលជាប្រទេសធ្លាប់មានកម្រិតអនុបាតបំណុលសាធារណៈខ្ពស់ជាងគេបំផុតនៅក្នុងតំបន់ក្លាយទៅជាប្រទេសមានអនុបាតបំណុលទាបបំផុតនៅក្នុងតំបន់។

ជាមួយនឹងកិច្ចប្រឹងប្រែងឥតឈប់ឈររបស់រាជរដ្ឋាភិបាលកន្លងមក កំណើនសេដ្ឋកិច្ចកាន់តែមានការលូតលាស់ និងក្នុងស្មារតីនៃការពង្រឹង និងកសាងភាពជាម្ចាស់ពិតប្រាកដលើកិច្ចអភិវឌ្ឍ។ នៅឆ្នាំ២០០១ រាជរដ្ឋាភិបាលពុះពារវិភាជថវិកាជាតិ តាមលទ្ធភាពដែលមានជាក់ស្តែងប្រមាណ ៥៨,៣ លានដុល្លារអាមេរិក សម្រាប់ការវិនិយោគសាធារណៈ បន្ថែមលើប្រភពហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ដើម្បីបំពេញតម្រូវការដ៏ធំសម្បើមនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ក្នុងមហិច្ឆតាជំរុញល្បឿននៃការអភិវឌ្ឍ និងចីរភាពនៃកំណើនសេដ្ឋកិច្ច ដោយត្រូវចាប់ផ្តើមពីគម្រោងដែលមានទំហំទឹកប្រាក់តូច, សាមញ្ញ, និងងាយអនុវត្ត។ ទំហំនៃការវិនិយោគសាធារណៈដោយថវិកាជាតិបានរីកធំឡើងជាលំដាប់រហូត ៧០៦,៥ លានដុល្លារអាមេរិក នៅឆ្នាំ២០១៨ ដែលស្មើនឹងប្រមាណ ២,៩% នៃផលិតផលក្នុងស្រុកសរុប គឺកើនឡើងជិត ១២ ដង ធៀបនឹងឆ្នាំ២០០១ និងបានធ្វើឱ្យសមាមាត្រនៃទំហំគម្រោងវិនិយោគសាធារណៈដោយប្រភពថវិកាជាតិនាពេលបច្ចុប្បន្នមានចំនួនរហូតដល់ប្រមាណ ១/៣ ធៀបនឹងប្រភពថវិកាពីដៃគូអភិវឌ្ឍន៍ដែលបានថយចុះពី ១០០% មកនៅត្រឹមប្រមាណ ២/៣ ។

បន្ថែមលើនេះ ដោយសារផ្លែផ្កានៃការអភិវឌ្ឍ និងជំនឿទុកចិត្តលើសុខសន្តិភាព និងស្ថិរភាពនយោបាយនៅកម្ពុជា ពីសំណាក់វិនិយោគិនទាំងក្នុងស្រុក និងក្រៅស្រុក, ការវិនិយោគសាធារណៈដោយដៃគូឯកជនក្រោមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន បើទោះបីជាមិនទាន់មានក្របខ័ណ្ឌគ្រប់គ្រងគ្រប់ជ្រុងជ្រោយក្តី ប៉ុន្តែបានចាប់ផ្តើមមានការវិនិយោគជាលើកដំបូងនៅដើមទសវត្សរ៍ឆ្នាំ១៩៩០ លើវិស័យថាមពលអគ្គិសនី និងអាកាសចរណ៍តាមយន្តការចំពោះកិច្ច ហើយការវិនិយោគនេះ បានកើនឡើងជាបន្តបន្ទាប់ ស្របតាមបរិការណ៍ជាក់ស្តែងនៃសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលចាត់ទុកថា ការចូលរួមវិនិយោគរបស់វិស័យឯកជនលើគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈមិនមែនត្រឹមតែនាំមកនូវប្រភពហិរញ្ញប្បទានបន្ថែមទេ តែថែមទាំងនាំមកនូវចំណេះដឹង-ចំណេះធ្វើ ព្រមទាំងបច្ចេកវិទ្យាទំនើបដល់វិស័យសាធារណៈ ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការវិនិយោគ និងប្រតិបត្តិការផ្តល់សេវាសាធារណៈជូនប្រជាជនទូទាំងប្រទេសទៀតផង។ ដើម្បីជំរុញការចូលរួមរបស់វិស័យឯកជនក្នុងកិច្ចការនេះ, នៅឆ្នាំ២០១៦ រាជរដ្ឋាភិបាលបានដាក់ចេញនូវ «ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន សម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០»។

ជាទិសដៅទៅមុខ, ដើម្បីធានាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយបរិយាប័ន្ន ឈានឆ្ពោះទៅសម្រេចបង្គោលចរឆ្នាំ២០៣០ ប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ និងចក្ខុវិស័យឆ្នាំ២០៥០ ជាប្រទេសចំណូលខ្ពស់, រាជរដ្ឋាភិបាល ចាំបាច់ត្រូវបង្កើនកិច្ចខិតខំប្រឹងប្រែងខ្លាំងក្លាថែមទៀត ក្នុងការជំរុញពិពិធកម្មសេដ្ឋកិច្ច និងលើកកម្ពស់ភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ តាមរយៈការបង្កើន និងលើកកម្ពស់ការគ្រប់គ្រងការវិនិយោគសាធារណៈឱ្យកាន់តែឆ្លើយតបនឹងតម្រូវការអាទិភាព, ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, និងចីរភាព សំដៅធានាបាននូវការបែងចែកធនធានសាធារណៈប្រកបដោយសមធម៌។

## ១.២. សារៈសំខាន់

ការវិនិយោគសាធារណៈ បានដើរតួនាទីជាឧបករណ៍សេដ្ឋកិច្ចយ៉ាងសំខាន់ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ, ហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់, និងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច-សង្គមផ្សេងទៀត ដែលជាមូលដ្ឋានគ្រឹះចាំបាច់សម្រាប់ការស្តារ, កសាង, និងអភិវឌ្ឍប្រទេស ហើយបាននាំកម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និង

ប្រកបដោយបរិយាប័ន្ន ជាពិសេសបានរួមចំណែកដល់ការបង្កើតការងារ, ការកាត់បន្ថយភាពក្រីក្រ, និងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាទូទាំងប្រទេស ។

ជាមួយនឹងកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្នក្នុងរង្វង់ ៧,៧% ក្នុងមួយឆ្នាំ នារយៈពេលជាងពីរទសវត្សរ៍កន្លងមក, ទំហំសេដ្ឋកិច្ចជាតិកាន់តែរីកធំធាត់ជាលំដាប់, រាជរដ្ឋាភិបាលចាំបាច់ត្រូវបន្តបង្កើនការវិនិយោគសាធារណៈលើ«វិស័យអាទិភាពទាំង ៤» និងកិច្ចការមួយចំនួនទៀត ដែលឆ្លើយតបនឹងតម្រូវការអភិវឌ្ឍន៍កម្ពុជានៅដំណាក់កាលថ្មី ជាពិសេស ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការពង្រឹងសមត្ថភាពប្រកួតប្រជែង ដែលរួមមាន÷ ១)- ការកែលម្អប្រព័ន្ធឡូជីស្ទីក, ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល, ២)- ការអភិវឌ្ឍប្រភពនៃកំណើនសេដ្ឋកិច្ចគន្លឹះ និងថ្មីៗ, និង ៣)- ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤ ជាដើម។ ទន្ទឹមនេះ, អាទិភាពនៃតម្រូវការការវិនិយោគសាធារណៈមិនត្រឹមកាន់តែរីកធំទៅតាមវិស័យអាទិភាពប៉ុណ្ណោះទេ តែត្រូវពង្រីកនៅគ្រប់កម្រិតផងដែរ ទាំងកម្រិតថ្នាក់ជាតិ, ទាំងកម្រិតថ្នាក់ក្រោមជាតិ ព្រមទាំងការវិនិយោគដោយគ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និងអង្គភាពសាធារណៈប្រហាក់ប្រហែល។

បន្ថែមលើនេះ, ក្នុងបរិការណ៍នៃតម្រូវការអភិវឌ្ឍន៍ និងរចនាសម្ព័ន្ធសេដ្ឋកិច្ចថ្មី, កម្ពុជាត្រូវផ្លាស់ប្តូរយុទ្ធសាស្ត្រនៃការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ពីការវិនិយោគដែលមានតម្លៃទាប ឱ្យបានហេដ្ឋា-រចនាសម្ព័ន្ធចំនួនច្រើន ក្នុងគោលដៅបែងចែកផលប្រកបដោយសមធម៌ និងជំរុញល្បឿននៃកំណើនសេដ្ឋកិច្ច មកជាការវិនិយោគដែលមានទំហំធំ និងតម្លៃខ្ពស់ ក្នុងគោលដៅធានាបាននូវគុណភាព, ប្រសិទ្ធភាពសេដ្ឋកិច្ច-សង្គម, និរន្តភាពបរិស្ថាន, និងភាពធន់ទ្រាំនឹងបម្រែបម្រួលអាកាសធាតុ។

*ការណ៍នេះ ធ្វើឱ្យទំហំនៃតម្រូវការវិនិយោគសាធារណៈកាន់តែរីកធំឡើងៗ ប៉ុន្តែក៏ត្រូវប្រឈមនឹងបញ្ហាភាពកម្រនៃធនធានវិនិយោគសាធារណៈ* ដែលបណ្តាលមកពី÷ ១)- ការធ្លាក់ចុះនៃប្រភពហិរញ្ញប្បទានឥតសំណង និងឥណទានដែលមានកម្រិតសម្បទានខ្ពស់ពីដៃគូអភិវឌ្ឍន៍ ដោយសារកម្ពុជាបានចាកផុតពីឋានៈជាប្រទេសដែលមានចំណូលទាប មកជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប, និង ២)- កំណើននៃបន្ទុកចំណាយចរន្ត ជាពិសេស ការកើនឡើងនៃបន្ទុកបៀវត្ស, ការអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗ, ការគាំពារសង្គម, និងការអនុវត្តវិធានការជាកញ្ចប់ត្រៀមទប់ទល់នឹងការគំរាមកំហែងពីខាងក្រៅ ដែលធ្វើឱ្យអតិរេកថវិកាសម្រាប់ទ្រទ្រង់ការវិនិយោគសាធារណៈ អាចនឹងថមថយជាយថាហេតុ ស្របពេលដែលកំណើនចំណូលជាតិ ប្រឈមនឹងកំណើនថមថយនាពេលអនាគត។

ឆ្លើយតបនឹងបញ្ហាប្រឈមនូវភាពកម្រនៃទុនវិនិយោគសាធារណៈ ជាមួយនឹងលទ្ធភាពនៃសេដ្ឋកិច្ចក្នុងដំណាក់កាលអភិវឌ្ឍន៍ថ្មី រាជរដ្ឋាភិបាលបានប្រកាន់យកគោលនយោបាយធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានសម្រាប់ការវិនិយោគសាធារណៈ ដែលរួមមាន÷ ១)- ពិពិធកម្មដៃគូអភិវឌ្ឍន៍ តាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ជាប្រពៃណី និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍សក្តានុពលថ្មីបន្ថែមទៀត, ២)- ពិពិធកម្មប្រភេទឥណទាន តាមរយៈការពិចារណា និងចរចាទទួលយកឥណទានដែលមានកម្រិតសម្បទានមធ្យម និងទាប (ឥណទានពាក់កណ្តាលពាណិជ្ជកម្ម), និង ៣)- ការខ្ចីក្នុងប្រទេសតាមរយៈការបោះលក់មូលបត្ររដ្ឋ។

ទន្ទឹមនេះ, រាជរដ្ឋាភិបាលក៏បានពិនិត្យឃើញមានចរន្តកើនឡើងនៃគម្រោងវិនិយោគសាធារណៈ ដែលមានចរិតលក្ខណៈស្មុគស្មាញ ដោយសារជាគម្រោងហិរញ្ញប្បទានដោយប្រភពចម្រុះ និងដែលមានចរិតលក្ខណៈដោយឡែកដោយហិរញ្ញប្បទានពីការធ្វើឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរដ្ឋ ផងដែរ។ ក្នុងបរិការណ៍ថ្មីនេះ, រាជរដ្ឋាភិបាលកាន់តែមានភាពចាំបាច់ក្នុងការពង្រឹងប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈឱ្យកាន់តែរឹងមាំ និងមានប្រសិទ្ធភាពខ្ពស់ថែមទៀត អនុលោមតាមគោលការណ៍គន្លឹះនៃយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ដើម្បីធានាប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានសាធារណៈ, ទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន។

ទន្ទឹមនេះ ក្រោមក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, រាជរដ្ឋាភិបាលបានរៀបចំ និងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨ - ២០២៥ ដែលបានដាក់ចេញនូវគោលដៅនៃការធ្វើសមាហរណកម្មថវិកានៅកម្រិតផែនការនីយកម្ម ទន្ទឹមគ្នានឹងការធ្វើសង្គតិភាពកម្រិតគោលការណ៍ និងអភិក្រមនៃការគ្រប់គ្រងថវិកា, និងប្រព័ន្ធរបាយការណ៍ សំដៅធានាបាននូវប្រសិទ្ធភាពខ្ពស់នៃការវិភាជ និងការអនុវត្តថវិកា ដើម្បីឈានទៅសម្រេចបាននូវលទ្ធផល និងគោលបំណងគោលនយោបាយរបស់រាជរដ្ឋាភិបាល។ គោលដៅនេះ តម្រូវឱ្យមានការធ្វើសមាហរណកម្មធនធានទាំងឡាយពាក់ព័ន្ធនឹងការវិនិយោគសាធារណៈ ដែលរួមមាន÷ ១)- សមាហរណកម្មថវិកាចរន្ត ជាមួយនឹងថវិកាវិនិយោគ, ២)- ការធ្វើសមាហរណកម្មថវិការដ្ឋបាលថ្នាក់ក្រោមជាតិ និងតម្រឹមជាមួយនឹងអាទិភាពតាមវិស័យនៃក្រសួង-ស្ថាប័នថ្នាក់ជាតិ (មន្ទីរជំនាញរាជធានី ខេត្ត), និង ៣)- ថវិកាវិនិយោគពីប្រភពផ្សេងទៀត ដូចជាថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ និងថវិកាវិនិយោគឯកជនតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន ជាមួយនឹងថវិកាវិនិយោគផ្ទាល់របស់ជាតិ ជាដើម។

ផ្អែកលើមូលដ្ឋានខាងលើ និងបរិការណ៍អភិវឌ្ឍន៍កម្ពុជានៅក្នុងដំណាក់កាលថ្មី, រាជរដ្ឋាភិបាលពិនិត្យឃើញពីភាពចាំបាច់ ដែលត្រូវតែមាន **«យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥»** ដែលជាសមាសភាគមួយនៃ **«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥»** ក្រោមក្របខ័ណ្ឌ **«កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ»** ដោយនឹងដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្រសម្រាប់ពង្រឹងការគ្រប់គ្រងការវិនិយោគសាធារណៈ ប្រកបដោយភាពឆ្លើយតប, តម្លាភាព, ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, គណនេយ្យភាព និងចីរភាពនៃការបែងចែក និងប្រើប្រាស់ធនធានសាធារណៈ ក្នុងគោលដៅបន្ត÷

១)- គាំទ្រនិងជំរុញចីរភាពនៃកំណើនសេដ្ឋកិច្ច, ពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង,

២)- បំពេញតម្រូវការទុនវិនិយោគសាធារណៈ ដែលកាន់តែរីកធំឡើង,

៣)- ធានានូវការប្រើប្រាស់ធនធានវិនិយោគចំទិសដៅឆ្លើយតបនឹងតម្រូវការអាទិភាពពិតប្រាកដ, និង

៤)- ឆ្លើយតបនឹងតម្រូវការសេវាសាធារណៈ និងធានាបាននូវសមធមិសង្គម។

ក្នុងន័យនេះ **«យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ - ២០២៥»** ត្រូវបានរៀបចំឡើងស្របតាមបរិការណ៍ជាក់ស្តែងរបស់កម្ពុជា និងឧត្តមានុវត្តន៍ជាអន្តរជាតិ ដែលនឹងដាក់ចេញនូវ÷

១)- វិធានការជាយុទ្ធសាស្ត្រ ដើម្បីសម្រេចឱ្យបាននូវការរៀបចំក្របខ័ណ្ឌគោលនយោបាយ, ក្របខ័ណ្ឌគតិយុត្ត, យន្តការស្ថាប័ន, និងយន្តការគាំទ្រហិរញ្ញវត្ថុ, និង

២)- ផែនការសកម្មភាពគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡាគ្នា ដោយកំណត់ឱ្យបានច្បាស់លាស់នូវស្ថាប័នដឹកមុខ និងស្ថាប័នទទួលខុសត្រូវ ព្រមទាំងត្រូវមានក្របខ័ណ្ឌពេលវេលាអនុវត្តជាក់លាក់។

យុទ្ធសាស្ត្រនេះ ត្រូវបានចាត់ទុកជា«**ឯកសាររស់**» ដែលអាចនឹងត្រូវកែសម្រួលជាយថាហេតុ ដើម្បីធានាសង្គតិភាពទៅតាមវឌ្ឍនាការនៃបរិការណ៍ជាក់ស្តែងនៅកម្ពុជា។

# ចក្ខុវិស័យ

# ២. ចក្ខុវិស័យ

នៅមុនដំណាច់ឆ្នាំ២០២៥ រាជរដ្ឋាភិបាលត្រូវបង្កើតឱ្យបាននូវប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរួមមួយរបស់ជាតិ ដែលធានាបាននូវភាពឆ្លើយតប, ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាពនៃការបែងចែក និងការប្រើប្រាស់ធនធានសាធារណៈ ស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ និងបរិការណ៍ជាក់ស្តែងរបស់កម្ពុជា សំដៅរួមចំណែកបង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង ដែលជាមូលដ្ឋានគ្រឹះក្នុងការធានាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន ឆ្ពោះទៅសម្រេចបង្គោលចរឆ្នាំ២០៣០ និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ។

# គោលបំណង និងគោលដៅ

## ៣. គោលបំណង និងគោលដៅ

យុទ្ធសាស្ត្រនេះ មានគោលបំណងកំណត់ក្របខ័ណ្ឌទស្សនាទានរួមមួយ សម្រាប់បង្កើតប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន (ទាំងពីថវិកាជាតិ ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ និងទុនវិនិយោគឯកជនតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន), និងនៅគ្រប់កម្រិតរដ្ឋបាល (ទាំងថ្នាក់ជាតិ ទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និងអង្គភាពសាធារណៈប្រហាក់ប្រហែល) ប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាព សំដៅរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសមធមិសង្គម។

ដើម្បីសម្រេចបានតាមគោលបំណង និងចក្ខុវិស័យខាងលើ យុទ្ធសាស្ត្រនេះមានគោលដៅ÷

១)- ពិនិត្យមើលឡើងវិញ និងរៀបចំក្របខ័ណ្ឌគតិយុត្ត សម្រាប់ធ្វើឱ្យមានសង្គតិភាពកម្រិតគោលការណ៍នៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ នៅគ្រប់ដំណាក់កាលនៃវដ្តគម្រោង, ពីគ្រប់ប្រភពហិរញ្ញប្បទាន (ទាំងថវិការដ្ឋ ថវិកាដៃគូ និងទុនវិនិយោគឯកជន) និងក្នុងគ្រប់កម្រិតរដ្ឋបាល(ទាំងថ្នាក់ជាតិ ទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែល),

២)- ពង្រឹងការធ្វើអាទិភាវូបនីយកម្មការវិនិយោគសាធារណៈបីឆ្នាំរំកិល, ការធ្វើផែនការនីយកម្មនៃការវិនិយោគសាធារណៈ និងការធ្វើសមាហរណកម្មថវិកាវិនិយោគសាធារណៈពីប្រភពថវិកាជាតិ និងថវិកាដៃគូអភិវឌ្ឍន៍ ព្រមទាំងរវាងថវិកាចរន្ត ជាមួយថវិកាមូលធន តាមបរិការណ៍ជាក់ស្តែងរបស់កម្ពុជា,

៣)- ពង្រឹងការធ្វើសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជាមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ដែលមានលក្ខណៈសមាហរណកម្ម ស្របតាមទិសដៅនៃយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩ - ២០២៥, និងលើកកម្ពស់ប្រសិទ្ធភាពនៃទំនាក់ទំនងប្រទាក់ក្រឡា និងបំពេញឱ្យគ្នា ដោយការតម្រឹមកម្មវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ទៅនឹងកម្មវិធីរបស់រដ្ឋបាលថ្នាក់ជាតិ (មន្ទីរជំនាញរាជធានី ខេត្ត),

៤)- ពង្រឹងគុណភាព ប្រសិទ្ធភាពអនុវត្ត និងភាពផ្សារភ្ជាប់រវាងផែនការវិនិយោគសាធារណៈ ជាមួយនឹងថវិកានីយកម្មការវិនិយោគសាធារណៈ,

៥)- បង្កើត និង/ឬ ពង្រឹងយន្តការស្ថាប័ន សម្រាប់គ្រប់គ្រងការវិនិយោគសាធារណៈ ជាពិសេស ដំណាក់កាលអាទិភាវូបនីយកម្ម និងផែនការនីយកម្ម, សិក្សាវាយតម្លៃ និងរៀបចំសំណើគម្រោង, ពិនិត្យវាយតម្លៃលើសំណើគម្រោង, ជ្រើសរើសគម្រោង និងថវិកានីយកម្មគម្រោងវិនិយោគសាធារណៈ, តាមដាន និងត្រួតពិនិត្យការអនុវត្តគម្រោង, និងវាយតម្លៃក្រោយបញ្ចប់ការអនុវត្តគម្រោង, និង

៦)- រៀបចំឯកសារណែនាំស្តីពីគោលការណ៍ និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការគម្រោងវិនិយោគសាធារណៈសម្រាប់គ្រប់ដំណាក់កាលនៃវដ្តគម្រោង។

# ក្របខ័ណ្ឌ
# នៃការគ្រប់គ្រងវិនិយោគសាធារណៈ៖
# បទពិសោធន៍អន្តរជាតិ និងបរិការណ៍
# កម្ពុជា

# ៤. ក្របខ័ណ្ឌនៃការគ្រប់គ្រងវិនិយោគសាធារណៈ÷ បទពិសោធន៍អន្តរជាតិ និងបរិការណ៍កម្ពុជា

ការវិនិយោគសាធារណៈ សំដៅដល់ការចំណាយលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ត្រូវបានចែកចេញជា ២ ប្រភេទគឺ÷ ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច ដូចជាផ្លូវថ្នល់, ស្ពាន, អាកាសយានដ្ឋាន, កំពង់ផែ ជាដើម និងហេដ្ឋារចនាសម្ព័ន្ធសង្គម ដូចជាសាលារៀន និងមន្ទីរពេទ្យ ជាដើម។ ការវិនិយោគសាធារណៈ អាចត្រូវបានហិរញ្ញប្បទានដោយ ១)- ថវិការបស់រដ្ឋាភិបាល ដែលបានមកពីថវិការដ្ឋ និងការខ្ចីពីក្នុងនិងក្រៅប្រទេស, និង ២)- ទុនវិនិយោគពីវិស័យឯកជន។ ការវិនិយោគសាធារណៈ ត្រូវបានហិរញ្ញប្បទានដោយថវិកាមូលធន ក្នុងដំណាក់កាលសាងសង់ និងហិរញ្ញប្បទានដោយថវិកាចរន្ត ក្នុងដំណាក់កាលប្រតិបត្តិការ និងថែទាំ។

ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ សំដៅដល់ប្រព័ន្ធគ្រប់គ្រងចំណាយលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ប្រកបដោយភាពប្រទាក់ក្រឡាគ្នា និងបំពេញឱ្យគ្នាទៅវិញទៅមក រវាង÷

- ១)- "**ការគ្រប់គ្រងផែនការវិនិយោគសាធារណៈ**" ដើម្បីឆ្លើយតបនឹងតម្រូវការអាទិភាព សម្រាប់ការអភិវឌ្ឍជាតិរយៈពេលមធ្យម,
- ២)- "**ការគ្រប់គ្រងថវិកា**" ដើម្បីធានាឱ្យការវិភាជថវិកាវិនិយោគ ត្រូវបានធ្វើឡើងដោយឆ្លើយតប និងអនុលោមតាមក្របខ័ណ្ឌថវិការយៈពេលមធ្យម និងត្រូវបានគិតគូរជាមួយនឹងការរៀបចំថវិកាចរន្តសម្រាប់ចំណាយប្រតិបត្តិការ និងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ, និង
- ៣)- "**ការគ្រប់គ្រងគម្រោងវិនិយោគនៅគ្រប់ដំណាក់កាលនៃវដ្តគម្រោង**" ដើម្បីធានាប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, និងចីរភាព នៃហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។

## ៤.១. បទពិសោធន៍អន្តរជាតិ

តាមការអនុវត្តជាសកល, វដ្តនៃគម្រោងវិនិយោគសាធារណៈ ត្រូវបានបែងចែកជា ៨ ដំណាក់កាល រួមមាន÷ ១)- ការធ្វើអត្តសញ្ញាណកម្ម និងរៀបចំសំណើគម្រោងបឋម, ២)- ការសិក្សាសមិទ្ធិលទ្ធភាព, វាយតម្លៃ និងរៀបចំសំណើគម្រោងផ្លូវការ, ៣)- ការពិនិត្យ និងវាយតម្លៃលើសំណើគម្រោង, ៤)- ការជ្រើសរើសសំណើគម្រោង និងថវិកានីយកម្ម, ៥)- ការគ្រប់គ្រង និងអនុវត្តគម្រោង, ៦)- ការកែសម្រួលគម្រោង, ៧)- ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាងសង់ក្រោមក្របខ័ណ្ឌគម្រោង, និង ៨)- ការវាយតម្លៃបញ្ចប់ការអនុវត្តគម្រោង។ ទន្ទឹមនេះ, ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ត្រូវមានសមាសធាតុជាសារវន្តចំនួន ៦ រួមមាន÷ ក្របខ័ណ្ឌគោលនយោបាយ, ក្របខ័ណ្ឌគតិយុត្ត, យន្តការស្ថាប័ន, គោលការណ៍ និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការ, យន្តការគាំទ្រហិរញ្ញវត្ថុ, និងសមត្ថភាពធនធានមនុស្ស និងស្ថាប័ន។

ការរៀនសូត្រដកពិសោធន៍ និងវិភាគលើបរិការណ៍សកល នឹងផ្តល់ជាមូលដ្ឋានសម្រាប់ការគិតគូរ និងរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរួមមួយរបស់កម្ពុជា។ ក្នុងន័យនេះ, ផ្នែកបទពិសោធន៍ជាអន្តរជាតិនឹងផ្តោតជាសំខាន់លើ÷ ១)- ក្របខ័ណ្ឌគ្រប់គ្រងការវិនិយោគសាធារណៈ ២)- ដំណាក់កាលនៃវដ្តគម្រោង

វិនិយោគសាធារណៈ និង ៣)- និន្នាការសកល ដោយឆ្លុះបញ្ចាំងអំពីបទពិសោធនៃការអនុវត្ត និងការគ្រប់គ្រងការវិនិយោគសាធារណៈនៅក្នុងប្រទេសមួយចំនួន។

### ៤.១.១. ក្របខ័ណ្ឌគ្រប់គ្រងការវិនិយោគសាធារណៈ

ជាសត្យានុម័ត, ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ និងបណ្ដាប្រទេសជាច្រើនលើពិភពលោកបានអនុវត្ត និងទទួលស្គាល់ថា ដើម្បីកសាងឱ្យបាននូវប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ដែលមានភាពពេញលេញ, គ្រប់ជ្រុងជ្រោយ និងមានប្រសិទ្ធភាពនៅក្នុងប្រទេសមួយ ចាំបាច់ត្រូវបង្កើតឡើងដោយសមាសធាតុគន្លឹះ ជាអាទិ៍÷

- *ក្របខ័ណ្ឌគោលនយោបាយ និងក្របខ័ណ្ឌគតិយុត្ត÷*

ក្របខ័ណ្ឌគោលនយោបាយ គឺជាឯកសារគោលនយោបាយជាតិ ដែលដាក់ចេញនូវចក្ខុវិស័យ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលមធ្យម និង/ឬ វែងរបស់រដ្ឋាភិបាល ដោយបានកំណត់នូវ÷ គោលដៅគោល-នយោបាយ, វិស័យអាទិភាពសំខាន់ៗ, និងតម្រូវការវិនិយោគសាធារណៈសរុប។ ក្របខ័ណ្ឌគោលនយោបាយ គឺជាមូលដ្ឋានសម្រាប់រៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ, ក្របខ័ណ្ឌថវិកា, និងផែនការ ឬកម្មវិធីវិនិយោគសាធារណៈរយៈពេលមធ្យមរបស់ប្រទេស។ ក្របខ័ណ្ឌគោលនយោបាយត្រូវបានរៀបចំឡើង ដើម្បីតម្រង់ទិសយុទ្ធសាស្ត្រ និងសកម្មភាពតាមវិស័យនៃក្រសួង-ស្ថាប័នរបស់រដ្ឋាភិបាល សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃទំនាក់ទំនងប្រទាក់ក្រឡា និងបំពេញឱ្យគ្នានៃការវិនិយោគសាធារណៈតាមវិស័យ ដើម្បីសម្រេចគោលបំណងរួមរបស់រដ្ឋាភិបាល ព្រមទាំងផ្ដល់នូវភាពអាចប៉ាន់ប្រមាណបាននៃតម្រូវការទុន និងលទ្ធភាពធនធានវិនិយោគសាធារណៈ ដែលត្រូវមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការរៀបចំ និងគ្រប់គ្រងការអនុវត្តគម្រោងវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន។

ក្របខ័ណ្ឌគតិយុត្ត ត្រូវបានបញ្ញត្តនូវវិធានជាសារវន្តសម្រាប់ការគ្រប់គ្រង និងអនុវត្តគម្រោងវិនិយោគសាធារណៈ ដោយកំណត់នូវយន្តការស្ថាប័ន, នីតិវិធីគ្រប់គ្រងប្រតិបត្តិការ, និងគោលការណ៍ណែនាំលម្អិត សម្រាប់ធានាបាននូវប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាពនៃការបែងចែក និងប្រើប្រាស់ធនធានសាធារណៈក្នុងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ។ ប្រទេសមួយចំនួនបានអនុម័ត និងដាក់ឱ្យប្រើជាច្បាប់ស្ដីពីការវិនិយោគសាធារណៈតែម្ដង ប៉ុន្តែក៏មានប្រទេសមួយចំនួនទៀតដាក់ឱ្យប្រើត្រឹមកម្រិតលិខិតបទដ្ឋានគតិយុត្ត ដែលមានឋានានុក្រមទាបជាងច្បាប់ ដើម្បីរក្សាបាននូវភាពទន់ភ្លន់ បត់បែន និងសមស្របទៅនឹងបរិការណ៍ជាក់ស្ដែងនៃការអនុវត្តគម្រោងវិនិយោគសាធារណៈនៅក្នុងប្រទេសរៀងៗខ្លួន។

- *យន្តការស្ថាប័ន÷*

តួនាទី និងភារកិច្ចរបស់ក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនឹងវដ្ដរបស់គម្រោង គិតចាប់ពីដំណាក់កាលធ្វើអត្តសញ្ញាណកម្មគម្រោង រហូតដល់ដំណាក់កាលវាយតម្លៃបញ្ចប់គម្រោង ចាំបាច់ត្រូវកំណត់ និងបែងចែកឱ្យបានច្បាស់លាស់រវាងមុខងារធំៗចំនួន ៧ ដែលរួមមាន÷

១)- មុខងារធ្វើអត្តសញ្ញាណកម្ម, រៀបចំ, និងគ្រប់គ្រងការអនុវត្តគម្រោង÷ ជាទូទៅជាសមត្ថកិច្ចរបស់ក្រសួង-ស្ថាប័នជំនាញតាមវិស័យ ក្នុងការកំណត់អត្តសញ្ញាណគម្រោងដែលត្រូវវិនិយោគ និងរៀបចំគម្រោងឱ្យឆ្លើយតបនឹងក្របខ័ណ្ឌគោលនយោបាយ, គោលបំណងរួមនៃផែនការអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ។ ការធ្វើអត្តសញ្ញាណកម្ម និងរៀបចំគម្រោង ត្រូវធ្វើ

ឡើងដោយផ្អែកតាម «**គោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណកម្ម និងរៀបចំគម្រោង**» ដែលត្រូវបានដាក់ឱ្យអនុវត្តដោយរដ្ឋាភិបាល,

២)- មុខងាររៀបចំបញ្ជីគម្រោងអាទិភាព៖ ជាទូទៅជាសមត្ថកិច្ចរបស់ក្រសួង-ស្ថាប័ន ដែលទទួលបន្ទុកលើកិច្ចការរៀបចំផែនការសេដ្ឋកិច្ច និង/ឬវិនិយោគ ដោយត្រូវដឹកនាំការសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងការដាក់បញ្ចូលគម្រោងវិនិយោគសាធារណៈ ដែលមានសក្តានុពលទៅក្នុងបញ្ជីគម្រោងអាទិភាពរបស់រដ្ឋាភិបាល,

៣)- មុខងារពិនិត្យ និងអនុម័តលើបញ្ជីគម្រោងអាទិភាព៖ ជាសមត្ថកិច្ចរបស់ប្រមុខរដ្ឋាភិបាល ដែលជាទូទៅត្រូវប្រើប្រាស់យន្តការកិច្ចប្រជុំរបស់គណៈរដ្ឋមន្ត្រី,

៤)- មុខងារពិនិត្យ និងវាយតម្លៃលើសំណើគម្រោង៖ ជាទូទៅជាសមត្ថកិច្ចរបស់ក្រសួងហិរញ្ញវត្ថុ ក្នុងការពិនិត្យមើលឡើងវិញ ដើម្បីធានាអនុលោមភាពនៃសំណើគម្រោងទៅនឹង«**គោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណកម្ម និងរៀបចំគម្រោង**», ការពិនិត្យលើថ្លៃ និងហានិភ័យគម្រោង, យន្តការគ្រប់គ្រង និងអនុវត្តគម្រោង ព្រមទាំងកំណត់នូវវិធានការចាំបាច់នានា ដើម្បីកែតម្រូវនិងគ្រប់គ្រងហានិភ័យគម្រោង,

៥)- មុខងារជ្រើសរើសគម្រោង និងថវិកានីយកម្ម៖ ជាទូទៅជាសមត្ថកិច្ចរបស់ក្រសួងហិរញ្ញវត្ថុ ក្នុងការជ្រើសរើសគម្រោងពីបញ្ជីគម្រោងអាទិភាព ដើម្បីធ្វើថវិកានីយកម្ម ក្នុងគោលដៅធានានូវភាពឆ្លើយតបនឹងតម្រូវការជាអាទិភាព, ប្រសិទ្ធភាពសេដ្ឋកិច្ច, សមធម៌សង្គម, លទ្ធភាពនៃថវិកា, ភាពរួចរាល់នៃការចាប់ផ្តើមអនុវត្ត, និងភាពដែលអាចអនុវត្តបាន,

៦)- មុខងារតាមដាន និងត្រួតពិនិត្យការអនុវត្តគម្រោង៖ ជាទូទៅជាសមត្ថកិច្ចរបស់ក្រសួងហិរញ្ញវត្ថុ ក្នុងការតាមដានត្រួតពិនិត្យលើការគ្រប់គ្រងនិងអនុវត្តគម្រោង និងវាយតម្លៃអនុលោមភាព តាមវិធាន, គោលការណ៍, និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការ ក្នុងគោលដៅធានានូវប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាព នៃការប្រើប្រាស់ធនធានសាធារណៈ,

៧)- មុខងារវាយតម្លៃក្រោយបញ្ចប់គម្រោង៖ ជាទូទៅជាសមត្ថកិច្ចរបស់ក្រសួង-ស្ថាប័នគ្រប់គ្រងការអនុវត្តគម្រោង ឬភាគីទី៣ ដែលជាស្ថាប័នឯករាជ្យ ក្នុងគោលដៅដកស្រង់មេរៀន និងបទពិសោធន៍ ព្រមទាំងផ្តល់នូវអនុសាសន៍សំខាន់ៗ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការរៀបចំ និងការអនុវត្តគម្រោងវិនិយោគសាធារណៈ នាពេលអនាគត។

- ***យន្តការគាំទ្រហិរញ្ញវត្ថុ៖***

យន្តការគាំទ្រហិរញ្ញវត្ថុនៃការវិនិយោគសាធារណៈ មានគោលបំណងផ្តល់ការគាំទ្រហិរញ្ញវត្ថុដល់ក្រសួង-ស្ថាប័នជំនាញ ដែលអាចមានចាប់ពីដំណាក់កាលសិក្សាសមិទ្ធិលទ្ធភាព រហូតដល់ការប្រគល់កិច្ចសន្យា ប៉ុន្តែការរៀបចំយន្តការនេះអាស្រ័យលើសមត្ថភាពស្ថាប័ន, លទ្ធភាពនៃថវិកា, និងបរិការណ៍ជាក់ស្តែងរបស់ប្រទេសនីមួយៗ។ ប្រទេសមួយចំនួន ជាពិសេស ប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿន អាចមានលទ្ធភាពវិភាជថវិកាជូនក្រសួង-ស្ថាប័នជំនាញ ឬរៀបចំឱ្យមានស្ថាប័នជំនាញមួយផ្សេងតែម្តង ក្នុងការសិក្សាសមិទ្ធិលទ្ធភាពគម្រោងវិនិយោគ

សាធារណៈ ជាពិសេស សម្រាប់គម្រោងដែលមានទុនវិនិយោគធំ និងមានភាពស្មុគស្មាញ។ ដោយឡែក, ចំពោះប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន ពុំទាន់មានលទ្ធភាពផ្តល់ហិរញ្ញប្បទានគ្រប់គ្រាន់ជូនក្រសួង-ស្ថាប័នជំនាញ ធ្វើការសិក្សា និងរៀបចំគម្រោងបានពេញលេញនៅឡើយទេ។

### ៤.១.២. ដំណាក់កាលនៃវដ្តគម្រោងវិនិយោគសាធារណៈ

ប្រទេសមួយចំនួនបានអនុវត្តការបែងចែកដំណាក់កាលនៃវដ្តគម្រោងជា ៦ ឬ ៨ ដំណាក់កាល ដោយអាស្រ័យទៅនឹងបរិការណ៍នៃនីតិវិធីគ្រប់គ្រងគម្រោងវិនិយោគសាធារណៈនៅក្នុងប្រទេសរបស់ខ្លួន។ ដោយឡែក, ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ បានពិនិត្យឃើញថា ប្រទេសដែលមានប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរឹងមាំ ឬជឿនលឿន ជាទូទៅបានបែងចែកវដ្តគម្រោងជា ៨ ដំណាក់កាល ដូចខាងក្រោម៖

*ដំណាក់កាលទី១ - ការធ្វើអត្តសញ្ញាណកម្ម និងការរៀបចំសំណើគម្រោងបឋម៖* ក្រសួង-ស្ថាប័នជំនាញ ត្រូវកំណត់អត្តសញ្ញាណគម្រោង, រៀបចំសំណើគម្រោងបឋម ឬឯកសារទស្សនាទានគម្រោង ដោយពិនិត្យពីទំនាក់ទំនងទៅនឹងអាទិភាពគោលនយោបាយជាតិ, គោលនយោបាយតាមវិស័យ, ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម, និងក្របខ័ណ្ឌថវិការយៈពេលមធ្យមជាដើម។ ការធ្វើអត្តសញ្ញាណកម្ម និងរៀបចំគម្រោង ត្រូវធ្វើឡើងដោយផ្អែកលើ "**ឯកសារណែនាំស្តីពីការកំណត់អត្តសញ្ញាណកម្ម និងរៀបចំគម្រោង**" ដែលត្រូវដាក់ឱ្យអនុវត្តដោយរដ្ឋាភិបាល។ គោលបំណងសំខាន់នៃឯកសារណែនាំជាយុទ្ធសាស្ត្រនេះ គឺដើម្បីបន្សុី និងតម្រឹមសំណើគម្រោងជាក់លាក់នីមួយៗទៅតាមគោលបំណង និងគោលដៅរួមនៃផែនការអភិវឌ្ឍន៍ជាតិ និងគោលនយោបាយ ឬយុទ្ធសាស្ត្រតាមវិស័យ តាមរយៈការកំណត់ច្បាស់លាស់នូវគោលបំណង, គោលដៅ, លទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយជាមួយនឹងកាលវេលានៃបង្គោលចរច្បាស់លាស់។

បន្ទាប់ពីនេះ, ក្រសួងផែនការ ឬក្រសួង-ស្ថាប័នមានសមត្ថកិច្ចដែលទទួលបន្ទុកលើកិច្ចការរៀបចំផែនការសេដ្ឋកិច្ច និង/ឬវិនិយោគ នឹងសម្របសម្រួលធ្វើអាទិភាវូបនីយកម្មសំណើគម្រោងវិនិយោគ ដែលទទួលបានពីក្រសួង-ស្ថាប័នជំនាញ ដាក់បញ្ចូលទៅក្នុងផែនការ ឬកម្មវិធីវិនិយោគសាធារណៈ។

*ដំណាក់កាលទី២ - ការសិក្សាសមិទ្ធិលទ្ធភាព, វាយតម្លៃ និងរៀបចំសំណើគម្រោងផ្លូវការ៖* ជាដំណាក់កាលដែលក្រសួង-ស្ថាប័នជំនាញ ត្រូវធ្វើការសិក្សាសមិទ្ធិលទ្ធភាព និងវាយតម្លៃគម្រោងលើទិដ្ឋភាពពាក់ព័ន្ធ រួមមាន៖ បច្ចេកទេស, តម្លៃ, ហានិភ័យ, សេដ្ឋកិច្ច, ហិរញ្ញវត្ថុ, ច្បាប់, ផលប៉ះពាល់សង្គមនិងបរិស្ថាន, យន្តការស្ថាប័នគ្រប់គ្រង និងអនុវត្តគម្រោងជាដើម ដោយត្រូវគោរពគោលការណ៍ណែនាំលម្អិត និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការជាធរមាន, ព្រមទាំងរៀបចំជាសំណើគម្រោងផ្លូវការ ដើម្បីដាក់សុំការអនុម័តពីស្ថាប័នមានសមត្ថកិច្ច។

*ដំណាក់កាលទី៣ - ការពិនិត្យ និងវាយតម្លៃលើសំណើគម្រោង៖* ជាដំណាក់កាលដែលត្រូវពិនិត្យផ្ទៀងផ្ទាត់ឡើងវិញលើការវាយតម្លៃសំណើគម្រោង ដោយស្ថាប័នមានសមត្ថកិច្ចផ្សេងដាច់ពីក្រសួង-ស្ថាប័នម្ចាស់សំណើគម្រោង។ ជាទូទៅ តួនាទីនៃការពិនិត្យឡើងវិញលើការវាយតម្លៃសំណើគម្រោង គឺជាសមត្ថកិច្ចរបស់ក្រសួងហិរញ្ញវត្ថុ ឬនៅប្រទេសមួយចំនួនទៀត រដ្ឋាភិបាលបង្កើតស្ថាប័នឯករាជ្យ ដើម្បីត្រួតពិនិត្យ និងផ្តល់យោបល់លើសំណើគម្រោងរបស់ក្រសួង-ស្ថាប័នម្ចាស់សំណើគម្រោង។

*ដំណាក់កាលទី៤ - ការជ្រើសរើសសំណើគម្រោង និងថវិកានីយកម្ម៖* ជាដំណាក់កាលដែលក្រសួងហិរញ្ញវត្ថុត្រូវជ្រើសរើសគម្រោងពីបញ្ជីគម្រោងអាទិភាពដែលបានឆ្លងកាត់ដំណាក់កាលទី៣ ដើម្បីកំណត់ប្រភពហិរញ្ញប្បទាន និងធ្វើថវិកានីយកម្ម ក្នុងគោលដៅធានាប្រសិទ្ធភាពសេដ្ឋកិច្ច, សមធម៌សង្គម, និងលទ្ធភាពនៃថវិកា ក្នុងដំណាក់កាលវិនិយោគ និងប្រតិបត្តិការ។ មានតែគម្រោងដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អនុលោមតាមលក្ខណៈវិនិច្ឆ័យ និងវិធានជាធរមានប៉ុណ្ណោះ នឹងត្រូវបានជ្រើសរើសចេញពីបញ្ជីគម្រោងអាទិភាព សម្រាប់ការធ្វើថវិកានីយកម្ម។ ប្រទេសមួយចំនួនបានប្រកាន់យកគោលការណ៍រៀបចំកញ្ចប់ថវិកាវិនិយោគសាធារណៈរយៈពេលមធ្យម ដើម្បីធានាការចំណាយ និងការវិភាជន៍ធនធានដល់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធពហុឆ្នាំតែម្តង និងលើសពីនេះក៏មានប្រទេសមួយចំនួនទៀត បានគិតគូរពេញលេញរហូតដល់ដំណាក់កាលថែទាំហេដ្ឋារចនាសម្ព័ន្ធផងដែរ។

*ដំណាក់កាលទី៥ - ការគ្រប់គ្រង និងការអនុវត្តគម្រោង៖* ក្រសួង-ស្ថាប័នជំនាញ ដែលជាម្ចាស់គម្រោង សហការជាមួយក្រសួងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ចាប់ផ្តើមអនុវត្តកិច្ចលទ្ធកម្ម រាប់ទាំងការរៀបចំផែនការ, ការអនុវត្តនីតិវិធីលទ្ធកម្ម និងការគ្រប់គ្រងកិច្ចសន្យា។ ចំពោះករណីគម្រោងវិនិយោគដែលមានទំហំមធ្យម, ធំ, ឬមានលក្ខណៈស្មុគស្មាញ តម្រូវឱ្យមានការរៀបចំក្នុងក្របខ័ណ្ឌនៃកញ្ចប់ថវិកាពហុឆ្នាំ, រចនាសម្ព័ន្ធគ្រប់គ្រង, និងរយៈពេលអនុវត្តច្បាស់លាស់ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគម្រោង និងជៀសវាង ឬកាត់បន្ថយហានិភ័យពាក់ព័ន្ធដែលអាចនឹងកើតឡើង ជាពិសេស ក្នុងដំណាក់កាលនៃការអនុវត្តកិច្ចលទ្ធកម្ម។

*ដំណាក់កាលទី៦ - ការកែសម្រួលគម្រោង៖* ក្រសួង-ស្ថាប័នជំនាញ និងក្រសួងហិរញ្ញវត្ថុ ឬក្រសួង-ស្ថាប័នមានសមត្ថកិច្ច មានភារកិច្ចតាមដានការអនុវត្តគម្រោង ដោយផ្ទៀងផ្ទាត់វឌ្ឍនភាពនៃការអនុវត្តគម្រោងទៅនឹងផែនការអនុវត្តគម្រោងដែលបានអនុម័តរួច ហើយក្នុងករណីចាំបាច់ អាចឈានទៅដល់ការកែសម្រួលគម្រោង ដូចជាការពន្យារពេល ឬការចំណាយលើសផែនការជាដើម។ ក្នុងករណីដែលមានការចំណាយខ្ពស់លើសពីដានកំណត់, ក្រសួងហិរញ្ញវត្ថុ ឬក្រសួង-ស្ថាប័នមានសមត្ថកិច្ច មានសិទ្ធិស្នើឱ្យក្រសួង-ស្ថាប័នជំនាញពិនិត្យលទ្ធភាពវាយតម្លៃគម្រោងឡើងវិញ ដើម្បីកែសម្រួលសមាសភាគ/សកម្មភាព ឬវិសាលភាពនៃគម្រោង ឬបញ្ឈប់ការផ្តល់ហិរញ្ញប្បទានលើគម្រោងតែម្តង។ ក្នុងករណីចាំបាច់, អាចរៀបចំគម្រោងបន្ថែមថ្មី ដើម្បីអនុវត្តបញ្ចប់ និងសម្រេចតាមគោលដៅគម្រោង។

*ដំណាក់កាលទី៧ - ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាងសង់ក្រោមគម្រោង៖* ក្រសួង-ស្ថាប័នជំនាញ មានភារកិច្ចត្រួតពិនិត្យ និងវាយតម្លៃបញ្ចប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដើម្បីអនុវត្តការប្រគល់-ទទួល និងចុះបញ្ជីជាទ្រព្យសម្បត្តិរដ្ឋស្របតាមនីតិវិធីជាធរមាន។ ទន្ទឹមនេះ ត្រូវកំណត់ដែនសមត្ថកិច្ចគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ និងគ្រោងឥណទានថវិការបស់ក្រសួង-ស្ថាប័នជំនាញ សម្រាប់ធានាដល់ប្រតិបត្តិការ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធក្នុងដំណាក់កាលប្រើប្រាស់ និងផ្តល់សេវាសាធារណៈ។

*ដំណាក់កាលទី៨ - ការវាយតម្លៃបញ្ចប់ការអនុវត្តគម្រោង៖* ក្រសួង-ស្ថាប័នគ្រប់គ្រងការអនុវត្តគម្រោង ឬភាគីទី៣ ដែលជាស្ថាប័នមានសមត្ថកិច្ចផ្សេងពីក្រសួង-ស្ថាប័នម្ចាស់គម្រោង ត្រូវប្រមូលទិន្នន័យនៃការចំណាយសរុប, លទ្ធផលសម្រេចបាន និងក្របខ័ណ្ឌពេលវេលា ធៀបនឹងផែនការដើម, លទ្ធផលរំពឹងទុក, និងគោលដៅ

របស់គម្រោង។ ជាទូទៅ ការវាយតម្លៃបញ្ចប់គម្រោងត្រូវធ្វើឡើងភ្លាមបន្ទាប់ពីបានបញ្ចប់ការអនុវត្តគម្រោង ឬនៅក្នុងរយៈពេលមិនលើសពី ពីរ ឬបីឆ្នាំ បន្ទាប់ពីគម្រោងត្រូវបានបញ្ចប់ ដើម្បីរៀបចំចងក្រងជារបាយការណ៍ស្ដីពីលទ្ធផលសម្រេចបាន ទាំងលទ្ធផលសម្រេចបានក្នុងរយៈពេលអនុវត្តគម្រោង និងទាំងលទ្ធផលចុងក្រោយ ព្រមទាំងបញ្ហាប្រឈមនៃការអនុវត្តគម្រោង សម្រាប់ជាបទពិសោធន៍ក្នុងការរៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈក្រោយៗទៀត។

**ដំណាក់កាលនៃវដ្ដគម្រោងវិនិយោគសាធារណៈ**




ប្រភព÷ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ

តាមការវាយតម្លៃរបស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ លើកម្រិតសមត្ថភាពនៃប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ, ជាទូទៅ មានក្រុមប្រទេសចំនួន ២ ធំៗ ដូចខាងក្រោម÷

*១)- ក្រុមប្រទេសដែលមានប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរឹងមាំ ឬជឿនលឿន÷* ដែលជារួមដោយសារមានកត្តាកំណត់ដ៏រឹងមាំ ជាអាទិ៍ដូចខាងក្រោម÷

- ឯកសារក្របខ័ណ្ឌគោលនយោបាយគ្រប់គ្រាន់ និងគ្រប់ជ្រុងជ្រោយ ដែលផ្ដល់ជាមូលដ្ឋានក្នុងការរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ, ក្របខ័ណ្ឌថវិកា, និងផែនការ ឬកម្មវិធីវិនិយោគសាធារណៈរយៈពេលមធ្យម,
- ក្របខ័ណ្ឌគតិយុត្ត, នីតិវិធីគ្រប់គ្រងប្រតិបត្តិការ, យន្តការស្ថាប័ន, និងសមត្ថភាពធនធានមនុស្ស ដើម្បីគាំទ្រដល់ការរៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈ,
- យន្តការគាំទ្រហិរញ្ញវត្ថុ សម្រាប់គាំទ្រដល់ការសិក្សាសមិទ្ធិលទ្ធភាព និងការរៀបចំសំណើគម្រោងវិនិយោគសាធារណៈ,
- យន្តការ និងនីតិវិធីត្រួតពិនិត្យលើការវាយតម្លៃសំណើគម្រោងដោយឯករាជ្យ,
- រៀបចំកញ្ចប់ថវិកាពហុឆ្នាំ សម្រាប់ការអនុវត្តគម្រោង,
- ការយកចិត្តទុកដាក់លើការគ្រប់គ្រងចំណាយសរុប (វិនិយោគ ប្រតិបត្តិការ និងថែទាំ) និងមានការកំណត់តួនាទី និងភារកិច្ចនៃក្រសួង-ស្ថាប័ននីមួយៗ ដែលទទួលបន្ទុកក្នុងការអនុវត្តគម្រោងវិនិយោគសាធារណៈ,
- យន្តការ និងនីតិវិធីច្បាស់លាស់ក្នុងការពិនិត្យនិងកែសម្រួលគម្រោងឡើងវិញ,

- នីតិវិធីច្បាស់លាស់ក្នុងការកត់ត្រាចុះបញ្ជីជាទ្រព្យសម្បត្តិរដ្ឋ និងយន្តការគ្រប់គ្រង ប្រើប្រាស់ និងថែទាំហេដ្ឋារចនាសម្ព័ន្ធបានច្បាស់លាស់,
- ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃបញ្ចប់គម្រោង, និង
- អង្គភាពថ្នាក់កណ្តាល ឬលេខាធិការដ្ឋានមួយទទួលបន្ទុកប្រមូលផ្តុំ និងគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈទាំងអស់ ដើម្បីតាមដានវឌ្ឍនភាព និងវាយតម្លៃប្រសិទ្ធភាពនៃការរៀបចំ និងអនុវត្តគម្រោង។

*២)- ក្រុមប្រទេសដែលមិនទាន់មានប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរឹងមាំ ឬស្ថិតក្នុងដំណាក់កាលនៃការពង្រឹងបន្ថែម និងដំណាក់កាលនៃការកែទម្រង់៖* ជាទូទៅ នៅមានភាពខ្វះចន្លោះមួយចំនួន តាមដំណាក់កាលនីមួយៗ នៃវដ្តគម្រោង ដែលរួមមាន៖

- ការផ្សារភ្ជាប់ការធ្វើផែនការ ឬកម្មវិធីវិនិយោគសាធារណៈ ជាមួយនឹងក្របខ័ណ្ឌគោលនយោបាយ និងថវិកា,
- ក្របខ័ណ្ឌគតិយុត្ត, នីតិវិធីគ្រប់គ្រងប្រតិបត្តិការ, យន្តការស្ថាប័ន, និងសមត្ថភាពធនធានមនុស្ស ដើម្បីគាំទ្រដល់ការរៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈ,
- គុណភាពនៃការធ្វើអត្តសញ្ញាណកម្មគម្រោង ការរៀបចំគម្រោង និងការវាយតម្លៃសំណើគម្រោង,
- ប្រសិទ្ធភាព និងអនុលោមភាពនៃការអនុវត្តកិច្ចលទ្ធកម្ម និងគុណភាពនៃហេដ្ឋារចនាសម្ព័ន្ធ,
- ប្រសិទ្ធភាព និងចីរភាពនៃការគ្រប់គ្រង, ប្រើប្រាស់ និងថែទាំហេដ្ឋារចនាសម្ព័ន្ធ, និង
- កិច្ចសម្របសម្រួលអន្តរស្ថាប័ន ជាមួយនឹងភាគីពាក់ព័ន្ធសំខាន់ៗ ជាដើម។

### ៤.១.៣. និន្នាការសកល

បច្ចុប្បន្ន បទពិសោធនៃការអនុវត្តជាសកលខាងលើបានបង្ហាញថា ត្បិតមានក្រុមប្រទេសដែលមានប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរឹងមាំ ឬជឿនលឿនក្តី, តែក្រុមប្រទេសទាំងនោះក៏ពុំទាន់គោរពតាមនីតិវិធីដែលមានជាធរមានបានពេញលេញនៅឡើយ។ ដូច្នេះហើយ, ក្រុមប្រទេសទាំងនេះ នៅតែបន្តពង្រឹងកែលម្អ ឬកែសម្រួលសមាសធាតុពាក់ព័ន្ធនឹងប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរបស់ខ្លួន ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់មួយកម្រិតទៀត ស្របតាមបរិការណ៍ជាក់ស្តែងនៃប្រទេសរៀងៗខ្លួន។ ចំណែកឯបណ្តាប្រទេសដែលមិនទាន់មានប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរឹងមាំ ឬស្ថិតក្នុងដំណាក់កាលនៃការពង្រឹងបន្ថែម និងការកែទម្រង់, ការបង្កើត ឬការពង្រឹងប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរបស់ខ្លួន គឺដើម្បីបម្រើឱ្យគោលដៅចម្បងចំនួន ៣ រួមមាន៖ ១)- ការឆ្លើយតបទៅនឹងតម្រូវការហេដ្ឋារចនាសម្ព័ន្ធសាធារណៈ, ២)- ការគ្រប់គ្រងសម្ពាធនៃកំណើនបំណុលសាធារណៈ, និង ៣)- ការលើកកម្ពស់ប្រសិទ្ធភាព និងចីរភាពនៃការវិនិយោគសាធារណៈ សំដៅរួមចំណែកក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង។

ជាមួយគ្នានេះ, ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ជាច្រើន បាននិងកំពុងនាំមុខផ្តួចផ្តើមជ្រោមជ្រែងជួយប្រទេសសមាជិក ក្នុងការបង្កើត ឬពង្រឹងក្របខ័ណ្ឌរួម សម្រាប់គ្រប់គ្រងការវិនិយោគសាធារណៈបន្ថែមទៀត ដែលអាចផ្តល់នូវទិដ្ឋភាពគ្រប់ជ្រុងជ្រោយ, ប្រទាក់ក្រឡា, និងជាប្រព័ន្ធក្នុងដំណាក់កាលនីមួយៗនៃ

វដ្តគម្រោង សំដៅធានាបាននូវភាពឆ្លើយតប, ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព និងចីរភាពនៃការបែងចែក និងប្រើប្រាស់ធនធានសាធារណៈប្រកបដោយសមធម៌សង្គម។

ជារួម, ការបង្កើត ឬការពង្រឹងក្របខ័ណ្ឌរួម ដើម្បីគ្រប់គ្រងការវិនិយោគសាធារណៈ គឺតម្រូវឱ្យប្រទេសដែលមិនទាន់មានប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរឹងមាំ ចាប់ផ្តើមពីការកែលម្អ និងពង្រឹងក្របខ័ណ្ឌគោលនយោបាយ, ក្របខ័ណ្ឌគតិយុត្ត, នីតិវិធីគ្រប់គ្រងប្រតិបត្តិ, យន្តការស្ថាប័ន, សមត្ថភាពធនធានមនុស្ស, និងយន្តការគាំទ្រហិរញ្ញវត្ថុរបស់ខ្លួន ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ឈានទៅដល់កម្រិតនៃការអភិវឌ្ឍដូចប្រទេសដែលមានប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរឹងមាំ ឬជឿនលឿន។

## ៤.២. បរិការណ៍កម្ពុជា

### ៤.២.១. ក្របខ័ណ្ឌគោលនយោបាយ

សម្រាប់រយៈពេលជាង ២ ទសវត្សរ៍កន្លងមកនេះ ក្នុងការគ្រប់គ្រងការវិនិយោគសាធារណៈនៅកម្ពុជា, រាជរដ្ឋាភិបាល បានដាក់ចេញនូវយុទ្ធសាស្ត្រត្រីកោណ, បន្ទាប់មក យុទ្ធសាស្ត្រចតុកោណទាំងបួនដំណាក់កាល, ក៏ដូចជាគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធចាំបាច់នានា ជាពិសេស ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដែលជាត្រីវិស័យចង្អុលបង្ហាញអំពីតម្រូវការជាយុទ្ធសាស្ត្រនៃចំណាយវិនិយោគសាធារណៈ ដើម្បីជំរុញ និងទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ ក៏ដូចជាការអភិវឌ្ឍសង្គមជារួម។ ក្រោមក្របខ័ណ្ឌនេះ, មុខសញ្ញាចំណាយវិនិយោគសាធារណៈត្រូវបានផ្តល់អាទិភាពជាចម្បងលើការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលគាំទ្រដល់វិស័យសេដ្ឋកិច្ចដែលរួមមាន÷ ១)- ការបន្តស្តារ កសាង និងកែលម្អប្រព័ន្ធឡូជីស្ទីក និងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ (ផ្លូវគោក, ផ្លូវទឹក, និងផ្លូវអាកាស), ២)- ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ, ៣)- ការអភិវឌ្ឍវិស័យថាមពល, ៤)- ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានគមនាគមន៍ និងឌីជីថល, និង ៥)- ការរៀបចំខ្លួន សម្រាប់ប្រព័ន្ធសេដ្ឋកិច្ចឌីជីថល និងសម្រាប់ឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី៤ ។

ផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រ គោលនយោបាយ ក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, រាជរដ្ឋាភិបាលក៏បានដាក់ឱ្យអនុវត្តកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ដែលជាការប្រមូលផ្តុំ និងចងក្រងនូវគម្រោងវិនិយោគសាធារណៈ ដែលមានអាទិភាពខ្ពស់របស់ក្រសួង-ស្ថាប័ន ហើយធ្វើការរៀបចំកែសម្រួល និងរំកិលជារៀងរាល់ឆ្នាំទៅតាមអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ជារួម, កម្មវិធីវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល គួរជាឧបករណ៍គន្លឹះ សម្រាប់ការរៀបចំផែនការវិនិយោគសាធារណៈ ដើម្បីឆ្លើយតបនឹងទិសដៅនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ប៉ុន្តែជាក់ស្តែង កម្មវិធីវិនិយោគសាធារណៈនេះ នៅតែមិនទាន់អាចបំពេញមុខងារនេះបានប្រកបដោយប្រសិទ្ធភាពនៅឡើយ ដោយសារ÷

**១)- ផែនការវិនិយោគសាធារណៈ** មិនទាន់ឆ្លើយតប និងផ្សារភ្ជាប់ទៅនឹងគោលនយោយបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនៅឡើយ។ អាទិភាពដែលកំណត់ក្នុងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ មានលក្ខណៈជាគោលបំណងរួម និងទិសដៅជាយុទ្ធសាស្ត្រប៉ុណ្ណោះ គឺនៅមិនទាន់មានភាពច្បាស់លាស់គ្រប់គ្រាន់សម្រាប់ការធ្វើអត្តសញ្ញាណកម្មគម្រោង និងធ្វើផែនការគម្រោងវិនិយោគ ដែលមានចរិតជាផែនការអនុវត្ត

ជាក់ស្តែងបាននៅឡើយ។ ជាគោលការណ៍ គឺចាំបាច់ត្រូវមាន **«គោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណកម្ម និងរៀបចំគម្រោង»** ដែលត្រូវដាក់ឱ្យអនុវត្តដោយរាជរដ្ឋាភិបាល សម្រាប់ឱ្យក្រសួង-ស្ថាប័នអនុវត្តតាម។ គោល-បំណងសំខាន់នៃឯកសារណែនាំជាយុទ្ធសាស្ត្រនេះ គឺដើម្បីបន្សុី និងតម្រឹមសំណើគម្រោងជាក់លាក់នីមួយៗទៅតាមគោលបំណងរួមនៃផែនការអភិវឌ្ឍន៍ជាតិ តាមរយៈការកំណត់ច្បាស់លាស់នូវគោលបំណង, គោលដៅ, លទ្ធផលក្នុងឆ្នាំ, និងលទ្ធផលចុងក្រោយ ជាមួយនឹងកាលវេលានៃបង្គោលចរច្បាស់លាស់។ *បច្ចុប្បន្ន កម្ពុជាមិនទាន់មាន* **«គោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណកម្ម និងរៀបចំគម្រោង»** *ដែលមានភាពពេញលេញ និងគ្រប់ជ្រុងជ្រោយនៅឡើយ។ គោលការណ៍ណែនាំនេះ ជាមូលដ្ឋានគន្លឹះ សម្រាប់ធានានូវការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយប្រសិទ្ធភាព និងភាពឆ្លើយតបនៃគម្រោងវិនិយោគសាធារណៈ;*

**២)- បញ្ហាភាពគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡានៃផែនការវិនិយោគសាធារណៈ÷ បច្ចុប្បន្ន មានតែកម្មវិធីវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល** ដែលមានវិសាលភាពគ្របដណ្តប់តែលើគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានពីក្រៅប្រទេសប៉ុណ្ណោះ ដោយមិនអាចគ្របដណ្តប់លើគម្រោងវិនិយោគសាធារណៈពីប្រភពផ្សេងៗទៀត,

**៣)- ផែនការវិនិយោគសាធារណៈ** មិនទាន់ផ្សារភ្ជាប់គ្នាទៅនឹងថវិកានីយកម្មការវិនិយោគសាធារណៈនៅឡើយ, និង

**៤)- ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅរដ្ឋបាលថ្នាក់ក្រោមជាតិក៏នៅមិន**ទាន់ផ្សារភ្ជាប់ទៅនឹងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបាននៅឡើយ ដោយសារផែនការទាំងនេះ ត្រូវបានរៀបចំដាច់ដោយឡែករវាងថ្នាក់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ទោះបីជាមានយន្តការសម្របសម្រួលពិគ្រោះយោបល់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធ្វើសមាហរណកម្មផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក៏ដោយ ក៏ភាពខុសគ្នានៃពេលវេលា, វិធីសាស្ត្រ, និងអភិក្រម បានធ្វើឱ្យដំណើរការនៃការធ្វើសមាហរណកម្មបញ្ចូលគ្នានេះពិបាកនឹងសម្រេចបាន។

## ៤.២.២. ក្របខ័ណ្ឌគតិយុត្ត

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ បានបញ្ញត្តគោលការណ៍គ្រឹះនៃការគ្រប់គ្រង និងប្រើប្រាស់ថវិកាមូលធន និងឥណទានវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស សម្រាប់ការអនុវត្តគម្រោងវិនិយោគសាធារណៈទាំងកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ទោះបីជាយ៉ាងណា, អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តចាំបាច់មួយចំនួនដែលត្រូវរៀបចំក្រោមក្របខ័ណ្ឌនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដើម្បីកំណត់អំពីអភិក្រម គោល-ការណ៍ និងសមត្ថកិច្ចស្ថាប័ន ក្នុងការរៀបចំ គ្រប់គ្រង និងអនុវត្តថវិកាមូលធន និងការវិនិយោគសាធារណៈ នៅមិនទាន់ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តបានពេញលេញនៅឡើយ។

ក្រៅពីក្របខ័ណ្ឌច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, ច្បាប់ស្តីពីសម្បទានត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៧ ក្នុងគោលបំណងសម្រួលដល់ការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធដោយហិរញ្ញប្បទានឯកជន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីបម្រើផលប្រយោជន៍សាធារណៈ និងបំពេញសេចក្តីត្រូវការរបស់សង្គម និងសេដ្ឋកិច្ចជាតិ។ ច្បាប់នេះបានបញ្ជាក់ពីសម្បទានដែលត្រូវបានផ្តល់ឱ្យតាមរយៈកិច្ចសន្យាសម្បទាន ដែលមានទំនាក់ទំនង

ទៅនឹងការវិនិយោគហេដ្ឋារចនាសម្ព័ន្ធតាមរយៈការផ្គត់ផ្គង់សេវាដោយផ្ទាល់ ឬដោយប្រយោល ដើម្បីជាប្រយោជន៍សាធារណៈ។ កិច្ចសន្យាសម្បទាន ត្រូវបានចូលរួមរៀបចំ និងអនុវត្តដោយស្ថាប័នពាក់ព័ន្ធលើវិស័យដូចតទៅ÷

- ការផលិត ការបញ្ជូន និងការចែកចាយថាមពលអគ្គិសនី,
- ហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធដឹកជញ្ជូនមានជាអាទិ៍ ផ្លូវថ្នល់ ស្ពាន ព្រលានយន្តហោះ កំពង់ផែ ផ្លូវដែក ព្រែកជីក,
- ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ,
- ហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យទូរគមនាគមន៍ និងបច្ចេកវិទ្យាព័ត៌មាន,
- ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសម្ភារៈបម្រើឱ្យគម្រោងផ្នែកទេសចរណ៍មានជាអាទិ៍រមណីយដ្ឋាន ទេសចរណ៍ សារមន្ទីរ,
- ហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យវិស័យឧស្ម័ន និងប្រេងមានជាអាទិ៍ បំពង់បង្ហូរប្រេង និងឧស្ម័ន,
- ប្រព័ន្ធលូ ប្រព័ន្ធបង្ហូរទឹក និងប្រព័ន្ធបូមស្តារ,
- ប្រព្រឹត្តិកម្ម និងការគ្រប់គ្រងសំណល់,
- ហេដ្ឋារចនាសម្ព័ន្ធសាធារណៈពាក់ព័ន្ធនឹងវិស័យសុខាភិបាល វិស័យអប់រំ និងវិស័យកីឡា,
- ហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យតំបន់សេដ្ឋកិច្ចពិសេស និងលំនៅដ្ឋានសង្គម,
- ហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យប្រព័ន្ធធារាសាស្ត្រ និងការងារកសិកម្ម, និង
- វិស័យផ្សេងៗទៀត ដែលច្បាប់ដោយឡែកណាមួយអនុញ្ញាតឱ្យមានការផ្តល់នូវសម្បទាន។

ក្រៅពីនេះ អនុក្រឹត្យស្តីពីការគ្រប់គ្រងកម្មវិធីវិនិយោគសាធារណៈ ឆ្នាំ២០០០ ត្រូវបានបង្កើតឡើង ដើម្បីរៀបចំ និងអនុវត្ត តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគសាធារណៈ ដែលកម្មវិធីវិនិយោគនេះ គឺជាកម្មវិធីវិនិយោគរយៈពេលបីឆ្នាំរំកិល ដោយធ្វើការកែលម្អជារៀងរាល់ឆ្នាំ និងត្រូវកសាងឡើងតាមខ្លឹមសារ និងស្មារតីនៃសារាចរររវាងក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកសាងគម្រោងកម្មវិនិយោគសាធារណៈ ដោយមានការរួមយោបល់ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ អនុក្រឹត្យនេះ បានបញ្ញត្តបើកផ្លូវឱ្យក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចេញសារាចរអន្តរក្រសួង ដើម្បីណែនាំឱ្យក្រសួង-ស្ថាប័ននានារៀបចំគម្រោងកម្មវិធីវិនិយោគសាធារណៈតាមវិស័យដែលខ្លួនគ្រប់គ្រង និងតាមកាលកំណត់។

នៅរដ្ឋបាលថ្នាក់ក្រោមជាតិ អនុក្រឹត្យលេខ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពី **«ផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ»** បានកំណត់អំពីគោលការណ៍ យន្តការ និងនីតិវិធី សម្រាប់គ្រប់គ្រង និងអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ទោះជាយ៉ាងនេះក្តី, អនុក្រឹត្យនេះពុំបានបញ្ជាក់ឱ្យបានច្បាស់លាស់អំពីដំណើរការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ និងវដ្តនៃគម្រោងនៅឡើយ។ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរៀងរាល់មួយឆ្នាំម្តងរៀងៗខ្លួន ដោយផ្សារភ្ជាប់ជាមួយផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ដើម្បីដាក់ឱ្យក្រុមប្រឹក្សាសាមីពិនិត្យ និងអនុម័ត។

ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចបន្តសម្របសម្រួល ដើម្បីធានាបាននូវសុខដុមនីយកម្មការងារផែនការវិនិយោគសាធារណៈ និងគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ។

ជារួម ក្របខ័ណ្ឌគតិយុត្តស្តួលទាំងនេះ បាននូវមចំណែកយ៉ាងសំខាន់ក្នុងការជំរុញឱ្យមានចលនាវិនិយោគសាធារណៈស្ទើរគ្រប់វិស័យនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែនៅមានភាពចន្លោះប្រហោងច្រើននៅឡើយ ដែលការណ៍នេះទាមទារឱ្យមានការកែសម្រួល ឬត្រួតពិនិត្យឡើងវិញនូវច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងរៀបចំលិខិតបទដ្ឋានគតិយុត្តបំពេញបន្ថែម ដើម្បីគាំទ្រដល់ការគ្រប់គ្រងការវិនិយោគសាធារណៈនៅកម្ពុជាឱ្យមានប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព និងប្រកបដោយចីរភាពក្នុងដំណាក់កាលប្រតិបត្តិការ និងថែទាំ។

## ៤.២.៣. យន្តការស្ថាប័ន

នៅក្នុងក្របខ័ណ្ឌគម្រោងវិនិយោគសាធារណៈ ការសិក្សាបឋម (ឯកសារទស្សនាទានគម្រោង), ការសិក្សាសមិទ្ធិលទ្ធភាព, និងការរៀបចំគម្រោង ត្រូវទទួលបន្ទុកដោយក្រសួង-ស្ថាប័នសាមី ដែលជាម្ចាស់សំណើគម្រោង ហើយការរៀបចំនេះ នឹងក្លាយជាកម្មវត្ថុនៃការពិនិត្យ និងវាយតម្លៃរបស់ក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទៅតាមដំណាក់កាលផ្សេងៗគ្នា ដើម្បីស្នើសុំការពិនិត្យ និងសម្រេចពីរាជរដ្ឋាភិបាល ដូចខាងក្រោម÷

- *ដំណាក់កាលរៀបចំផែនការតាមវិស័យ*

នៅក្នុងដំណាក់កាលនេះ ក្រសួងផែនការដឹកនាំរៀបចំផែនការស្តីពីការអភិវឌ្ឍរយៈពេលវែង មធ្យម និងខ្លី ដោយសម្របសម្រួលជាមួយបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ដោយធ្វើយ៉ាងណាឱ្យផែនការ និងកម្មវិធីជាតិទាំងនោះ មានភាពស្របគ្នារវាងបណ្តាផ្នែក និងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងរៀបចំយុទ្ធសាស្ត្រគោលនយោបាយ និងកំណត់អាទិភាពក្នុងការវិនិយោគទាំងឯកជន និងសាធារណៈ។ លទ្ធផលនៃការរៀបចំនេះ នឹងត្រូវបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ដើម្បីស្នើសុំការពិនិត្យ និងសម្រេចពីរាជរដ្ឋាភិបាល។

ការរៀបចំថវិកាប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ន គឺផ្អែកលើសារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល។ ផ្អែកលើសារាចរណែនាំនេះ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចេញសារាចរណែនាំមួយទៀត ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ រៀបចំថវិកាប្រចាំឆ្នាំរបស់ខ្លួន។

បច្ចុប្បន្ន ការរៀបចំផែនការវិនិយោគរយៈពេលមធ្យមនៃហិរញ្ញប្បទានដោយឥណទានសម្បទានពីដៃគូអភិវឌ្ឍន៍ ត្រូវបានអនុវត្តដោយឡែកៗតាមដៃគូអភិវឌ្ឍន៍។ ផែនការនេះត្រូវបានធ្វើសមាហរណកម្មចូលទៅក្នុងបញ្ជីគម្រោងវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល រួមជាមួយនឹងគម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានឥតសំណងពីដៃគូអភិវឌ្ឍន៍។ ដោយឡែក, ការរៀបចំផែនការគម្រោងវិនិយោគសាធារណៈ ហិរញ្ញប្បទានដោយថវិកាជាតិ និងតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន នៅមិនទាន់មានផែនការរយៈពេលមធ្យមនៅឡើយ ប៉ុន្តែបានអនុវត្តដោយផ្អែកតាមគោលការណ៍អាទិភាព ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល។

- *ដំណាក់កាលរៀបចំផែនការថវិកាកម្រិតយុទ្ធសាស្ត្រ*

បន្ទាប់ពីការរៀបចំផែនការតាមវិស័យ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដឹកនាំការរៀបចំក្របខ័ណ្ឌថវិកា ដោយផ្អែកលើក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនិងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល ដើម្បីផ្តល់ព័ត៌មានដល់ក្រសួង-ស្ថាប័ន អំពីលទ្ធភាព និងអាទិភាពចំណាយ និងសក្តានុពលចំណូលនៃឆ្នាំថវិកា និងពីរឆ្នាំទៅមុខ។ គ្រប់ក្រសួង-ស្ថាប័នទាំងថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិការយៈពេលមធ្យម។ ក្របខ័ណ្ឌ និងផែនការយុទ្ធសាស្ត្រថវិកា ត្រូវបានរៀបចំ និងធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំ ដោយបង្ហាញពីបុរេនិទស្សន៍រយៈពេលបីឆ្នាំរំកិលទៅមុខ។

ចំពោះគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយឥណទានសម្បទាន, ដៃគូអភិវឌ្ឍន៍នីមួយៗដោយសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងដោយមានការពិគ្រោះយោបល់ជាមួយក្រសួង-ស្ថាប័នជំនាញ, រៀបចំក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការភាពជាដៃគូរយៈពេលមធ្យម ដោយកំណត់អំពីកម្មវិធី/គម្រោង និងវិស័យអាទិភាពដែលដៃគូអភិវឌ្ឍន៍នីមួយៗនឹងរួមចំណែកជួយគាំទ្រដល់កិច្ចអភិវឌ្ឍរបស់រាជរដ្ឋាភិបាល។ ក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការភាពជាដៃគូនេះ ត្រូវបានរៀបចំដោយផ្អែកលើរបៀបវារៈអភិវឌ្ឍន៍របស់ដៃគូនីមួយៗ និងឆ្លើយតបតាមតម្រូវការអាទិភាពរបស់រាជរដ្ឋាភិបាល ដែលបានកំណត់ក្នុងកម្មវិធីវិនិយោគ ៣ ឆ្នាំរំកិល អនុលោមតាមយុទ្ធសាស្ត្រចតុកោណ, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ។

ទន្ទឹមនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក៏ចូលរួមរៀបចំ និងអនុវត្តយុទ្ធសាស្ត្រស្តីពីការកៀរគរ និងការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍, និងកៀរគរ និងវិភាជន៍ហិរញ្ញប្បទានឥតសំណង សម្រាប់អនុវត្តបណ្តាគោលដៅអាទិភាពដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការអភិវឌ្ឍន៍តាមវិស័យ, ព្រមទាំងសម្របសម្រួលកំណត់លំដាប់អាទិភាពនៃកម្មវិធី និងគម្រោងវិនិយោគក្នុងការទទួលហិរញ្ញប្បទានឥតសំណងពីដៃគូអភិវឌ្ឍន៍ សម្រាប់រយៈពេលមធ្យម និងរយៈពេលមួយឆ្នាំផងដែរ។

- *ដំណាក់កាលរៀបចំ និងអនុម័តថវិកា*

ដំណើរការនៃការរៀបចំ និងអនុម័តថវិកាប្រចាំឆ្នាំ ត្រូវបានអនុវត្តតាមប្រតិទិន ដែលបានដាក់ចេញដោយច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

ការរៀបចំកញ្ចប់ថវិការបស់ក្រសួង-ស្ថាប័ន រួមទាំងមន្ទីរជំនាញរាជធានី ខេត្ត គឺផ្អែកលើសារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល។ ចំណែកឯ ការរៀបចំថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺផ្អែកលើសារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្រសួង-ស្ថាប័ន រួមទាំងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ទាំងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ មានរយៈពេលជាងប្រាំមួយសប្តាហ៍ ក្នុងការរៀបចំថវិការបស់ខ្លួន។ ក្រោយពីទទួលបានការសម្រេចរបស់ប្រមុខរាជរដ្ឋាភិបាល សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ត្រូវបានបញ្ជូនទៅស្ថាប័ននីតិប្បញ្ញត្តិ ដើម្បីពិនិត្យ និងអនុម័ត។

ចំពោះការរៀបចំថវិកា សម្រាប់គម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ តំណាងស្របច្បាប់របស់រាជរដ្ឋាភិបាល ដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំកិច្ចប្រជុំចរចាលើកិច្ច

ព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីសុំការអនុម័តពីក្រុមប្រឹក្សានាយកប្រតិបត្តិរបស់ស្ថាប័នដៃគូអភិវឌ្ឍន៍ ព្រមទាំងដាក់ឱ្យចាប់ផ្តើមដំណើរការអនុវត្តគម្រោងតាមនីតិវិធីរួមបច្ចុប្បន្នកម្ម សម្រាប់អនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍នានា នៅដំណាក់កាលអនុវត្តគម្រោងតែម្តង។

- ***ដំណាក់កាលអនុវត្ត និងត្រួតពិនិត្យការអនុវត្តថវិកា***

បន្ទាប់ពីច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ឬហៅថា ច្បាប់ថវិកាប្រចាំឆ្នាំ ត្រូវបានអនុម័តរួច, ក្រសួង-ស្ថាប័ន ដែលជាអាណាប័កដើមខ្សែ តម្រូវឱ្យស្នើសុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធានាចំណាយ។ បច្ចុប្បន្ន ការត្រួតពិនិត្យចំណាយរបស់ក្រសួង-ស្ថាប័ន ត្រូវបានអនុវត្តតាមយន្តការមជ្ឈការ ក្នុងដំណាក់កាលធានាចំណាយ, កិច្ចលទ្ធកម្ម, អាណត្តិកិច្ច, និងការទូទាត់។

- ***ដំណាក់កាលតាមដាន និងវាយតម្លៃការអនុវត្តថវិកា***

ក្នុងការអនុវត្តថវិកា ក្រសួង-ស្ថាប័ន ត្រូវផ្តល់របាយការណ៍ហិរញ្ញវត្ថុ ស្របតាមគោលការណ៍គណនេយ្យទូទៅរបស់រដ្ឋ និងរបាយការណ៍សមិទ្ធកម្ម តាមកម្មវិធីប្រចាំឆមាស និងប្រចាំឆ្នាំ ដោយផ្អែកលើទម្រង់នៃរបាយការណ៍ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**<u>តារាងសង្ខេបអំពីយន្តការស្ថាប័ន</u>**



## ៤.២.៤. យន្តការគាំទ្រហិរញ្ញវត្ថុ

នីតិវិធីអនុវត្តបច្ចុប្បន្ន សម្រាប់ការវិនិយោគសាធារណៈនៅកម្ពុជា ពុំទាន់បានកំណត់ច្បាស់លាស់អំពីយន្តការគាំទ្រហិរញ្ញវត្ថុរួម សម្រាប់គ្រប់ប្រភពហិរញ្ញប្បទាននៅឡើយទេ។ ជារួម, ការរៀបចំគម្រោងវិនិយោគសាធារណៈត្រូវបានអនុវត្តទៅតាមប្រភពហិរញ្ញប្បទាន ដូចខាងក្រោម÷

- *យន្តការគាំទ្រហិរញ្ញវត្ថុ សម្រាប់គម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាជាតិ÷*

បច្ចុប្បន្នគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាជាតិ (ទាំងថ្នាក់ជាតិ និងទាំងថ្នាក់ក្រោមជាតិ) មានចរិតជាគម្រោងវិនិយោគទៅតាមតម្រូវការអាទិភាពបន្ទាន់របស់រាជរដ្ឋាភិបាល មានទំហំទឹកប្រាក់តូច ពុំសូវមានភាពស្មុគស្មាញ និងពុំទាន់មានយន្តការគាំទ្រហិរញ្ញវត្ថុ សម្រាប់សិក្សាសមិទ្ធិលទ្ធភាព និងរៀបចំគម្រោងនៅឡើយ។ ក្នុងបរិការណ៍នៃការអភិវឌ្ឍក្នុងដំណាក់កាលថ្មី, គម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាជាតិ កាន់តែមានទំហំធំជាងមុន, ស្មុគស្មាញជាងមុន, និងមានចរិតជាគម្រោងពហុឆ្នាំ ដែលកង្វះយន្តការគាំទ្រហិរញ្ញវត្ថុ សម្រាប់ការសិក្សាសមិទ្ធិលទ្ធភាព និងរៀបចំគម្រោង បានក្លាយជាបញ្ហាប្រឈមចំពោះគោលដៅនៃការធានានូវភាពឆ្លើយតប, ប្រសិទ្ធភាព, និងចីរភាពនៃការអនុវត្តគម្រោងវិនិយោគសាធារណៈ។

- *យន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់គម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានពីក្រៅប្រទេស÷*

ចំពោះគម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស, ថវិកាសម្រាប់ការសិក្សាសមិទ្ធិលទ្ធភាព និងរៀបចំគម្រោង ត្រូវបានហិរញ្ញប្បទានដោយហិរញ្ញប្បទានឥតសំណង, ជំនួយបច្ចេកទេស ឬមូលនិធិអភិវឌ្ឍន៍គម្រោងរបស់ដៃគូអភិវឌ្ឍន៍ ដោយត្រូវគោរពតាមនីតិវិធី និងគោលការណ៍ណែនាំ ដែលមានជាធរមានរបស់ដៃគូអភិវឌ្ឍន៍។ ទោះជាយ៉ាងណា, បច្ចុប្បន្នមានដៃគូអភិវឌ្ឍន៍មួយចំនួនកំពុងប្រឈមនឹងភាពរឹងស្ងួតនៃប្រភពហិរញ្ញប្បទានក្រោមទម្រង់ខាងលើ ហើយកំពុងជំរុញឱ្យរាជរដ្ឋាភិបាលពិនិត្យលទ្ធភាពប្រើប្រាស់ថវិកាជាតិ ឬខ្ចីជាឥណទានសម្បទាន សម្រាប់ទ្រទ្រង់ចំណាយលើការសិក្សាសមិទ្ធិលទ្ធភាព និងរៀបចំគម្រោង។

- *យន្តការគាំទ្រហិរញ្ញវត្ថុ សម្រាប់គម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន÷*

យន្តការគាំទ្រហិរញ្ញវត្ថុ សម្រាប់សិក្សាសមិទ្ធិលទ្ធភាព និងរៀបចំគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ពុំទាន់ត្រូវបានបង្កើតឡើងនៅឡើយ។ នៅក្នុងដំណាក់កាលអន្តរកាល, ក្រសួង-ស្ថាប័នជំនាញត្រូវបានលើកទឹកចិត្តឱ្យស្នើសុំថវិកា សម្រាប់ការសិក្សា និងរៀបចំគម្រោងពីដៃគូអភិវឌ្ឍន៍ ដោយត្រូវគោរពតាមនីតិវិធី និងគោលការណ៍ណែនាំ ដែលមានជាធរមានរបស់ដៃគូអភិវឌ្ឍន៍។ ទោះបីជាយ៉ាងនេះក្តី, ដើម្បីជំរុញការអនុវត្តគម្រោងវិនិយោគសាធារណៈតាមយន្តការនេះ, រាជរដ្ឋាភិបាលបាននិងកំពុងពិនិត្យលទ្ធភាពក្នុងការបង្កើតមូលនិធិចំនួន ២ គឺ÷ ១)- មូលនិធិអភិវឌ្ឍន៍គម្រោង ដែលមានគោលដៅគាំទ្រដល់ការសិក្សាសមិទ្ធិលទ្ធភាព និងរៀបចំគម្រោង, និង ២)- មូលនិធិបំពេញផលហិរញ្ញវត្ថុ ដែលមានគោលដៅក្នុងការជួយឧបត្ថម្ភដល់គម្រោងវិនិយោគសាធារណៈមួយចំនួន ដើម្បីឱ្យមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សម្រាប់ទាក់ទាញវិនិយោគិនពីវិស័យឯកជន។

### ៤.២.៥. គោលការណ៍ និងអភិក្រមនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ

បច្ចុប្បន្ន គម្រោងវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន (ទាំងថវិការដ្ឋ ថវិកាដៃគូអភិវឌ្ឍន៍ និងទុនវិនិយោគឯកជន) និងពីគ្រប់កម្រិតរដ្ឋបាល (ទាំងថ្នាក់ជាតិ ទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែល) ត្រូវបានរៀបចំ និងអនុវត្តទៅតាមគោលការណ៍ និងអភិក្រមផ្សេងៗគ្នា ដែលមិនទាន់អាចធានាបាននូវប្រសិទ្ធភាពនៃទំនាក់ទំនងប្រទាក់ក្រឡា និងបំពេញឱ្យគ្នាទៅវិញទៅមកនៅឡើយ។

**១)- គម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ**

ក្រសួង-ស្ថាប័នជំនាញ មានភារកិច្ចរៀបចំសំណើគម្រោងវិនិយោគសាធារណៈ ដោយផ្អែកលើអាទិភាពគោលនយោបាយតាមវិស័យ ដែលត្រូវគោរពទៅតាមគោលដៅអាទិភាពនៃគោលនយោបាយជាតិ ជាពិសេស គឺត្រូវគោរពទៅតាមគោលការណ៍កំណត់អាទិភាពគម្រោងប្រចាំឆ្នាំ ដែលសម្រេចដោយប្រមុខរាជរដ្ឋាភិបាល។ ទោះជាយ៉ាងណា, ក្រសួង-ស្ថាប័នជំនាញភាគច្រើន មិនទាន់មានលទ្ធភាពរៀបចំផែនការគម្រោងវិនិយោគសាធារណៈរយៈពេលមធ្យមរបស់ខ្លួនឱ្យឆ្លើយតបតាមគោលដៅអាទិភាពនៃគោលនយោបាយជាតិ និងប្រកបដោយគុណភាពនៅឡើយ ដោយសារកម្ពុជានៅមិនទាន់មាន **«គោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណកម្ម និងរៀបចំគម្រោង»** បូករួមនឹងបញ្ហាសមត្ថភាពនៅមានកម្រិត និងកង្វះយន្តការគាំទ្រហិរញ្ញវត្ថុ សម្រាប់សិក្សាសមិទ្ធិលទ្ធភាពគម្រោង។

ការជ្រើសរើស និងអនុម័តថវិកាសម្រាប់គម្រោងវិនិយោគសាធារណៈនីមួយៗ គឺធ្វើឡើងក្រោយពីច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ត្រូវបានដាក់ឱ្យអនុវត្ត ហើយប្រើយន្តការគណៈកម្មការអន្តរក្រសួង (ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសាមី) ជាសេនាធិការ ក្នុងការរៀបចំបញ្ជីគម្រោងអាទិភាព និងស្នើសុំការពិនិត្យសម្រេចពីប្រមុខរាជរដ្ឋាភិបាល។ ក្នុងដំណើរការអនុវត្តគម្រោង, ក្រសួង-ស្ថាប័នម្ចាស់គម្រោង ដើរតួនាទីស្នូលក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោង ឱ្យត្រឹមត្រូវតាមស្តង់ដារបច្ចេកទេស និងបទដ្ឋានពាក់ព័ន្ធជាធរមាន។ ទន្ទឹមនេះ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងតួនាទីជាអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ពិនិត្យ និងវាយតម្លៃគម្រោង ដោយផ្អែកទៅតាមលក្ខខណ្ឌនៃកិច្ចសន្យាជាធរមាន។

**២)- គម្រោងវិនិយោគសាធារណៈដោយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ**

រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ទទួលបានការឧបត្ថម្ភធន ឬការផ្ទេរធនធាន ដើម្បីបំពេញចំណាយពីថវិកាថ្នាក់ជាតិ។ បច្ចុប្បន្ន, រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ទទួលបានការផ្តល់ហិរញ្ញប្បទានស្ទើរតែទាំងស្រុង ដោយការផ្ទេរថវិកាពីថ្នាក់ជាតិ។ ថវិការបស់រដ្ឋបាលរាជធានី ខេត្ត មួយចំណែកធំ មានប្រភពចំណូលពីមូលដ្ឋាន (ចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ) និងមួយចំណែកទៀត ទទួលបានពីការផ្ទេរថវិកាពីថ្នាក់ជាតិ។ ទន្ទឹមនេះ, រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តមូលនិធិមានភ្ជាប់លក្ខខណ្ឌ សម្រាប់ផ្តល់ហិរញ្ញប្បទានលើគម្រោងវិនិយោគសាធារណៈ ដែលមានចរិតលក្ខណៈជាយុទ្ធសាស្ត្រ ក្នុងគោលដៅជំរុញ និងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្នុងន័យនេះ, រដ្ឋបាលថ្នាក់ក្រោមជាតិ រៀបចំផែនការអភិវឌ្ឍន៍រយៈពេល ៥ ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរៀងៗខ្លួន ដើម្បីស្នើសុំក្រុមប្រឹក្សាសាមី ពិនិត្យ និងអនុម័ត។ ទោះបីជាមានគោលការណ៍, យន្តការ, និងនីតិវិធីសម្រាប់គ្រប់គ្រង និងអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគក្តី ក៏ដំណើរការគ្រប់គ្រងការវិនិយោគសាធារណៈនៅថ្នាក់ក្រោមជាតិ ពុំទាន់មានភាពច្បាស់លាស់នៅឡើយ។ យន្តការសម្របសម្រួលពិគ្រោះយោបល់ តាមរយៈគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ត្រូវបានបង្កើតឡើង ដើម្បីធ្វើសមាហរណកម្មផែនការអភិវឌ្ឍន៍ ៥ ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ទោះជាយ៉ាងនេះក្តី, អាស្រ័យដោយភាពខុសគ្នានៃក្របខ័ណ្ឌពេលវេលា, វិធីសាស្ត្រ, និងអភិក្រមនៃការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ របស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ បានធ្វើឱ្យកិច្ចការធ្វើសមាហរណកម្មនេះ មិនអាចសម្រេចបាន។

ផ្អែកតាមកម្មវិធីជាអាទិភាព ដែលមាននៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល, រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ រៀបចំផែនការយុទ្ធសាស្ត្រថវិកា និងផែនការថវិកាប្រចាំឆ្នាំ ដើម្បីស្នើសុំក្រុមប្រឹក្សាសាមីពិនិត្យ និងអនុម័ត។

ផែនការយុទ្ធសាស្ត្រថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិ មិនទាន់ត្រូវបានធ្វើសមាហរណកម្ម នៅកម្រិតរាជធានី ខេត្ត និងនៅមិនទាន់បានតម្រឹមជាមួយនឹងផែនការរបស់មន្ទីរជំនាញរាជធានី ខេត្ត នៅឡើយ ដោយសារនៅពុំទាន់បានសម្របសម្រួល និងសហការគ្នារៀបចំរវាងក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលរាជធានី ខេត្ត គឺរៀបចំឡើងដោយផ្អែកលើអាទិភាពតាមវិស័យពីថ្នាក់ជាតិចុះមក។ ជាមួយគ្នានេះ, សមត្ថភាពបច្ចេកទេសរបស់រដ្ឋបាលរាជធានី ខេត្តនៅមានកម្រិត ដែលបានបង្ហាញឱ្យឃើញពីភាពទន់ខ្សោយនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា តាមរយៈការកំណត់មិនបានច្បាស់លាស់អំពីសូចនាករសមិទ្ធកម្មនៅក្នុងកម្មវិធី និងចង្កោមសកម្មភាព ក៏ដូចជាការប៉ាន់ប្រមាណថវិកាជាដើម។ ភាពទន់ខ្សោយនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ បានធ្វើឱ្យធនធានសាធារណៈមិនបានឆ្លុះបញ្ចាំងពីអាទិភាពគោលនយោបាយបានទាំងស្រុង ដែលជាលទ្ធផលធ្វើឱ្យការផ្តល់សេវាសាធារណៈមិនបានគ្រប់ជ្រុងជ្រោយ។

ទោះជាយ៉ាងនេះក្តី, **យុទ្ធសាស្ត្រនៃកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩ - ២០២៥** ដែលត្រូវបានរាជរដ្ឋាភិបាលអនុម័តនៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៩ គឺការកែទម្រង់ប្រព័ន្ធថវិកាដែលមានរយៈពេលវែង និងគ្រប់ជ្រុងជ្រោយ ដោយមានគោលដៅធានាឱ្យបានការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ជាពិសេសគោលបំណងគោលនយោបាយរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវតម្រឹមជាមួយនឹងគោលបំណង/អាទិភាពគោលនយោបាយជាតិ។ ផែនការ/កម្មវិធីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវធ្វើឱ្យមានការផ្សារភ្ជាប់ទំនាក់ទំនងគ្នាបំពេញឱ្យគ្នា និងប្រទាក់គ្នាទៅវិញទៅមក តាមរយៈសមាហរណកម្មផែនការយុទ្ធសាស្ត្រថវិកា។ ទន្ទឹមនឹងការធ្វើសមាហរណកម្មផែនការយុទ្ធសាស្ត្រថវិកា គឺត្រូវកែលម្អ និងផ្លាស់ប្តូរ ជាជំហានៗនូវវដ្តថវិកានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ពិសេស កំណត់ឱ្យបានត្រឹមត្រូវច្បាស់លាស់អំពីសិទ្ធិអំណាច និងការទទួលខុសត្រូវនៅក្នុងដំណាក់កាលនៃវដ្តថវិកា។

### ៣)- គម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

ផ្អែកតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, ក្រសួងផែនការសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ធ្វើ

អាទិភាវូបនីយកម្មលើសំណើគម្រោងវិនិយោគសាធារណៈ ដែលបានស្នើឡើងដោយក្រសួង-ស្ថាប័នសាមី ដើម្បីរៀបចំកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល និងត្រូវដាក់ស្នើសុំការអនុម័តពីគណៈរដ្ឋមន្ត្រី។ ទន្ទឹមគ្នានេះ, ដៃគូអភិវឌ្ឍន៍នីមួយៗដោយសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងដោយមានការពិគ្រោះយោបល់ជាមួយក្រសួង-ស្ថាប័នជំនាញ, រៀបចំក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការភាពជាដៃគូរយៈពេលមធ្យមរបស់ខ្លួន ដោយកំណត់អំពីកម្មវិធី/គម្រោង និងវិស័យអាទិភាព ដែលដៃគូអភិវឌ្ឍន៍នីមួយៗនឹងរួមចំណែកជួយគាំទ្រដល់កិច្ចអភិវឌ្ឍរបស់រាជរដ្ឋាភិបាល។ ក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការភាពជាដៃគូនេះ ត្រូវបានរៀបចំដោយផ្អែកលើរបៀបវារៈអភិវឌ្ឍន៍របស់ដៃគូនីមួយៗ និងឆ្លើយតបតាមតម្រូវការអាទិភាពរបស់រាជរដ្ឋាភិបាល ដែលបានកំណត់ក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិល អនុលោមតាមយុទ្ធសាស្ត្រចតុកោណ, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កំណត់ស្ថាប័ន ដែលត្រូវបំពេញមុខងារជាភ្នាក់ងារប្រតិបត្តិ និងអនុវត្តគម្រោងដោយផ្អែកលើសមត្ថកិច្ច និងអាណត្តិកិច្ចរបស់ក្រសួង-ស្ថាប័ននីមួយៗ ព្រមទាំងដឹកនាំការចរចាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិជាមួយដៃគូអភិវឌ្ឍន៍។ បន្ទាប់ពីគម្រោងត្រូវបានប្រកាសចូលជាធរមាន ក្រសួង-ស្ថាប័នជាភ្នាក់ងារអនុវត្តគម្រោង ត្រូវដឹកនាំគ្រប់គ្រងការអនុវត្ត ដោយអនុលោមតាមខ្លឹមសារនៃកិច្ចព្រមព្រៀងហិរញ្ញប្បទាន និងនីតិវិធីរួម សម្រាប់អនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍។

**៨)- គម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន**

ច្បាប់ស្តីពីសម្បទានត្រូវបានអនុម័ត និងប្រកាសដាក់ឱ្យប្រើនៅឆ្នាំ២០០៧ ប៉ុន្តែ សេចក្តីព្រាងអនុក្រឹត្យសម្រាប់គាំទ្រដល់ការអនុវត្តច្បាប់នេះ មិនទាន់ត្រូវបានអនុម័តនៅឡើយ។ ទោះបីជាយ៉ាងនេះក្តី, ក្នុងរយៈកាលអន្តរកាលកន្លងមក ក៏មានគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនមួយចំនួនជាពិសេស គម្រោងក្នុងវិស័យថាមពល និងអាកាសចរណ៍ ត្រូវបានរៀបចំ និងអនុវត្តតាមយន្តការចំពោះកិច្ច។ ការប្រើប្រាស់យន្តការចំពោះកិច្ចនេះ បានបង្កើតនូវបញ្ហាប្រឈមមួយចំនួន ដូចជា÷ គុណភាពនៃការវាយតម្លៃហានិភ័យហិរញ្ញវត្ថុនៃគម្រោង, ប្រសិទ្ធភាពសេដ្ឋកិច្ច-សង្គម ដែលទទួលបានពីគម្រោងវិនិយោគ, និងសមភាពនៃការបែងចែកផល និងហានិភ័យ រវាងដៃគូរដ្ឋនិងឯកជនជាដើម។ ក្នុងន័យនេះ, កាលពីឆ្នាំ២០១៦ រាជរដ្ឋាភិបាលបានដាក់ចេញនូវ **«ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦ - ២០២០»** ដើម្បីឈានទៅបង្កើតប្រព័ន្ធគ្រប់គ្រងមួយ ស្របតាមឧត្តមានុវត្តជាអន្តរជាតិ និងបរិការណ៍ជាក់ស្តែងរបស់កម្ពុជា, ពង្រឹងការគ្រប់គ្រងកាតព្វកិច្ចបំណុលជាយថាហេតុ ដែលកើតចេញពីការអនុវត្តគម្រោងវិនិយោគសាធារណៈតាមយន្តការនេះ និង ជាពិសេស ដើម្បីឈានទៅលុបបំបាត់ការប្រើប្រាស់យន្តការចំពោះកិច្ច។

នៅក្នុងដំណាក់កាលអន្តរកាល, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបង្កើតគណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដើម្បី÷ ១)- ពិនិត្យឡើងវិញនូវបទប្បញ្ញត្តិ និងច្បាប់ពាក់ព័ន្ធ ព្រមទាំងធ្វើវិសោធនកម្មតាមការចាំបាច់, ២)- រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ, នីតិវិធីគ្រប់គ្រងប្រតិបត្តិការនៃគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន, និង

៣)- ពិនិត្យ និងអនុម័តបញ្ជីគម្រោងអាទិភាពតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន និងលទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាពគម្រោងអាទិភាពទាំងនោះ និងគម្រោងសាកល្បងផងដែរ។

**៥)- គម្រោងវិនិយោគសាធារណៈរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល**

គម្រោងវិនិយោគសាធារណៈរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបានរៀបចំ និងសម្រេចដោយក្រុមប្រឹក្សាភិបាល ដែលជាអង្គការដឹកនាំខ្ពស់បំផុតរបស់គ្រឹះស្ថាន ដោយផ្អែកលើផែនការអភិវឌ្ឍន៍របស់គ្រឹះស្ថាន សម្រាប់រយៈពេលមធ្យម និងវែង។ គម្រោងថវិការបស់គ្រឹះស្ថាន ត្រូវបានរៀបចំដោយនាយកគ្រឹះស្ថាន ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាល ពិនិត្យ និងអនុម័ត រួចបញ្ជូនទៅក្រសួង-ស្ថាប័នអាណាព្យាបាលបច្ចេកទេស ពិនិត្យ និងសម្រេចមុននឹងបញ្ជូនបន្តទៅក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ ពិនិត្យ និងសម្រេច ដោយអនុលោមតាមប្រតិទិននៃការរៀបចំថវិកាប្រចាំឆ្នាំ ដូចមានចែងក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

**៦)- គម្រោងវិនិយោគសាធារណៈរបស់សហគ្រាសសាធារណៈ**

ស្រដៀងគ្នាទៅនឹងគ្រឹះស្ថានសាធារណៈរដ្ឋបាលដែរ, គម្រោងវិនិយោគសាធារណៈរបស់សហគ្រាសសាធារណៈ ត្រូវបានរៀបចំ និងសម្រេចដោយក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបាល សម្រេចគម្រោងថវិកាប្រចាំឆ្នាំសម្រាប់ការប្រព្រឹត្តទៅ និងការវិនិយោគដោយផ្អែកតាមផែនការអភិវឌ្ឍន៍សហគ្រាស ដែលឯកសារទាំងនេះត្រូវដាក់សុំការអនុម័តយល់ព្រមពីក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេស និងក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ។

**៧)- គម្រោងវិនិយោគសាធារណៈ ហិរញ្ញប្បទានដោយឥណទានពាណិជ្ជកម្ម**

បច្ចុប្បន្ន កម្ពុជានៅពុំទាន់បានបោះផ្សាយមូលបត្ររដ្ឋ ដែលជាការខ្ចីក្នុងប្រទេស មានលក្ខខណ្ឌជាឥណទានពាណិជ្ជកម្ម សម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគសាធារណៈណាមួយនៅឡើយទេ។ ទោះជាយ៉ាងនេះក្តី, កម្ពុជាក៏បានត្រៀមលក្ខណៈសម្បត្តិរបស់ខ្លួនជាបណ្តើរៗ សម្រាប់ឈានទៅបោះផ្សាយមូលបត្ររដ្ឋក្នុងពេលដ៏ខ្លីខាងមុខ ដើម្បីឆ្លើយតបនឹងទំហំតម្រូវការដ៏ធំនៃទុនវិនិយោគសាធារណៈ និងបរិការណ៍សេដ្ឋកិច្ចក្នុងដំណាក់កាលអភិវឌ្ឍន៍ថ្មី។

**៨)- គម្រោងវិនិយោគសាធារណៈ ហិរញ្ញប្បទានដោយការធ្វើឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរដ្ឋ**

កន្លងមកនេះ គម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈមួយចំនួន ត្រូវបានហិរញ្ញប្បទានដោយថវិកាបានពីការធ្វើឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរដ្ឋ តាមរយៈនៃការលក់ ជួល ឬដោះដូរទ្រព្យសម្បត្តិរដ្ឋ។ ជាគោលការណ៍, ថវិកាដែលទទួលបានពីការធ្វើឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរដ្ឋ ត្រូវបានជាគុណប្រយោជន៍នៃថវិកាជាតិ ហើយរាជរដ្ឋាភិបាលចាត់ចែងប្រើប្រាស់សម្រាប់មុខចំណាយអាទិភាព និងចំណាយវិនិយោគសាធារណៈទៅតាមនីតិវិធីគ្រប់គ្រងតាមប្រភេទចំណាយជាធរមាន។ បើទោះបីជាយ៉ាងនេះក្តី, ក្នុងការអនុវត្តកន្លងមក មានករណីដោយឡែកមួយចំនួន ដែលការធ្វើឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរដ្ឋ ត្រូវបានផ្តល់ជាថ្នូរមកវិញដោយវិស័យឯកជនចាត់ចែងអនុវត្តគម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈ តាមអភិក្រម **“ប្រគល់សោរដល់ដៃ-Turnkey Contract”** ជូនភាគីរាជរដ្ឋាភិបាលតែម្តង ដោយនីតិវិធី និងយន្តការគ្រប់គ្រងការអនុវត្តគម្រោងរបស់ក្រសួងជំនាញ និងមុខងារជាទ្វារបាលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនត្រូវបានប្រើប្រាស់ពេញលេញ សម្រាប់

គោលដៅនៃការធានាប្រសិទ្ធភាពសេដ្ឋកិច្ចនៃការវិនិយោគសាធារណៈបែបនេះទេ។ ការណ៍នេះ តម្រូវឱ្យរាជរដ្ឋាភិបាលត្រូវដាក់ចេញនូវវិធាន និងនីតិវិធីគ្រប់គ្រងច្បាស់លាស់ សម្រាប់គ្រប់គ្រងគម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈប្រភេទនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់។

**៩)- គម្រោងវិនិយោគសាធារណៈ ដោយប្រភពហិរញ្ញប្បទានចម្រុះ**

គម្រោងវិនិយោគសាធារណៈដោយប្រភពហិរញ្ញប្បទានចម្រុះ សំដៅដល់គម្រោងវិនិយោគហិរញ្ញប្បទានដោយទុនវិនិយោគសាធារណៈ ជាមួយទុនវិនិយោគពីវិស័យឯកជន ដែលក្នុងនោះ រាជរដ្ឋាភិបាលប្រើប្រាស់ទុនវិនិយោគសាធារណៈជាយុទ្ធសាស្ត្រ សម្រាប់ទាក់ទាញទុនវិនិយោគបន្ថែមពីវិស័យឯកជន ឆ្ពោះទៅសម្រេចគោលដៅនៃការអភិវឌ្ឍប្រកបដោយចីរភាព និងជំរុញការហក់ឡើងនៃកំណើនសេដ្ឋកិច្ច។ ជាទូទៅ គម្រោងវិនិយោគប្រភេទនេះ ត្រូវបានផ្តោតលើវិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលរួមមាន÷ ថាមពល, ផ្លូវថ្នល់, ការផ្គត់ផ្គង់ទឹកស្អាត, និងលំនៅដ្ឋានតម្លៃសមរម្យ ជាដើម។

ក្នុងន័យនេះ, ដើម្បីពង្រឹងការគ្រប់គ្រងគម្រោងប្រភេទនេះឱ្យមានប្រសិទ្ធភាពខ្ពស់ តម្រូវឱ្យរាជរដ្ឋាភិបាលត្រូវដាក់ចេញនូវគោលការណ៍ណែនាំច្បាស់លាស់ និងមានភាពទន់ភ្លន់ ដើម្បីទាក់ទាញជាអតិបរមានូវទុនវិនិយោគពីវិស័យឯកជន សម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។

## ៤.៣. បញ្ហាប្រឈម និងការអនុវត្តនាព

### ៤.៣.១. បញ្ហាប្រឈម

ដោយសារកង្វះនូវក្របខ័ណ្ឌរួម ដែលកំណត់ជាអាទិ៍អំពី÷ គោលការណ៍, អភិក្រម, យន្តការស្ថាប័ន, និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការ, ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈនៅកម្ពុជា បាននិងកំពុងប្រឈមនឹងបញ្ហាមួយចំនួន ដូចខាងក្រោម÷

- *ក្របខ័ណ្ឌគតិយុត្ត*

  លិខិតបទដ្ឋានគតិយុត្តចាំបាច់មួយចំនួន ដែលកំណត់អំពីអភិក្រម គោលការណ៍ និងសមត្ថកិច្ចស្ថាប័នក្នុងការកំណត់អត្តសញ្ញាណកម្ម, រៀបចំ, គ្រប់គ្រង, និងអនុវត្តគម្រោងវិនិយោគសាធារណៈ នៅមិនទាន់ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត។

- *ការធ្វើអត្តសញ្ញាណកម្ម និងការរៀបចំសំណើគម្រោងបឋម*

  - ផែនការវិនិយោគសាធារណៈ ត្រូវបានរៀបចំ សម្រាប់តែគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ប៉ុណ្ណោះ ក្នុងទម្រង់ជាកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល។ ដោយឡែក គម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានពីប្រភពផ្សេងៗទៀត ដូចជា ថវិកាជាតិ និងទុនវិនិយោគ ឯកជនតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន នៅពុំទាន់រៀបចំឱ្យមានជាផែនការវិនិយោគសាធារណៈរយៈពេលមធ្យម,
  - កម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិលមិនទាន់ឆ្លើយតបបានពេញលេញទៅនឹងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដោយសារពុំទាន់មាន **«គោលការណ៍ណែនាំស្តីពីការកំណត់**

**អត្តសញ្ញាណកម្ម និងរៀបចំគម្រោង»** ដែលមានភាពពេញលេញ និងគ្រប់ជ្រុងជ្រោយនៅឡើយ សម្រាប់ជាមូលដ្ឋានឱ្យក្រសួង-ស្ថាប័នជំនាញ អាចកំណត់អត្តសញ្ញាណគម្រោងបានត្រឹមត្រូវ ព្រមទាំង បន្ទុ និងតម្រឹមសំណើគម្រោងជាក់លាក់នីមួយៗ ទៅតាមគោលបំណង និងគោលដៅនៃផែនការ អភិវឌ្ឍន៍ជាតិ,

- មិនទាន់មានយន្តការសម្របសម្រួលច្បាស់លាស់ នៅដំណាក់កាលសមាហរណកម្មផែនការវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន និងពីគ្រប់កម្រិតរដ្ឋបាល ដើម្បីកសាងនូវផែនការវិនិយោគសាធារណៈ ដែលមានភាពគ្រប់ជ្រុងជ្រោយ ធានាឱ្យគម្រោងទាំងអស់ប្រទាក់ក្រឡា និងបំពេញឱ្យគ្នាទៅវិញទៅមក ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពសេដ្ឋកិច្ច និងឆ្លើយតបនឹង គោលបំណងរួមនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ,
- កង្វះយន្តការ និងការសម្របសម្រួលផ្ទៃក្នុងនៅកម្រិតក្រសួង-ស្ថាប័នជំនាញ ក្នុងការកំណត់អត្តសញ្ញាណកម្មនិងរៀបចំសំណើគម្រោងវិនិយោគសាធារណៈ និងរៀបចំផែនការគម្រោងវិនិយោគសាធារណៈ,
- ចំពោះក្រសួង-ស្ថាប័នជំនាញមួយចំនួន ដែលមានសមត្ថកិច្ចពាក់ព័ន្ធនឹងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធរូបវន្តតភ្ជាប់ និងនគរូបនីយកម្ម នៅមិនទាន់បានរៀបចំផែនការមេ ដែលជាមូលដ្ឋានក្នុងការតម្រង់ទិសនៃការរៀបចំផែនការវិនិយោគសាធារណៈនៅឡើយ,
- កម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល មិនទាន់ផ្សារភ្ជាប់គ្នាទៅនឹងថវិកានីយកម្មការវិនិយោគសាធារណៈ, និង
- កម្មវិធីវិនិយោគបីឆ្នាំរំកិល ដែលបានរៀបចំដោយរដ្ឋបាលថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ពុំបានផ្សារភ្ជាប់ទំនាក់ទំនងប្រទាក់ក្រឡា និងបំពេញឱ្យគ្នាទៅវិញទៅមក ដោយសារមិនទាន់ធ្វើសមាហរណកម្មកម្មវិធីវិនិយោគក្នុងក្របខ័ណ្ឌកម្រិតរាជធានី ខេត្តតែមួយ ដើម្បីផ្សារភ្ជាប់ទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងអាទិភាពគោលនយោបាយជាតិ។

- *ការសិក្សាសមិទ្ធិលទ្ធភាព, ការវាយតម្លៃ និងការរៀបចំសំណើគម្រោងផ្លូវការ*
  - ពុំទាន់មាន **«គោលការណ៍ណែនាំស្តីពីការសិក្សា និងការវាយតម្លៃសមិទ្ធិលទ្ធភាព និងចីរភាពនៃគម្រោង»** ជាពិសេស សម្រាប់គម្រោងហិរញ្ញប្បទានដោយថវិកាជាតិ,
  - ខ្វះយន្តការគាំទ្រហិរញ្ញវត្ថុ សម្រាប់សិក្សាសមិទ្ធិលទ្ធភាពនៃគម្រោង, រៀបចំនូវបញ្ជីប៉ាន់តម្លៃគម្រោងលម្អិត, និងប្លង់បច្ចេកទេសគ្រប់ជ្រុងជ្រោយ, និង
  - កង្វះការសិក្សាវាយតម្លៃផលប៉ះពាល់សង្គម និងបរិស្ថាន ក្នុងដំណាក់កាលសិក្សាសមិទ្ធិលទ្ធភាព និងរៀបចំគម្រោង។
- *ការពិនិត្យ និងវាយតម្លៃលើសំណើគម្រោង*
  - មុខងារទ្វារបាលកិច្ច របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅក្នុងដំណាក់កាលបុរេថវិកានីយកម្មគម្រោងវិនិយោគសាធារណៈ នៅមានភាពចាំបាច់ត្រូវពង្រឹងបន្ថែម និងធ្វើស្ថាបនូបនីយកម្ម, និង

- មិនទាន់មានយន្តការគ្រប់គ្រងនៅដំណាក់កាលបុរេថវិកានីយកម្មការវិនិយោគសាធារណៈ ដើម្បី÷ ១)- ពិនិត្យ និងវាយតម្លៃលើសំណើគម្រោងរបស់ក្រសួង-ស្ថាប័ន, និង ២)- ជ្រើសរើសគម្រោងដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់, កំណត់ប្រភពហិរញ្ញប្បទានសមស្រប, និងដាក់ចូលក្នុងដំណាក់កាលថវិកានីយកម្ម។

• *ការជ្រើសរើសសំណើគម្រោង និងថវិកានីយកម្ម*

- នៅមានភាពចាំបាច់ត្រូវពង្រឹងបន្ថែម និងធ្វើស្ថាបនូបនីយកម្មនូវ **«គោលការណ៍ណែនាំស្តីពីការជ្រើសរើសគម្រោង»** ដែលត្រូវកំណត់ច្បាស់លាស់អំពីលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសគម្រោងសម្រាប់ធានាបាននូវប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, និងចីរភាពនៃការវិនិយោគសាធារណៈ ព្រមទាំងភាពឆ្លើយតបនឹងតម្រូវការអាទិភាពពិតប្រាកដរបស់រាជរដ្ឋាភិបាល,
- ពុំទាន់មានប្រព័ន្ធពេញលេញ សម្រាប់ការធ្វើសមាហរណកម្មថវិកាវិនិយោគសាធារណៈជាមួយនឹងថវិកាចរន្តសម្រាប់គម្រោងវិនិយោគសាធារណៈ ជាពិសេស គឺថវិកាប្រតិបត្តិការ និងថែទាំ។ បច្ចុប្បន្ន បើទោះបីជាផែនការយុទ្ធសាស្ត្រថវិកាត្រូវបានប្រើប្រាស់ជាឧបករណ៍ សម្រាប់ការធ្វើ សមាហរណកម្មថវិកាវិនិយោគ ជាមួយនឹងថវិកាចរន្តក្តី ប៉ុន្តែជាក់ស្តែង ការវិភាជន៍ថវិកាចរន្ត សម្រាប់ទ្រទ្រង់ចំណាយប្រតិបត្តិការ និងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលត្រូវបានសាងសង់រួច មិនទាន់ត្រូវបានគ្រោងឱ្យបានគ្រប់ជ្រុងជ្រោយ និងឆ្លើយតបតាមតម្រូវការចាំបាច់ទាំងស្រុងនៅឡើយ, និង
- ប្រតិទិននៃការៀបចំ និងអនុម័តផែនការវិនិយោគសាធារណៈ និងប្រតិទិននៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាប្រចាំឆ្នាំ នៅមិនទាន់ត្រូវបានកែសម្រួល និងតម្រឹម ដើម្បីផ្សារភ្ជាប់ផែនការវិនិយោគសាធារណៈ ទៅនឹងដំណាក់កាលថវិកានីយកម្មនៅឡើយ។

• *ការគ្រប់គ្រង និងការអនុវត្តគម្រោង*

ចំពោះគម្រោងវិនិយោគសាធារណៈដោយថវិកាជាតិ នៅមិនទាន់មានឯកសារណែនាំស្តីពីនីតិវិធីប្រតិបត្តិការ ដែលកំណត់អំពីគោលការណ៍ អភិក្រម នីតិវិធី និងយន្តការក្នុងការរៀបចំគម្រោង, ការពិនិត្យ និងវាយតម្លៃសំណើគម្រោង, ការជ្រើសរើស, ការធ្វើថវិកានីយកម្ម, និងការគ្រប់គ្រងនិងអនុវត្តគម្រោងទៅតាមដំណាក់កាលនីមួយៗនៃវដ្តគម្រោង។

• *ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាងសង់ក្រោមគម្រោង*

នៅមានភាពចាំបាច់ត្រូវពង្រឹងបន្ថែម និងធ្វើស្ថាបនូបនីយកម្មនូវយន្តការ, គោលការណ៍, និងនីតិវិធីគ្រប់គ្រងលើការប្រើប្រាស់និងថែទាំហេដ្ឋារចនាសម្ព័ន្ធក្រោយបញ្ចប់ការសាងសង់ ដើម្បីធានាប្រសិទ្ធភាព និងចីរភាពនៃហេដ្ឋារចនាសម្ព័ន្ធ។

• *ការវាយតម្លៃបញ្ចប់ការអនុវត្តគម្រោង*

ខ្វះយន្តការវាយតម្លៃក្រោយបញ្ចប់ការអនុវត្តគម្រោង សម្រាប់វាយតម្លៃប្រសិទ្ធភាពនៃគម្រោង ដែលជាមូលដ្ឋានក្នុងការរៀនសូត្រដកពិសោធន៍ សម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃការរៀបចំ និងអនុវត្តគម្រោងវិនិយោគក្រោយៗទៀត។

- *បញ្ហាប្រឈមផ្សេងៗ*
  - ធនធានមនុស្ស នៅមានកម្រិត ក្នុងការសិក្សាសមិទ្ធិលទ្ធភាពរបស់ក្រសួង-ស្ថាប័នជាម្ចាស់គម្រោង, ពិនិត្យវាយតម្លៃឯកសារសមិទ្ធិលទ្ធភាពនៃគម្រោង និងការពិនិត្យបញ្ជីប៉ាន់តម្លៃ និងប្លង់បច្ចេកទេសគ្រប់ជ្រុងជ្រោយ, និង
  - កង្វះប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈ ដែលជាមូលដ្ឋានក្នុងការពង្រឹងប្រសិទ្ធភាពក្នុងការរៀបចំផែនការគម្រោងវិនិយោគ ក៏ដូចជាការត្រួតពិនិត្យតម្លៃនៃគម្រោង។ល។

### ៤.៣.២. កាលានុវត្តភាព

ទន្ទឹមនឹងបញ្ហាប្រឈមខាងលើ ក្នុងបរិការណ៍នៃដំណាក់កាលអភិវឌ្ឍន៍ថ្មីរបស់កម្ពុជា, រាជរដ្ឋាភិបាលនឹងបង្កើតឱ្យបាននូវប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរួមមួយរបស់ជាតិ ដែលធានាបាននូវភាពឆ្លើយតប, ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាព ប្រកបដោយបរិយាប័ន្ន ដោយឈរលើមូលដ្ឋាននៃកាលានុវត្តភាពមួយចំនួន ដូចខាងក្រោម÷

- ឆន្ទៈមោះមុតរបស់រាជរដ្ឋាភិបាល ក្នុងការឈានឆ្ពោះទៅសម្រេចបង្គោលចរឆ្នាំ២០៣០ ប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ និងចក្ខុវិស័យឆ្នាំ២០៥០ ជាប្រទេសមានចំណូលខ្ពស់,
- កំណើននៃតម្រូវការហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងសេវាសាធារណៈ ទាំងបរិមាណ និងគុណភាព,
- កំណើនខ្ពស់នៃចំណូលថវិកាជាតិ ដែលនឹងជួយបង្កើនលទ្ធភាពរបស់រាជរដ្ឋាភិបាលក្នុងការពង្រីកទំហំនៃការវិនិយោគសាធារណៈ,
- ដៃគូអភិវឌ្ឍន៍ប្រពៃណី និងដៃគូអភិវឌ្ឍន៍ថ្មីៗ កំពុងពង្រីកទំហំហិរញ្ញប្បទានសហប្រតិបត្តិការ,
- ដៃគូអភិវឌ្ឍន៍ធំៗមួយចំនួន បាននិងកំពុងផ្តល់ការគាំទ្រជាអាទិភាពលើការពង្រឹងប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈនៅកម្ពុជា,
- ការអនុវត្តដោយជោគជ័យលើការដ្ឋានកែទម្រង់សំខាន់ៗទាំងបី រួមមាន÷ ១)- កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ២)- កម្មវិធីកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល, និង ៣)- កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, និង
- ការដាក់ចេញ និងការអនុវត្តយ៉ាងសកម្មនូវយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨- ២០២៥, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩- ២០២៥, យុទ្ធសាស្ត្រកៀរគរចំណូល២០១៩- ២០២៣, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩- ២០២៥, យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ២០១៩- ២០២៣, យុទ្ធសាស្ត្រ និងគោលនយោបាយពាក់ព័ន្ធផ្សេងទៀត នឹងរួមចំណែកបន្តលើកកម្ពស់ប្រសិទ្ធភាព និងភាពជោគជ័យបន្ថែមទៀតលើការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងពង្រឹងប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ។

# វិធានការជាយុទ្ធសាស្ត្រ

# ៥. វិធានការជាយុទ្ធសាស្ត្រ

ដើម្បីសម្រេចនូវចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ យុទ្ធសាស្ត្រគន្លឹះរបស់រាជរដ្ឋាភិបាល គឺការរៀបចំ និងដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្រ សំដៅបង្កើតប្រព័ន្ធរួមមួយរបស់ជាតិ សម្រាប់ពង្រឹងការគ្រប់គ្រងការវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន គ្រប់កម្រិតរដ្ឋបាលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និងអង្គភាពសាធារណៈប្រហាក់ប្រហែល ប្រកបដោយភាពគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡាគ្នាជាជំហានៗ ដែលរួមមាន÷

- ការចាប់ផ្តើមពីការពិនិត្យ និងកែសម្រួលនូវក្របខ័ណ្ឌគតិយុត្ត,
- ការកំណត់សមត្ថកិច្ចស្ថាប័ន និងការពង្រឹងយន្តការស្ថាប័ននៅតាមដំណាក់កាលនីមួយៗ នៃវដ្តគម្រោង,
- ការរៀបចំ និងដាក់ឱ្យអនុវត្តយន្តការគាំទ្រហិរញ្ញវត្ថុ, និង
- ការរៀបចំនិងដាក់ឱ្យអនុវត្តនីតិវិធីប្រតិបត្តិការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ។

ការឈានទៅបង្កើតប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ នឹងធ្វើឱ្យមានការប្រែប្រួលសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័នមួយចំនួន, ផ្លាស់ប្តូររបៀបរបបបំពេញការងារ, ព្រមទាំងត្រូវការបំពេញលក្ខខណ្ឌជាច្រើនថែមទៀត ដើម្បីឱ្យសំណើគម្រោងវិនិយោគសាធារណៈមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលចាំបាច់ទាមទារឱ្យគ្រប់ភាគីពាក់ព័ន្ធ ជាពិសេស ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាលត្រូវតែបុរេសកម្ម, សកម្ម, អន្តរសកម្ម និងម៉ឺងម៉ាត់ជាងមុន ដើម្បីមិនត្រឹមតែធានាថា គ្មានការរាំងស្ទះដល់ចលនាការអភិវឌ្ឍប្រទេសដោយសារការជាប់គាំងនៃគម្រោងវិនិយោគសាធារណៈនៅដំណាក់កាលណាមួយនោះទេ, តែថែមទាំងជួយលើកកម្ពស់ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាពនៃការវិនិយោគសាធារណៈឱ្យកាន់តែប្រសើរជាងមុនទៀតផង។ ក្នុងស្មារតីនេះ អភិក្រមនៃការអនុវត្ត ត្រូវតែធ្វើដោយប្រយ័ត្នប្រយែង, សន្សឹមៗ, ឈរលើគោលការណ៍ប្រាកដនិយម, ទន់ភ្លន់, និង «រៀនផង-ធ្វើផង»។

ក្នុងន័យនេះ រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្របន្ទាន់ចំពោះមុខ និងវិធានការជាយុទ្ធសាស្ត្ររយៈពេលមធ្យម ដូចខាងក្រោម÷

## ៥.១. វិធានការជាយុទ្ធសាស្ត្របន្ទាន់ចំពោះមុខ

ផ្អែកតាមនិន្នាការ និងការអនុវត្តជាសកល ព្រមទាំងបរិការណ៍ជាក់ស្តែងកម្ពុជា ដូចបានវិភាគខាងលើ រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្របន្ទាន់ចំពោះមុខមួយចំនួន ដូចខាងក្រោម÷

**១)- រៀបចំ និងដាក់ឱ្យអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ÷** ជាអនុក្រឹត្យគោល ដែលនឹងកំណត់នូវគោលការណ៍ជាសារវន្ត និងប្រព័ន្ធនៃការគ្រប់គ្រងការវិនិយោគសាធារណៈ ជាអាទិ៍ ដូចខាងក្រោម÷

- ❖ គោលការណ៍រួម សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន(ថវិកាជាតិ ថវិកាដៃគូអភិវឌ្ឍន៍ និងទុនវិនិយោគឯកជន) និងនៅគ្រប់កម្រិតរដ្ឋបាល (ថ្នាក់ជាតិ ថ្នាក់

ក្រោមជាតិ សហគ្រាសសាធារណៈ គ្រឹះស្ថានរដ្ឋបាលសាធារណៈ និងអង្គភាពសាធារណៈ ប្រហាក់ប្រហែល),

❖ អភិក្រម យន្តការស្ថាប័ន និងនីតិវិធីនៃការរៀបចំ និងគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ នៅគ្រប់ដំណាក់កាលនៃវដ្តគម្រោង ដោយពង្រឹងបន្ថែមនៅដំណាក់កាលនៃការធ្វើអាទិភាវូបនីយកម្ម, ផែនការនីយកម្ម, ការរៀបចំសំណើគម្រោង, សមាហរណកម្មថវិកានីយកម្ម, និងបុរេថវិកានីយកម្ម (ពិនិត្យនិងវាយតម្លៃលើសំណើគម្រោង, ជ្រើសរើសគម្រោងដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់, និងកំណត់ប្រភពហិរញ្ញប្បទាន), ថវិកានីយម្មគម្រោងវិនិយោគសាធារណៈ, និងការវាយតម្លៃក្រោយបញ្ចប់ការអនុវត្តគម្រោង។ មុខងារ ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័នជាម្ចាស់គម្រោង និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានដូចខាងក្រោម÷

- **ក្រសួង-ស្ថាប័ន ឬ អង្គភាពសាធារណៈដែលជាម្ចាស់គម្រោង** ត្រូវមានភារកិច្ចនិងទទួលខុសត្រូវលើការ÷ រៀបចំឯកសារទស្សនាទាន, ធ្វើអាទិភាវូបនីយកម្ម, ផែនការនីយកម្មការវិនិយោគសាធារណៈ, រៀបចំឯកសារសំណើគម្រោង (ត្រូវភ្ជាប់មកជាមួយនូវរបាយការណ៍សិក្សាសមិទ្ធិលទ្ធភាពគម្រោង និងរបាយការណ៍វាយតម្លៃគម្រោង), គ្រប់គ្រងការអនុវត្តគម្រោង, ព្រមទាំងរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគម្រោង និងរបាយការណ៍ក្រោយបញ្ចប់ការអនុវត្តគម្រោង។
- **បង្កើតយន្តការបុរេថវិកានីយកម្មការវិនិយោគសាធារណៈ** នៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់បំពេញមុខងារជាទ្វារបាលនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ពីគ្រប់ប្រភពហិរញ្ញប្បទានទាំងអស់ *ដែលមានភារកិច្ចសំខាន់ៗ ដូចខាងក្រោម÷*
  - រៀបចំ «គោលការណ៍ណែនាំស្តីពីការរៀបចំគម្រោង» ដែលដាក់ចេញនូវក្របខ័ណ្ឌ និងទិសដៅជាយុទ្ធសាស្ត្រនៃការរៀបចំសំណើគម្រោងវិនិយោគសាធារណៈ ឱ្យឆ្លើយតបនឹងតម្រូវការអាទិភាពនៃផែនការយុទ្ធសាស្ត្រតាមវិស័យ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ,
  - ពិនិត្យ និងវាយតម្លៃសំណើគម្រោង (លើកលែងតែគម្រោងវិនិយោគសាធារណៈរបស់សហគ្រាសសាធារណៈ, គ្រឹះស្ថានសាធារណៈរដ្ឋបាល, អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ) ដោយពិនិត្យផ្ទៀងផ្ទាត់លើតម្លៃគម្រោង, ហានិភ័យពាក់ព័ន្ធនឹងគម្រោង ព្រមទាំងដាក់ចេញនូវគោលការណ៍ និងវិធានការជាក់ស្តែងតាមការចាំបាច់ រួមមានការកំណត់ឡើងវិញនូវតម្លៃគម្រោង, សកម្មភាព ឬសមាសភាគនៃគម្រោង, យន្តការគ្រប់គ្រងគម្រោង និងការចាត់ចែងកិច្ចលទ្ធកម្មគម្រោងជាដើម ដើម្បីបង្ការ និងបញ្ចៀសហានិភ័យពាក់ព័ន្ធនានា សំដៅធានាប្រសិទ្ធភាព និងភាពជោគជ័យនៃការអនុវត្តគម្រោង។ ក្នុងករណីគម្រោងដែលមានភាពស្មុគស្មាញខ្លាំងខាងផ្នែកបច្ចេកទេស និងវេទយិតភាពខ្ពស់, ការពិនិត្យ និងវាយតម្លៃ អាចត្រូវបានធ្វើដោយក្រុមហ៊ុនកុងសុលតង់អន្តរជាតិ តាមការសម្រេចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, និង

- កំណត់ប្រភពហិរញ្ញប្បទាន សម្រាប់គម្រោងវិនិយោគសាធារណៈ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

❖ លក្ខខណ្ឌតម្រូវអប្បបរមា ដើម្បីឱ្យសំណើគម្រោងវិនិយោគសាធារណៈអាចទទួលបានការអនុម័តជាគម្រោង ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ជាគោលការណ៍ មានជាអាទិ៍÷

- សំណើគម្រោងវិនិយោគសាធារណៈទាំងអស់ ត្រូវតែភ្ជាប់មកជាមួយនូវឯកសារទស្សនាទានគម្រោង ឬរបាយការណ៍សិក្សាសមិទ្ធិលទ្ធភាព និងវាយតម្លៃគម្រោង លើកលែងតែប្រភេទគម្រោងដែលមានទំហំតូច សាមញ្ញ និងងាយអនុវត្ត ឬគម្រោងជួសជុល និងស្តារឡើងវិញបន្ទាន់ ឬមានវេទយិតភាពផ្នែកសន្តិសុខ និងសង្គមខ្ពស់។
- សំណើគម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលមានទំហំមធ្យម និងធំ, គម្រោងហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់, គម្រោងហេដ្ឋារចនាសម្ព័ន្ធនៅទីក្រុង ឬទីប្រជុំជន ត្រូវតែភ្ជាប់មកជាមួយនូវផែនការនគរូបនីយកម្ម, ផែនការមេតាមវិស័យ, ផែនការមេតាមភូមិសាស្ត្រ, ផែនការរំលោះថ្លៃដើមវិនិយោគ, របាយការណ៍វិភាគផលចំណេញសេដ្ឋកិច្ច, របាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម, ផែនការដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍, ព្រមទាំងលក្ខខណ្ឌមួយចំនួនផ្សេងទៀត តាមការចាំបាច់។

❖ **គោលការណ៍អប្បបរមា** សម្រាប់ការជ្រើសរើស និងថវិកានីយកម្មគម្រោងវិនិយោគសាធារណៈ រួមមាន÷

- **គោលការណ៍អប្បបរមារួម**
  - គោលការណ៍សនិទានកម្ម÷ គម្រោងត្រូវតែមានភាពចាំបាច់ចំពោះសេដ្ឋកិច្ច, សង្គម, បរិស្ថាន ឆ្លើយតបនឹងតម្រូវការអាទិភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, យុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ, ផែនការមេតាមវិស័យ, ផែនការមេតាមភូមិសាស្ត្រ ព្រមទាំងគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធផ្សេងទៀតរបស់រាជរដ្ឋាភិបាល,
  - គោលការណ៍ផលសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷ គម្រោងត្រូវតែបង្ហាញអំពីផលចំណេញផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលទទួលបានពីការវិនិយោគ។ ទោះជាយ៉ាងណា, ការវិនិច្ឆ័យលើគោលការណ៍នេះ ក៏ត្រូវឈរលើមូលដ្ឋាននៃការថ្លឹងថ្លែងអំពីសារៈសំខាន់ និងចាំបាច់នៃសេវាសាធារណៈ និងគោលការណ៍សមធម៌សង្គម សម្រាប់គម្រោងវិនិយោគសាធារណៈដែលមានចរិតជាអន្តរាគមន៍សង្គម,
  - គោលការណ៍ជម្រើសប្រសើរបំផុត÷ ត្រូវតែជាគម្រោងដែលមានឧត្តមភាពប្រៀបធៀប, ផ្តល់ផលសេដ្ឋកិច្ច និងសង្គម ខ្ពស់ជាងគេ ធៀបនឹងជម្រើសគម្រោងដទៃផ្សេងទៀត,
  - គោលការណ៍ភាពអាចទ្រទ្រង់បាននៃថវិកា,
  - គោលការណ៍ភាពអាចអនុវត្តបាន, និង
  - គោលការណ៍ភាពរួចរាល់សម្រាប់ការចាប់ផ្តើមអនុវត្តគម្រោង។

- **គោលការណ៍បន្ថែមដោយឡែក៖** បន្ថែមលើគោលការណ៍រួមនៃការគ្រប់គ្រងការវិនិយោគសាធារណៈ ត្រូវមានគោលការណ៍បន្ថែមដោយឡែក សម្រាប់ប្រភេទគម្រោងវិនិយោគសាធារណៈមួយចំនួន ដូចខាងក្រោម៖
  - ចំពោះគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយឥណទានពាណិជ្ជកម្ម៖ ត្រូវបានអនុញ្ញាត សម្រាប់តែគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងត្រូវមានផលសេដ្ឋកិច្ច និងផលចំណេញហិរញ្ញវត្ថុខ្ពស់ តាមតម្រូវការជាក់ស្តែងរបស់កម្ពុជា តាមអត្រាដែលនឹងកំណត់ដោយអនុក្រឹត្យគោល។
  - ចំពោះគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទាន ដោយការធ្វើឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរដ្ឋ៖ ជាគោលការណ៍ ត្រូវអនុវត្តតាមគោលការណ៍រួមនៃការគ្រប់គ្រងការវិនិយោគសាធារណៈ។ ដោយឡែក, ចំពោះករណីស្នើសុំអនុវត្តដោយឡែកតាមអភិក្រម «ប្រគល់សោរដល់ដៃ» ត្រូវ៖ ១)- គោរពតាមគោលការណ៍តម្លៃស្មើគ្នា ទៅនឹងតម្លៃទីផ្សារនៃទ្រព្យសម្បត្តិរដ្ឋដែលត្រូវធ្វើឯកជនភាវូបនីយកម្ម និង ២)- ធ្វើឡើងតាមរយៈយន្តការ «សម្តេចតេជោនាយករដ្ឋមន្ត្រី ជាអគ្គមេបញ្ជាការតែមួយ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជា សេនាធិការតែមួយលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ» អនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ បន្ថែមលើនេះ, ត្រូវពង្រឹងភាពម៉ឺងម៉ាត់នៃការអនុវត្តមុខងារជាទ្វារបាលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមុខងារត្រួតពិនិត្យ និងវាយតម្លៃការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់ក្រសួង-ស្ថាប័ន ជំនាញ។
  - ចំពោះគម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានចម្រុះ៖ ត្រូវមានភាពទន់ភ្លន់ចំពោះការអនុវត្តគោលការណ៍ផលសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធានា និងលើកកម្ពស់ភាពទាក់ទាញទុនវិនិយោគបន្ថែមពីវិស័យឯកជន សម្រាប់បំពេញតម្រូវការវិនិយោគសាធារណៈសរុប ព្រមទាំងឆ្លើយតបទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងបរិស្ថាន ប្រកបដោយបរិយាប័ន្ន។

❖ គោលការណ៍ណែនាំស្តីពីការសិក្សា និងការវាយតម្លៃសមិទ្ធិលទ្ធភាព និងនិរន្តរភាពនៃគម្រោង។

**២)- ពង្រឹងគុណភាព ប្រសិទ្ធភាពអនុវត្ត និងភាពផ្សារភ្ជាប់រវាងផែនការវិនិយោគសាធារណៈ ជាមួយនឹងថវិកានីយកម្មការវិនិយោគសាធារណៈ តាមរយៈ៖**

- ការពង្រឹងគុណភាពនៃការធ្វើអាទិភាវូបនីយកម្មការវិនិយោគសាធារណៈ ឱ្យឆ្លើយតបចំគោលបំណងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល តាមរយៈការដាក់ឱ្យអនុវត្ត «គោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណកម្ម និងអាទិភាវូបនីយកម្មគម្រោង»,
- ការពង្រឹងការធ្វើសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជាមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ស្របតាមទិសដៅនៃយុទ្ធសាស្ត្រកែ

ទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩ - ២០២៥, និងលើកកម្ពស់ប្រសិទ្ធភាពនៃទំនាក់ទំនងប្រទាក់ក្រឡា និងបំពេញឱ្យគ្នាជាមួយកម្មវិធីថ្នាក់ជាតិដោយការតម្រឹមកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាមួយផែនការវិនិយោគសាធារណៈរបស់ជាតិ។

**៣)- ធ្វើសមាហរណកម្មថវិការវាងប្រភពថវិការដ្ឋ** ជាមួយនឹងថវិកាដៃគូអភិវឌ្ឍន៍ និងរវាងថវិកាចរន្ត ជាមួយនឹងថវិកាមូលធន តាមរយៈការពង្រីកវិសាលភាពគ្របដណ្ដប់នៃក្របខ័ណ្ឌថវិការយៈពេលមធ្យម, ផែនការយុទ្ធសាស្ត្រថវិកា, និងថវិកាប្រចាំឆ្នាំ សំដៅធានាប្រសិទ្ធភាពនៃគម្រោងវិនិយោគសាធារណៈ និងចីរភាពនៃការប្រើប្រាស់ និងថែទាំហេដ្ឋារចនាសម្ព័ន្ធដែលបានសាងសង់។

**៤)- កែលម្អដំណើរការប្រឹក្សាយោបល់ និងការសម្របសម្រួលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ** ក្នុងដំណាក់កាលនៃការធ្វើផែនការយុទ្ធសាស្ត្រថវិកា ដើម្បីសម្រេចបានដំណើរការធ្វើសមាហរណកម្មផែនការវិនិយោគនៅក្នុងផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត។ ដំណើរការប្រឹក្សាយោបល់ និងការសម្របសម្រួលនេះ នឹងត្រូវធ្វើឡើងដោយ «**គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**» ដែលដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត មុននឹងដាក់ជូនក្រុមប្រឹក្សារាជធានី ខេត្តត្រួតពិនិត្យ និងអនុម័ត រួចបញ្ជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**៥)- រៀបចំ និងដាក់ឱ្យអនុវត្តនីតិវិធីគ្រប់គ្រងប្រតិបត្តិការគម្រោងវិនិយោគសាធារណៈ** តាមប្រភពហិរញ្ញប្បទាន ដែលនឹងត្រូវចែងលម្អិតអំពីយន្តការនិងសមត្ថកិច្ចស្ថាប័ន និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការគម្រោងវិនិយោគសាធារណៈ នៅគ្រប់ដំណាក់កាលទាំងអស់នៃវដ្តគម្រោង។

**៦)- រៀបចំ និងដាក់ឱ្យអនុវត្តគោលការណ៍ និងនីតិវិធីគ្រប់គ្រងការប្រើប្រាស់ និងការថែទាំហេដ្ឋា-រចនាសម្ព័ន្ធ។**

**៧)- រៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមនៃគម្រោងវិនិយោគសាធារណៈ** ដើម្បីកត់ត្រា និងបូកសរុបចំណាយ ព្រមទាំងតាមដានការអនុវត្តគម្រោងវិនិយោគសាធារណៈទាំងអស់ ពីគ្រប់ប្រភពហិរញ្ញប្បទាន។

**៨)- រៀបចំ និងដាក់ឱ្យអនុវត្តយន្តការគាំទ្រហិរញ្ញវត្ថុ ដើម្បីសិក្សាសមិទ្ធិលទ្ធភាព និងរៀបចំគម្រោងលម្អិត។**

**៩)- រៀបចំ និងដាក់ឱ្យអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស** សម្រាប់ការគ្រប់គ្រងការវិនិយោគសាធារណៈ (ឧបសម្ព័ន្ធទី៣)។

## ៥.២. វិធានការជាយុទ្ធសាស្ត្ររយៈពេលមធ្យម

ឈរលើមូលដ្ឋាននៃការអនុវត្តវិធានការជាយុទ្ធសាស្ត្របន្ទាន់ចំពោះមុខ បន្ទាប់ពីអនុក្រឹត្យស្ដីពីការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត ត្រូវបានអនុម័ត, ក្នុងរយៈពេលមធ្យម រាជរដ្ឋាភិបាលនឹង÷

**១)- សិក្សា និងពិនិត្យឡើងវិញលើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨** ព្រមទាំងពិនិត្យលទ្ធភាពរៀបចំបទប្បញ្ញត្តិបំពេញបន្ថែមមួយចំនួន ដែលកំណត់អំពីគោលការណ៍, អភិក្រម, យន្តការ, និងសមត្ថកិច្ចស្ថាប័ន

ក្នុងការគ្រប់គ្រងការវិនិយោគសាធារណៈ ដើម្បីឈានទៅអនុវត្តបានពេញលេញតាមវិធានការជាយុទ្ធសាស្ត្រដែលបានដាក់ចេញ ក្រោមយុទ្ធសាស្ត្រនេះ ប្រកបដោយប្រសិទ្ធភាព,

**២)- ពិនិត្យឡើងវិញ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្ត** សម្រាប់បន្តពង្រឹងប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព និងចីរភាពនៃការអនុវត្តគម្រោងវិនិយោគសាធារណៈ,

**៣)- កែសម្រួលគោលការណ៍ណែនាំស្តីពីការគ្រប់គ្រង និងអនុវត្តគម្រោងវិនិយោគសាធារណៈ** ពីគ្រប់ប្រភពហិរញ្ញប្បទាន ទាំងថ្នាក់ជាតិ និងទាំងថ្នាក់ក្រោមជាតិ ឱ្យស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន, និង

**៤)- ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈ និងផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស** សម្រាប់ការគ្រប់គ្រងការវិនិយោគសាធារណៈ។

ដើម្បីគាំទ្រការអនុវត្តវិធានការជាយុទ្ធសាស្ត្រខាងលើប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, និងគណនេយ្យភាព, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងឋានៈជាសេនាធិការរបស់រាជរដ្ឋាភិបាល ត្រូវទទួលបន្ទុកជាស្ថាប័ននាំមុខ ក្នុងការសម្របសម្រួលលើការអនុវត្តផែនការសកម្មភាព ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី២។

# ការត្រួតពិនិត្យតាមដាន
# និងការវាយតម្លៃលើការ
# អនុវត្តវិធានការជាយុទ្ធសាស្ត្រ

# ៦. ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការអនុវត្តវិធានការជាយុទ្ធសាស្ត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចសម្របសម្រួលការអនុវត្តប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយ-តម្លៃការអនុវត្តវិធានការជាយុទ្ធសាស្ត្រ ដូចខាងក្រោម÷

*ប្រព័ន្ធរបាយការណ៍÷* ផែនការសកម្មភាពដែលបានកំណត់នៅក្នុងឧបសម្ព័ន្ធទី១ នឹងត្រូវដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពរួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (CAP ឬ GDAP ឬ MAP) ដែលជាកម្មវត្ថុនៃការរៀបចំអនុវត្តរបស់អគ្គនាយកដ្ឋាន/អង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ។ ក្នុងន័យនេះ, អគ្គនាយកដ្ឋាន/អង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវផ្តល់របាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ស្តីពីការរៀបចំ និងការអនុវត្តផែនការសកម្មភាព សម្រាប់អនុវត្តវិធានការជាយុទ្ធសាស្ត្រពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួន ជូនអគ្គលេខាធិការដ្ឋានគណៈ-កម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីបូកសរុប និងរាយការណ៍ជូនគណៈកម្មការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

*យន្តការដោះស្រាយបញ្ហាប្រឈម÷* គណៈកម្មការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានភារកិច្ចពិនិត្យ និងសម្រេចដាក់ចេញនូវវិធានការចាំបាច់នានា ដើម្បីដោះស្រាយបញ្ហាប្រឈមដែលបានកើតឡើងក្នុងពេលអនុវត្តវិធានការជាយុទ្ធសាស្ត្រ។ ក្នុងករណីមានវេទយិតភាព, ត្រូវស្នើសុំការសម្រេចពីគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនាយករដ្ឋមន្ត្រី។

*យន្តការត្រួតពិនិត្យតាមដាន និងវាយតម្លៃអំពីវឌ្ឍនភាពជាប្រចាំ÷* អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានភារកិច្ចតាមដាន, ត្រួតពិនិត្យ, និងវាយតម្លៃ លើវឌ្ឍនភាពនៃការអនុវត្តវិធានការជាយុទ្ធសាស្ត្រ និងវិធានការដោះស្រាយបញ្ហាប្រឈម ដែលបានដាក់ចេញ និងរាយការណ៍ជូនគណៈកម្មការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

# សេចក្តីសន្និដ្ឋាន

# ៧. សេចក្តីសន្និដ្ឋាន

ជារួម, ក្នុងបរិការណ៍ថ្មីនៃការអភិវឌ្ឍរបស់កម្ពុជា រាជរដ្ឋាភិបាលពិនិត្យឃើញថា ការដាក់ឱ្យអនុវត្តពេញលេញ និងប្រកបដោយប្រសិទ្ធភាពនូវប្រព័ន្ធរួម សម្រាប់គ្រប់គ្រងការវិនិយោគសាធារណៈ ពិតជាមានសារៈសំខាន់ក្នុងចលនាការនៃការបន្តជំរុញគាំទ្រកិច្ចអភិវឌ្ឍសេដ្ឋកិច្ច-សង្គមក្នុងល្បឿនលឿន ជាពិសេស ការឆ្លើយតបបានគ្រប់គ្រាន់ទាំងបរិមាណ និងទាំងប្រសិទ្ធភាពនៃសេវាសាធារណៈ ចំពោះតម្រូវការប្រើប្រាស់របស់ប្រជាជន។

ជាការពិត, យុទ្ធសាស្ត្រនេះ គឺជាផែនទីបង្ហាញផ្លូវ សម្រាប់អភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងជាសេចក្តីសម្រេចជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលលើការកំណត់វិស័យអាទិភាព សម្រាប់គម្រោងវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន។ ដូច្នេះ ដើម្បីឈានដល់ការអនុវត្តពេញលេញនូវប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរួម នៅមុនដំណាច់ឆ្នាំ២០២៥ រាជរដ្ឋាភិបាលត្រូវបន្តខិតខំរៀបចំក្របខ័ណ្ឌគតិយុត្ត, នីតិវិធីគ្រប់គ្រងប្រតិបត្តិការ, កំណត់យន្តការស្ថាប័ន, បង្កើតយន្តការគាំទ្រហិរញ្ញវត្ថុ, និងអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្សចាំបាច់ ដូចដែលបានណែនាំ និងដាក់ចេញក្នុងវិធានការជាយុទ្ធសាស្ត្រនៃឯកសារយុទ្ធសាស្ត្រនេះ។

រាជរដ្ឋាភិបាល ចាត់ទុកយុទ្ធសាស្ត្រនេះ ជាឯកសាររស់ ដែលអាចនឹងត្រូវបានកែសម្រួលជាយថាហេតុ ដើម្បីធានាសង្គតិភាពចំពោះវឌ្ឍនាការនៃបរិការណ៍ជាក់ស្តែងនៅកម្ពុជា នាពេលខាងមុខ។ ទន្ទឹមនេះ, រាជរដ្ឋាភិបាលសង្ឃឹមយ៉ាងមុតមាំថា ការអនុវត្តដោយជោគជ័យនូវ **«យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥»** នឹងរួមចំណែក÷ ១)- បង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង ដែលជាមូលដ្ឋានគ្រឹះក្នុងការធានាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងបរិយាប័ន្ន ឆ្ពោះទៅសម្រេចបង្គោលចរឆ្នាំ២០៣០ និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ និង ២)- ពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ តាមរយៈនៃការពង្រឹងសមត្ថភាពក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ លើភាពអាចប៉ាន់ប្រមាណបាននៃកាតព្វកិច្ចបំណុលជាយថាហេតុរបស់រដ្ឋ។

ក្នុងន័យនេះ, រាជរដ្ឋាភិបាលប្រគល់ភារកិច្ចជូន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទទួលបន្ទុកជាស្ថាប័ននាំមុខក្នុងការសម្របសម្រួលលើការអនុវត្ត **«យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥»** ដោយត្រូវមានការចូលរួមផ្តល់កិច្ចសហប្រតិបត្តិការពេញលេញប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ពីសំណាក់ក្រសួង-ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល៕

# សន្ទានុក្រម

# សទ្ទានុក្រម
# សម្រាប់ប្រើប្រាស់ក្នុង
# យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ: ២០១៩ - ២០២៥

**ការកែសម្រួលគម្រោង** (Project Adjustment)

សំដៅដល់ដំណើរការនៃការកែសម្រួលផ្នែកណាមួយនៃគម្រោង ដែលបានអនុម័តរួចហើយ ជាអាទិ៍÷ ការកែសម្រួលតម្លៃ,វិសាលភាព,សកម្មភាព,ឬ រយៈពេលនៃការអនុវត្តគម្រោងជាដើម។

**ការវាយតម្លៃសំណើគម្រោង** (Project Appraisal)

សំដៅដល់ដំណើរការវាយតម្លៃលើទិដ្ឋភាពសំខាន់ៗនៃសំណើគម្រោង ជាអាទិ៍÷ បច្ចេកទេស, តម្លៃ, ហានិភ័យ, ផលប្រយោជន៍សេដ្ឋកិច្ចនិងសង្គម, ហេតុប៉ះពាល់បរិស្ថាននិងសង្គម, និងថវិកាជាដើម។

**ការសិក្សាសមិទ្ធិលទ្ធភាព** (Feasibility Study)

សំដៅដល់ការសិក្សាស៊ីជម្រៅលើសំណើគម្រោង ដោយរួមបញ្ចូលការវិភាគលើទិដ្ឋភាពពាក់ព័ន្ធ រួមមាន÷ បច្ចេកទេស, តម្លៃ, ហានិភ័យ, សេដ្ឋកិច្ច, ហិរញ្ញវត្ថុ, ច្បាប់, ហេតុប៉ះពាល់បរិស្ថាននិងសង្គម, ភាពអាចទ្រទ្រង់បាននៃថវិកា ព្រមទាំងយន្តការនិងសមត្ថភាពស្ថាប័ន សម្រាប់គ្រប់គ្រងនិងតាមដានការអនុវត្តគម្រោង ដោយត្រូវគោរពតាមគោលការណ៍ណែនាំលម្អិត និងនីតិវិធីរៀបចំ និងគ្រប់គ្រងប្រតិបត្តិការជាធរមាន។

**កិច្ចសន្យាប្រគល់សោរដល់ដៃ** (Turnkey Contract)

សំដៅដល់កិច្ចសន្យា ដែលសម្បទានិកទទួលបានសិទ្ធិចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ តាមរយៈការធ្វើឯកជនភាវូបនីយកម្ម ដើម្បីទទួលខុសត្រូវក្នុងការចាត់ចែង, រៀបចំ, និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ឱ្យបានរួចរាល់សម្រាប់ប្រតិបត្តិការ មុននឹងប្រគល់ជូនភាគីរាជរដ្ឋាភិបាល។

**ទ្វារបាលកិច្ច** (Gatekeeping)

សំដៅដល់មុខងាររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការពិនិត្យ និងវាយតម្លៃលើសំណើគម្រោង ការធ្វើអាទិភាវូបនីយកម្ម ការជ្រើសរើស និងថវិកានីយកម្ម ព្រមទាំងការតាមដាននិងត្រួតពិនិត្យលើការអនុវត្តគម្រោង។

**ភាពជាដៃគូរវាងរដ្ឋនិងឯកជន** (Public Private Partnership - PPP)

សំដៅដល់ការព្រមព្រៀងគ្នារវាងភាគីរដ្ឋ និងដៃគូឯកជនមួយ ឬ ច្រើន ដើម្បីស្តារ សាងសង់ ជួសជុល គ្រប់គ្រងប្រតិបត្តិការ និង/ ឬ ថែទាំលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ទ្រព្យសម្បត្តិគម្រោង ឬ ដើម្បីផ្តល់សេវាសាធារណៈនៅក្នុងអំឡុងពេលកំណត់ណាមួយ ដោយដៃគូឯកជនត្រូវធ្វើការវិនិយោគ ទទួលបន្ទុកហានិភ័យ និងទទួលអត្ថប្រយោជន៍ ដោយផ្អែកលើសមិទ្ធកម្ម និងដោយអនុលោមតាមលក្ខខណ្ឌ ដែលមានចែងក្នុងកិច្ចសន្យាភាពជាដៃគូរវាងរដ្ឋនិងឯកជន។

**ឯកសារទស្សនាទានគម្រោង (Project Concept Note)**

សំដៅដល់ឯកសារទស្សនាទានបឋម ដែលបញ្ជាក់អំពីសនិទានកម្ម គោលដៅនៃគម្រោង តម្រូវការនិងអាទិភាពនៃគម្រោង ការផ្សារភ្ជាប់ទៅនឹងគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយតាមវិស័យ។

ឧបសម្ព័ន្ធ ២

# ផែនការសកម្មភាពរួម
# សម្រាប់អនុវត្តយុទ្ធសាស្ត្រ
# ស្តីពីការកែទម្រង់ប្រព័ន្ធ
# គ្រប់គ្រងការវិនិយោគសាធារណៈ

# ផែនការសកម្មភាពរួម
# សម្រាប់អនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ

| ល.រ. | សកម្មភាព | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|
| | ឆ្នាំ២០១៩ - ២០២១ | ឆ្នាំ២០២២ - ២០២៥ | |
| ១ | | សិក្សានិងពិនិត្យឡើងវិញលើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨ | ក.ស.ហ.វ<br>ក្រសួង-ស្ថាប័ន |
| ២ | រៀបចំ និងដាក់ឱ្យអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ | ពិនិត្យឡើងវិញអនុក្រឹត្យស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ និងកែសម្រួល ក្នុងករណីចាំបាច់ | ក.ស.ហ.វ(អ.គ.ហ)<br>អគ្គនាយកដ្ឋានពាក់ព័ន្ធ<br>ក្រសួង-ស្ថាប័ន |
| ៣ | ពង្រឹងការអនុវត្ត «គោលការណ៍ស្តីពីការកំណត់អត្តសញ្ញាណកម្ម និងអាទិ-ភាវូបនីយកម្មគម្រោង» | បន្តពង្រឹងការអនុវត្ត «គោល-ការណ៍ស្តីពីការកំណត់អត្តសញ្ញា-ណកម្ម និងអាទិភាវូបនីយកម្មគម្រោង» | ក្រសួងផែនការ<br>ក្រសួង-ស្ថាប័ន |
| ៤ | រៀបចំ និងដាក់ឱ្យអនុវត្ត «គោលការណ៍ណែនាំស្តីពីការរៀបចំសំណើគម្រោង» | ពិនិត្យឡើងវិញនូវការអនុវត្ត «គោលការណ៍ណែនាំស្តីពីការរៀបចំសំណើគម្រោង» និងកែសម្រួលក្នុងករណីចាំបាច់ | ក.ស.ហ.វ<br>ក្រសួង-ស្ថាប័ន |
| ៥ | ពង្រឹងការធ្វើសមាហរណកម្មកម្មវិធីវិនិ-យោគ ៣ ឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | ពិនិត្យឡើងវិញលើប្រសិទ្ធភាពនៃការការធ្វើសមាហរណកម្មកម្មវិធីវិនិយោគនេះ និងកែសម្រួលក្នុងករណីចាំបាច់ | ក.ស.ហ.វ(អ.ហ.ក) |
| ៦ | ពង្រឹង និងកែសម្រួលការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដើម្បីធ្វើសមាហរណកម្មថវិកានីយកម្មពីគ្រប់ប្រភព និងពីគ្រប់មុខសញ្ញាចំណាយ | ពិនិត្យឡើងវិញលើប្រសិទ្ធភាពនៃការអនុវត្តយន្តការរៀបចំផែនការយុទ្ធសាស្ត្រថវិកានេះ និងកែសម្រួលក្នុងករណីចាំបាច់ | ក.ស.ហ.វ (អ.ថ)<br>ក្រសួង-ស្ថាប័ន |

| | | | |
|---|---|---|---|
| ៧ | បង្កើតយន្តការបុរេថវិកានីយកម្មការវិនិយោគសាធារណៈ សម្រាប់បំពេញមុខងារទ្វារបាលកិច្ចនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ | ពិនិត្យឡើងវិញលើការអនុវត្ត និងកែសម្រួលក្នុងករណីចាំបាច់ | ក.ស.ហ.វ<br>ក្រសួង-ស្ថាប័ន |
| ៨ | រៀបចំ និងដាក់ឱ្យអនុវត្តនីតិវិធីគ្រប់គ្រងប្រតិបត្តិការគម្រោងវិនិយោគសាធារណៈ តាមប្រភពហិរញ្ញប្បទាន | ពិនិត្យឡើងវិញលើការអនុវត្ត និងកែសម្រួលក្នុងករណីចាំបាច់ | ក.ស.ហ.វ (អ.ថ)<br>ក.ស.ហ.វ(អ.ហ.ក)<br>ក.ស.ហ.វ(អ.ស.ប)<br>ក.ស.ហ.វ(ក.វ.ក)<br>ក្រសួង-ស្ថាប័ន |
| ៩ | រៀបចំបទដ្ឋានគតិយុត្តដូចមានចែងក្នុង «ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០» | ពិនិត្យឡើងវិញលើការអនុវត្ត និងកែសម្រួលក្នុងករណីចាំបាច់ | ក.ស.ហ.វ (អ.វ.ជ)<br>ក្រសួង-ស្ថាប័ន |
| ១០ | រៀបចំ និងដាក់ឱ្យអនុវត្តគោលការណ៍ និងនីតិវិធីគ្រប់គ្រងការប្រើប្រាស់ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ | ពិនិត្យឡើងវិញលើការអនុវត្ត និងកែសម្រួលក្នុងករណីចាំបាច់ | ក.ស.ហ.វ (អ.ថ)<br>ក.ស.ហ.វ(អ.ហ.ក)<br>ក្រសួង-ស្ថាប័ន |
| ១១ | រៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈ | ពិនិត្យឡើងវិញលើការអនុវត្ត និងកែសម្រួលក្នុងករណីចាំបាច់ | ក.ស.ហ.វ<br>ក្រសួង-ស្ថាប័ន |
| ១២ | រៀបចំ និងដាក់ឱ្យអនុវត្តយន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់សិក្សាសមិទ្ធលទ្ធភាព និងរៀបចំគម្រោង | ពិនិត្យឡើងវិញលើការអនុវត្ត និងកែសម្រួលក្នុងករណីចាំបាច់ | ក.ស.ហ.វ<br>ក្រសួង-ស្ថាប័ន |
| ១៣ | រៀបចំ និងដាក់ឱ្យអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស | តាមដានការអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស | ក.ស.ហ.វ(វ.ស.ហ)<br>ក្រសួង-ស្ថាប័ន |

<u>បញ្ជាក់</u>÷ អគ្គនាយកដ្ឋាន/អង្គភាពពាក់ព័ន្ធនៃ ក.ស.ហ.វ. និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំផែនការសកម្មភាពលម្អិត សម្រាប់អនុវត្តវិធានការជាយុទ្ធសាស្ត្រនៃ «**យុទ្ធសាស្ត្រស្តីពីការកែទម្រង់ការគ្រប់គ្រងវិនិយោគសាធារណៈ ២០១៩ - ២០២៥**» តាមសមត្ថកិច្ចរៀងៗខ្លួន។

ឧបសម្ព័ន្ធ ៣

# ផែនការអភិវឌ្ឍន៍
# សមត្ថភាពស្ថាប័ន និងធនធានមនុស្ស
# សម្រាប់ការ
# គ្រប់គ្រងការវិនិយោគសាធារណៈ

# មាតិកា

**១. សេចក្តីផ្តើម** ............................................ ១
**២. គោលបំណង** ............................................ ២
**៣. គោលដៅ** ............................................ ២
**៤. វិសាលភាព** ............................................ ២
**៥. ការវិភាគចំណុចខ្លាំង ចំណុចខ្សោយ កាលានុវត្តភាព និងការគំរាមកំហែង** ............................................ ២
៥.១ ចំណុចខ្លាំង ............................................ ២
៥.២ ចំណុចខ្សោយ ............................................ ៣
៥.៣ កាលានុវត្តភាព ............................................ ៣
៥.៤ ការគំរាមកំហែង ............................................ ៣
**៦. ផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ២០១៩-២០២៥** ..... ៤
៦.១ ផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍសមត្ថភាពស្ថាប័ន ............................................ ៤
៦.២ ផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស ............................................ ៤
**៧. គម្រោងប៉ាន់ស្មានថវិកាចំណាយសម្រាប់ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស** .......... ៦

# ផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ការគ្រប់គ្រងការវិនិយោគសាធារណៈ

## ១. សេចក្តីផ្តើម

ប្រសិទ្ធភាពនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ បានរួមចំណែកដ៏សំខាន់ក្នុងការសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន ក្នុងរង្វង់ **៧,៧ ភាគរយ** នារយៈពេលជាងពីរទសវត្សរ៍កន្លងមក ព្រមទាំងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនបានជាង **១ ភាគរយ** ក្នុងមួយឆ្នាំ។

ក្នុងបរិការណ៍ដែលសេដ្ឋកិច្ចកាន់តែមានការរីកចម្រើន ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈនៅកម្ពុជា ក៏កាន់តែមានភាពស្មុគស្មាញជាងមុនផងដែរ ដែលកត្តានេះ ទាមទារឱ្យរដ្ឋាភិបាលត្រូវបន្តកិច្ចខិតខំថែមទៀតក្នុងការពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្សនៅតាមក្រសួង-ស្ថាប័នពាក់ព័ន្ធ។

តាមរយៈកិច្ចខិតខំប្រឹងប្រែងនារយៈកាលកន្លងមក រាជរដ្ឋាភិបាលបានអនុម័ត និងដាក់ឱ្យអនុវត្តនូវផែនការសំខាន់ៗចំនួន ២ ពាក់ព័ន្ធនឹងការពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្សក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងការវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស និងតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន រួមមាន÷ ១)- ផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្សសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ និង ២)- ផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ។ ទន្ទឹមនេះ នៅតាមក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួន ក៏មានផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្សផ្ទៃក្នុង រៀងៗខ្លួនផងដែរ។

ថ្វីត្បិតតែកសាងបាននូវផែនការមួយចំនួនទាំងនេះហើយក្តី ក៏នៅពុំទាន់គ្រប់គ្រាន់ដែលអាចឆ្លើយតបបានទៅនឹងបរិការណ៍ជាក់ស្តែងរបស់កម្ពុជា និងស្របតាមឧត្តមានុវត្តជាអន្តរជាតិនៅឡើយទេ ដូចនេះ រាជរដ្ឋាភិបាលមានភាពចាំបាច់ត្រូវរៀបចំផែនការពង្រឹងសមត្ថភាពរួមមួយ ដែលគ្របដណ្តប់លើការវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន (ទាំងពីថវិកាជាតិ ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ និងទុនវិនិយោគឯកជនតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន), និងនៅគ្រប់កម្រិតរដ្ឋបាល (ទាំងថ្នាក់ជាតិ ទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និងអង្គភាពសាធារណៈប្រហាក់ប្រហែល) ដើម្បីបំពេញបន្ថែមឱ្យផែនការដែលបានរៀបចំកន្លងមក សំដៅធានាប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាព នៃការគ្រប់គ្រងវិនិយោគសាធារណៈ។

ផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ការគ្រប់គ្រងការវិនិយោគសាធារណៈ គឺជាឧបករណ៍ដ៏មានសារៈសំខាន់មួយ និងមិនអាចខ្វះបានសម្រាប់គាំទ្រដល់ការអនុវត្ត **«យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ - ២០២៥»** ។ ផែនការនេះ នឹងត្រូវប្រើប្រាស់ជាត្រីវិស័យចង្អុលទិសអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស ក្នុងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ សំដៅរួមចំណែកដល់ការបង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា។

ផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ការគ្រប់គ្រងការវិនិយោគសាធារណៈ ជា "**ឯកសាររស់**" ដែលអាចនឹងត្រូវបានត្រួតពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្ម តាមការចាំបាច់។

## ២. គោលបំណង

ផែនការនេះ មានគោលបំណងពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្សពាក់ព័ន្ធនឹងការគ្រប់គ្រងការវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន (ទាំងពីថវិកាជាតិ ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ និងទុនវិនិយោគឯកជនតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន), និងនៅគ្រប់កម្រិតរដ្ឋបាល (ទាំងថ្នាក់ជាតិ ទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និងអង្គភាពសាធារណៈប្រហាក់ប្រហែល) ដើម្បីធានាប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព គណនេយ្យភាព និងចីរភាព នៃការគ្រប់គ្រងវិនិយោគសាធារណៈ សំដៅរួមចំណែកដល់ការបង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា។

## ៣. គោលដៅ

ផែនការនេះ មានគោលដៅដាក់ចេញនូវផែនការសកម្មភាពរួម ក្នុងការពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស របស់ក្រសួង-ស្ថាប័នពាក់ព័ន្ធនឹងការគ្រប់គ្រងការវិនិយោគសាធារណៈ។

## ៤. វិសាលភាព

ផែនការនេះ មានវិសាលភាពគ្របដណ្តប់លើការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្សរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធនឹងការគ្រប់គ្រងការវិនិយោគសាធារណៈ។

## ៥. ការវិភាគចំណុចខ្លាំង ចំណុចខ្សោយ កាលានុវត្តភាព និងការគំរាមកំហែង

### ៥.១ ចំណុចខ្លាំង

ក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងការវិនិយោគសាធារណៈកម្ពុជាបច្ចុប្បន្ន រាជរដ្ឋាភិបាលយល់ឃើញថា មានចំណុចខ្លាំង ដូចខាងក្រោម÷

- រាជរដ្ឋាភិបាលមានរបៀបវារៈគោលនយោបាយច្បាស់លាស់ ក្នុងការបន្តកសាង និងអភិវឌ្ឍប្រទេស ដូចមានបញ្ជាក់ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលបានផ្តល់អាទិភាពទី១ លើមនុស្ស។
- រាជរដ្ឋាភិបាលមានឆន្ទៈគោលនយោបាយខ្ពស់ក្នុងការបន្តសកម្មអនុវត្តនូវកម្មវិធីកែទម្រង់គន្លឹះៗទាំងបី រួមមាន÷ ១)- កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ២)- កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និង ៣)- កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ដែលក្នុងនោះ ក៏ផ្តោតសំខាន់លើការបន្តពង្រឹងគុណភាព ស្ថាប័ន និងធនធានមនុស្សនៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធ ផងដែរ។
- ក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាលមានការយកចិត្តទុកដាក់ខ្ពស់ ក្នុងការបំពាក់បំប៉នសមត្ថភាពដល់មន្ត្រីពាក់ព័ន្ធជាប់ជាប្រចាំ ជាពិសេស លើការងារគ្រប់គ្រងការវិនិយោគសាធារណៈ តាមរយៈការរៀបចំកម្មវិធីបណ្តុះបណ្តាលក្នុងប្រទេស និងការបញ្ជូនឱ្យទៅចូលរួមវគ្គបណ្តុះបណ្តាលនៅក្រៅប្រទេស។
- មានការជ្រើសរើសមន្ត្រីថ្មី វ័យក្មេង ដែលមានសមត្ថភាព និងឆន្ទៈខ្ពស់បន្ថែម នៅតាមក្រសួង-ស្ថាប័នពាក់ព័ន្ធ តាមរយៈការប្រលងប្រកបដោយតម្លាភាព។

### ៥.២ ចំណុចខ្សោយ

ទន្ទឹមនឹងចំណុចខ្លាំងខាងលើ រាជរដ្ឋាភិបាល ក៏មើលឃើញនូវចំណុចខ្សោយមួយចំនួនរបស់កម្ពុជាផងដែរ ពាក់ព័ន្ធនឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្សក្នុងការគ្រប់គ្រងការវិនិយោគសាធារណៈបច្ចុប្បន្ន ដែលមានដូចខាងក្រោម÷

- រចនាសម្ព័ន្ធគ្រប់គ្រងបច្ចុប្បន្ននៅតាមក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួន លើការងារគ្រប់គ្រងការវិនិយោគសាធារណៈ ពុំទាន់បានឆ្លើយតបពេញលេញទៅនឹងបរិការណ៍ជាក់ស្តែងនៃការវិវត្តសេដ្ឋកិច្ចកម្ពុជា និងឧត្តមានុវត្តជាអន្តរជាតិ ដែលទាមទារឱ្យក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងនោះ ត្រូវបន្តយកចិត្តទុកដាក់ក្នុងការកែលម្អបន្ថែមទៀត។
- សមត្ថភាពមន្ត្រីពាក់ព័ន្ធតាមក្រសួង-ស្ថាប័នលើការងារគ្រប់គ្រងការវិនិយោគសាធារណៈ នៅតាមដំណាក់កាលនីមួយៗនៃវដ្តគម្រោង នៅមានកម្រិត បើទោះជាកន្លងមកក្រសួង-ស្ថាប័នពាក់ព័ន្ធនីមួយៗ ខិតខំកសាងបាននូវធនធានមនុស្សមួយចំនួនរួចហើយក្តី ក៏ប៉ុន្តែ ទាំងចំនួន និងទាំងសមត្ថភាព នៅពុំទាន់អាចឆ្លើយតបបានទៅនឹងទំហំការងារបច្ចុប្បន្ន ក៏ដូចជាអនាគតនៅឡើយ។
- ផលវិបាកក្នុងការរក្សាទុកធនធានមនុស្សដែលមានស្រាប់ ឱ្យនៅបន្តធ្វើការងារ និងទាក់ទាញធនធានមនុស្សថ្មីបន្ថែម ដែលមានសមត្ថភាព និងឆន្ទៈវិជ្ជាជីវៈខ្ពស់ ឱ្យមកបម្រើការងារ ដោយសារប្រព័ន្ធផ្តល់ការលើកទឹកចិត្តបច្ចុប្បន្ន នៅមិនទាន់មានភាពប្រកួតប្រជែង។

### ៥.៣ កាលានុវត្តភាព

ទន្ទឹមនឹងចំណុចខ្លាំង និងចំណុចខ្សោយដែលបានរៀបរាប់ខាងលើ, រាជរដ្ឋាភិបាលយល់ឃើញថា មានកាលានុវត្តភាពក្នុងការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ពាក់ព័ន្ធនឹងកិច្ចការគ្រប់គ្រងការវិនិយោគសាធារណៈ ទាំងផ្នែកបច្ចេកទេស និងផ្នែកហិរញ្ញវត្ថុ ដូចខាងក្រោម÷

- **ផ្នែកបច្ចេកទេស÷** កម្ពុជាមានជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា (ដូចជា÷ មូលនិធិរូបិយវត្ថុអន្តរជាតិ, ធនាគារពិភពលោក, និងធនាគារអភិវឌ្ឍន៍អាស៊ី ជាដើម) តាមរយៈការផ្តល់ជំនាញការអន្តរជាតិ ឬអ្នកជំនាញបច្ចេកទេស មកធ្វើបទបង្ហាញនៅក្នុងវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលា ដើម្បីផ្តល់ចំណេះដឹង និងបទពិសោធន៍ពាក់ព័ន្ធនឹងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ។
- **ផ្នែកហិរញ្ញវត្ថុ÷** រាជរដ្ឋាភិបាលអាចប្រើប្រាស់ជំនួយហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍ និងពីប្រភពផ្សេងទៀត សម្រាប់ហិរញ្ញប្បទានមន្ត្រីពាក់ព័ន្ធទៅចូលរួមសិក្ខាសាលា, វគ្គបណ្តុះបណ្តាល, ទស្សនកិច្ចសិក្សា, សន្និសីទ, វេទិកា ទាំងក្នុងស្រុក និងក្រៅប្រទេស និងសម្រាប់ផ្តល់ការលើកទឹកចិត្តដល់មន្ត្រីដែលមានសមត្ថភាព និងឆន្ទៈវិជ្ជាជីវៈខ្ពស់។

### ៥.៤ ការគំរាមកំហែង

រាជរដ្ឋាភិបាលយល់ឃើញថា ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្សពាក់ព័ន្ធនឹងការគ្រប់គ្រងការវិនិយោគសាធារណៈកម្ពុជា អាចនឹងទទួលរងនូវការគំរាមកំហែងមួយចំនួនពីកត្តាខាងក្រៅ ដូចខាងក្រោម÷

- ភាពទាក់ទាញខ្លាំងនៃការងារនៅតាមវិស័យឯកជន និងអង្គការ ស្ថាប័ននានា ដែលអាចជាបញ្ហាប្រឈមដ៏ចម្បងចំពោះក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ក្នុងការរក្សាទុក និងស្រូបយកនូវធនធានមនុស្សល្អៗ ឱ្យនៅបន្ត និងមកបម្រើការងារ។
- ភាពវិវត្តឥតឈប់ឈរនៃវិស័យព័ត៌មានវិទ្យា ដែលកម្ពុជាអាចនឹងពិបាកក្នុងការបត់បែនបានភ្លាមៗនូវរបៀបរបបនៃការអនុវត្តការងារ។
- ការផ្លាស់ប្តូរគោលនយោបាយជាយថាហេតុរបស់ដៃគូអភិវឌ្ឍន៍ ក្នុងការផ្តល់ជំនួយបច្ចេកទេសដល់កម្ពុជា។

## ៦. ផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ២០១៩ - ២០២៥

ក្នុងគោលបំណងពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ពាក់ព័ន្ធនឹងការគ្រប់គ្រងការវិនិយោគសាធារណៈ សំដៅរួមចំណែកទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ចរយៈពេលវែង រាជរដ្ឋាភិបាលអនុញ្ញាតឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្តប្រើប្រាស់ជំនួយពីដៃគូអភិវឌ្ឍន៍ និងពីប្រភពផ្សេងទៀត ក្នុងការអនុវត្តផែនការសកម្មភាពអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ដូចតទៅ÷

### ៦.១ ផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍសមត្ថភាពស្ថាប័ន

ដើម្បីអភិវឌ្ឍសមត្ថភាពក្រសួង-ស្ថាប័នពាក់ព័ន្ធនឹងការវិនិយោគសាធារណៈ ឱ្យមានភាពរឹងមាំ និងមានសមត្ថភាពពេញលេញ ក្នុងកម្រិតប្រកួតប្រជែងជាមួយប្រទេសក្នុងតំបន់ និង/ឬ លើសកលលោក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តនូវផែនការសកម្មភាព ដូចខាងក្រោម÷

១)- ចាត់វិធានការចាំបាច់នានាក្នុងការរក្សាទុកមន្ត្រីមានសមត្ថភាព និងឆន្ទៈវិជ្ជាជីវៈខ្ពស់ដែលមានស្រាប់តាមរយៈការពិនិត្យឡើងវិញលើប្រព័ន្ធផ្តល់ការលើកទឹកចិត្ត។

២)- ជ្រើសរើសមន្ត្រីថ្មីដែលមានសមត្ថភាព និងឆន្ទៈវិជ្ជាជីវៈខ្ពស់បន្ថែមទៀត ប្រកបដោយតម្លាភាព ឱ្យស្របតាមទំហំការងារជាក់ស្តែង។

៣)- បន្តអនុវត្តអភិក្រម **«រៀនផង-ធ្វើផង»**។

### ៦.២ ផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស

ដើម្បីពង្រឹងសមត្ថភាពធនធានមនុស្សពាក់ព័ន្ធនឹងការងារគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តនូវផែនការសកម្មភាព ដូចខាងក្រោម÷

១)- បន្តយកចិត្តទុកដាក់កសាងសមត្ថភាពមន្ត្រីពាក់ព័ន្ធនឹងការវិនិយោគសាធារណៈ លើមុខជំនាញសំខាន់ៗ ដូចជា÷

- ការរៀបចំឯកសារទស្សនទានគម្រោង (Project Concept Note)
- ការវាយតម្លៃ និងការធ្វើអាទិភាវូបនីយកម្មនៃសំណើគម្រោង

- ការរៀបចំសិក្សាសមិទ្ធិលទ្ធភាពនៃសំណើគម្រោង រួមទាំងការសិក្សាលើទិដ្ឋភាពបច្ចេកទេស, សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ច្បាប់, និង សង្គមនិងបរិស្ថាន
- ការពិនិត្យ និងជ្រើសរើសគម្រោង (Project screening/selection)
- ការកំណត់ចរិតលក្ខណៈនៃគម្រោងវិនិយោគសាធារណៈ (Defining project characteristics)
- ការកំណត់សមិទ្ធិផលជាក់លាក់ (Output specification)
- ការធ្វើរចនាសម្ព័ន្ធគម្រោង (Project structuring)
- ការរៀបចំកិច្ចសន្យាគម្រោងវិនិយោគសាធារណៈ (Project contract)
- ការរៀបចំផែនការគ្រប់គ្រងកិច្ចសន្យា (Contract management plan)
- ការរៀបចំផែនការ និងការធ្វើកិច្ចលទ្ធកម្ម (Procurement Plan) ដោយរួមបញ្ចូលទាំងការរៀបចំឯកសារដេញថ្លៃ និងការវាយតម្លៃសំណើដេញថ្លៃផងដែរ
- ការបែងចែកហានិភ័យក្នុងគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (Risk allocation)
- ការវិភាគ និងវាយតម្លៃគម្រោងតាមវិធីសាស្ត្រតម្លៃនៃលុយ (Value for Money)
- ការវិភាគគំរូហិរញ្ញវត្ថុ (Financial model for optimization of project life cycle cost)
- ការពិនិត្យ និងតាមដានការអនុវត្តគម្រោងវិនិយោគសាធារណៈ
- ការគ្រប់គ្រងហានិភ័យនៃគម្រោងវិនិយោគសាធារណៈ
- ការគណនាកាតព្វកិច្ចបំណុលជាយថាហេតុ (Contingent Liability Calculation)
- វិធីសាស្ត្រវាយតម្លៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PIMA) របស់ IMF
- និងមុខជំនាញពាក់ព័ន្ធផ្សេងទៀត។

២)- បន្តបណ្តុះបណ្តាលសមត្ថភាពមន្ត្រីពាក់ព័ន្ធ តាមអភិក្រម ដូចខាងក្រោម៖

- ការបណ្តុះបណ្តាលក្នុងស្រុក ដែលរួមមាន៖ ១)- ការរៀបចំវគ្គបណ្តុះបណ្តាលជំនាញដែលបង្ហាត់បង្ហាញដោយជំនាញការអន្តរជាតិ ឬ មន្ត្រីនៃស្ថាប័នជំនាញអន្តរជាតិនានា, ២)ការរៀបចំសិក្ខាសាលា ឬវេទិកា ឬសន្និសីទ ដោយមានការចូលរួមពីជំនាញការជាតិ អន្តរជាតិ ឬមន្ត្រីជំនាញនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ, និង ៣)- ការសិក្សាតាមប្រព័ន្ធអ៊ីនធើណែត។
- ការបណ្តុះបណ្តាលក្រៅប្រទេស ដែលរួមមាន៖ ១)- ការចូលរួមវគ្គបណ្តុះបណ្តាលជំនាញ ដែលរៀបចំដោយអង្គការ-ស្ថាប័នក្នុងតំបន់ ឬ អន្តរជាតិនានា, ២)- ការចូលរួមសិក្ខាសាលា វេទិកា ឬសន្និសីទក្នុងតំបន់ ឬអន្តរជាតិ លើប្រធានបទជំនាញពាក់ព័ន្ធ, និង ៣)- ការធ្វើទស្សនកិច្ចសិក្សានៅតាមក្រសួង-ស្ថាប័នជំនាញនៃប្រទេសក្នុងតំបន់ និងប្រទេសជឿនលឿននានាលើសកលលោក។ បន្ថែមលើនេះ ត្រូវរៀបចំឱ្យមានកម្មវិធីបណ្តុះបណ្តាលផ្ទៃក្នុងនៅតាមក្រសួង-ស្ថាប័ន ដើម្បីជាការចែករំលែកចំណេះដឹងបន្ត ពីមន្ត្រីដែលបានចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេស ដល់មន្ត្រីពាក់ព័ន្ធផ្សេងទៀត។

## ៧. គម្រោងប៉ាន់ស្មានថវិកាចំណាយសម្រាប់ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស

*ឯកតា÷ ពាន់ដុល្លារអាមេរិក*

| ផែនការសកម្មភាព | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ឆ្នាំទី៥ | ឆ្នាំទី៦ | សរុប |
|---|---|---|---|---|---|---|---|
| ១. ក្នុងស្រុក | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ៦០០ |
| ក. វគ្គបណ្តុះបណ្តាលជំនាញ | ៥០ | ៥០ | ៥០ | ៥០ | ៥០ | ៥០ | ៣០០ |
| ខ. សិក្ខាសាលា | ២៥ | ២៥ | ២៥ | ២៥ | ២៥ | ២៥ | ១៥០ |
| គ. វេទិកា | ១០ | ១០ | ១០ | ១០ | ១០ | ១០ | ៦០ |
| ឃ. សន្និសីទ | ១០ | ១០ | ១០ | ១០ | ១០ | ១០ | ៦០ |
| ង. ការសិក្សាតាមប្រព័ន្ធអ៊ីធើណែត | ៥ | ៥ | ៥ | ៥ | ៥ | ៥ | ៣០ |
| ២. ក្រៅស្រុក | ២៥០ | ២៥០ | ២៥០ | ២៥០ | ២៥០ | ២៥០ | ១ ៥០០ |
| ក. វគ្គបណ្តុះបណ្តាលជំនាញ | ៥០ | ៥០ | ៥០ | ៥០ | ៥០ | ៥០ | ៣០០ |
| ខ. សិក្ខាសាលា | ៥០ | ៥០ | ៥០ | ៥០ | ៥០ | ៥០ | ៣០០ |
| គ. វេទិកា | ២៥ | ២៥ | ២៥ | ២៥ | ២៥ | ២៥ | ១៥០ |
| ឃ. សន្និសីទអន្តរជាតិ | ២៥ | ២៥ | ២៥ | ២៥ | ២៥ | ២៥ | ១៥០ |
| ង. ទស្សនកិច្ចសិក្សា | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ៦០០ |
| **សរុប (១+២)÷** | **៣៥០** | **៣៥០** | **៣៥០** | **៣៥០** | **៣៥០** | **៣៥០** | **២ ១០០** |

# សមាសភាព

# ក្រុមការងារបច្ចេកទេស

# រៀបចំយុទ្ធសាស្ត្រស្តីពី

# ការកែទម្រង់ប្រព័ន្ធគ្រប់គ្រង

# ការវិនិយោគសាធារណៈ

# ២០១៩ - ២០២៣

## សមាសភាពក្រុមការងារបច្ចេកទេស
## រៀបចំយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ - ២០២៥

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម | **ប៉ែន ធីរុទ្ធ** | អគ្គនាយក នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល (អ.ស.ប) និងជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) |
| ២- | លោកបណ្ឌិត | **ឌី សុវណ្ណា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ |
| ៣- | លោក | **ម៉ាង សុភាវ៉ា** | ប្រធាននាយកដ្ឋានគ្រប់គ្រងបំណុល នៃ អ.ស.ប. |
| ៤- | លោក | **ហ៊ុល បុណ្ណារ័ត្ន** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការពហុភាគី នៃ អ.ស.ប. |
| ៥- | លោក | **ឱម ម៉ាក់ឆារិទ្ធ** | អនុប្រធាន នៃអង្គភាពភាពជាដៃគូរវាងរដ្ឋ និងឯកជនថ្នាក់កណ្តាល (អ.រ.ជ.) |
| ៦- | លោក | **ប៉ុម លៃហេង** | មន្ត្រីជំនាញជាន់ខ្ពស់ នៃ អ.គ.ហ. |
| ៧- | លោក | **ហៀង សុយ៉ាវ៉ូ** | មន្ត្រីជំនាញជាន់ខ្ពស់ នៃ អ.គ.ហ. |
| ៨- | លោក | **ជា សុភ័ក្ត** | ប្រធានផ្នែក នៃ អ.រ.ជ. |
| ៩- | លោកស្រី | **ឈុន វីរៈវឌ្ឍនា** | ប្រធានការិយាល័យ នៃ អ.ស.ប. |
| ១០- | លោក | **ឡាយ សុភ័ក្រ្ត** | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានថវិកា (អ.ថ.) |
| ១១- | លោក | **ចាន់ ពលរិទ្ធ** | អនុប្រធានការិយាល័យ នៃ អ.ថ. |
| ១២- | លោកស្រី | **ឌុន បូនីតា** | អនុប្រធានការិយាល័យ នៃ អ.ស.ប. |
| ១៣- | លោក | **ជាង សុវុទ្ធី** | អនុប្រធានការិយាល័យ នៃ អ.ស.ប. |
| ១៤- | លោក | **លឹម សុខហេង** | មន្ត្រីជំនាញ នៃ អ.គ.ហ. |
| ១៥- | លោក | **ហាក់ វុទ្ធិកា** | មន្ត្រីជំនាញ នៃ អ.រ.ជ. |
| ១៦- | លោក | **សិង សុបញ្ញាវឌ្ឍន៍** | មន្ត្រីជំនាញ នៃ អ.ថ. |
| ១៧- | លោក | **ឡូន សុភាផល្លា** | មន្ត្រីជំនាញ នៃ អ.ស.ប. |
| ១៨- | លោក | **អ៊ុច កិត្យា** | ជំនាញការផ្នែកសម្របសម្រួលគម្រោង នៃ អ.ស.ប |
| ១៩- | លោក | **អ៊ុន ពិសិដ្ឋ** | ជំនាញការផ្នែកគ្រប់គ្រងបំណុល នៃ អ.ស.ប |
| ២០- | កញ្ញា | **ធឿន វត្តីឆត្រីស្ទីនា** | ជំនាញការផ្នែកគ្រប់គ្រងបំណុល នៃ អ.ស.ប |
| ២១- | លោក | **វង់ ពេជ្រវិសាល** | ជំនាញការផ្នែកគ្រប់គ្រងបំណុល នៃ អ.ស.ប |